ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jul-2017, 14:01
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# លើសេចក្តីសន្និដ្ឋានផ្តល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៥០០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក រ៉ូស្សែល ហាប់គីនស៍
*(Mr. Russell HOPKINS)*
កញ្ញា ជា ស៊ីវហ័ង
កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms.Maddalena Ghezzi)*
លោកស្រី អេលីន័រ គ្លេឌី ហ្វ្រាយ
*(Ms. Elinor Gladys Fry)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*
លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក សេង លាង

លោក ស្រ៊ា រតនៈ

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
(*Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោកស្រី ដូរីន ជិន*(Ms. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រីនណា

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ឡារុស ដេសហ្វស
*(Ms.Larue DESFORGES)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្វ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ជេត វណ្ណលី | ខ្មែរ |
| លោក ហុង គីមសួន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៩:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការលើសំណុំរឿង០០២/០២។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងចាប់ផ្ដើមធ្វើសវនាការស្ដាប់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីនានានៅក្នុងសំណុំរឿង០០២/០២។

មុននឹងចាប់ផ្ដើមកិច្ចដំណើរការសវនាការនេះ អង្គជំនុំជម្រះសូមអញ្ជើញ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការស្ដាប់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។

សូមអរគុណលោកប្រធាន។

[០៩:០១:០៨]

**ប្រធានអង្គជំនុំ៖**

អរគុណ កញ្ញា ជា ស៊ីវហ័ង។

អង្គជំនុំជម្រះសូមជម្រាបរំឭកជូនដល់ភាគី និងសាធារណជនឲ្យបានជ្រាបថា អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទ សម្រាប់ធ្វើសវនាការស្ដាប់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលសំណុំរឿង០០២/០២ ចាប់ពីថ្ងៃនេះ គឺថ្ងៃអង្គារ ទី១៣ ខែមិថុនា ឆ្នាំ២០១៧ ហើយនិងបន្តរហូតដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ ដូចមានបញ្ជាក់នៅក្នុងដីកាកំណត់កាលបរិច្ឆេទធ្វើសវនាការសម្រាប់សេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលដែលអង្គជំនុំជម្រះបានចេញកាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ឯកសារ E457/6។ ដីកាកំណត់កាលបរិច្ឆេទនេះបានកំណត់អំពីនីតិវិធី និងការបែងចែកពេលវេលាសម្រាប់ធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល។ ហើយអង្គជំនុំជម្រះក៏បានជូន

ដំណឹងបន្ថែមស្ដីពីពេលវេលារបស់ភាគីនីមួយៗតាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន កាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ ផងដែរ។ ហើយនីតិវិធីនៃការធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលត្រូវគ្រប់គ្រងដោយវិធាន៩៤ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ភាគីនានាបានដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលលាយលក្ខណ៍អក្សររបស់ខ្លួន មកក្នុងសំណុំរឿង០០២/០២ កាលពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧។ ឯលំដាប់លំដោយនៃការឡើងធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ភាគីត្រូវអនុវត្តស្របតាមវិធាន៩៤(១) នៃវិធានផ្ទៃក្នុង និងតាមពេលវេលាដែលបានបែងចែកឲ្យដូចខាងក្រោមនេះ។

[០៩:០៣:០៤]

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលមួយថ្ងៃ។ សហព្រះរាជអាជ្ញាមានរយៈពេលពីរថ្ងៃ។ ក្រុមមេធាវីការពារក្ដី នួន ជា មានរយៈពេលពីរថ្ងៃ។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន មានរយៈពេលមួយថ្ងៃកន្លះ។ ហើយការធ្វើសេចក្ដីសន្និដ្ឋានតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាមានរយៈពេលមួយថ្ងៃ។ និងការធ្វើសេចក្ដីសន្និដ្ឋានតបចុងក្រោយក្រុមមេធាវីការពារក្ដី និងសេចក្ដីថ្លែងការណ៍ចុងក្រោយរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានរយៈពេលសរុបបួនម៉ោង ដែលនឹងធ្វើឡើងនៅថ្ងៃសុក្រ ទី២៣ ខែមិថុនា ឆ្នាំ២០១៧។

បន្ទាប់ពីបញ្ចប់ការធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល អង្គជំនុំជម្រះនឹងផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ ដោយមិនទាន់កំណត់ពេលវេលា។ អង្គជំនុំជម្រះនឹងពិភាក្សាសម្រេចលើសាលក្រមអនុលោមតាមវិធាន៩៦ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ អង្គជំនុំជម្រះនឹងជូនដំណឹងដល់ភាគី និងសាធារណជនបានជ្រាបអំពីកាលបរិច្ឆេទជាក់លាក់ពីការប្រកាសសាលក្រមនៅក្នុងពេលសមស្របខាងមុខ។

អង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីផងដែរថា ដើម្បីធានាបាននូវប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីនៃការធ្វើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ បិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០២ នេះ និងដើម្បីប្រើប្រាស់ឲ្យមានប្រសិទ្ធភាពបំផុតនូវពេលវេលាដែលបានបែងចែកជូនភាគី សូមលោក លោកស្រី ចងចាំអំពីការប្រើប្រាស់បីភាសានៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ និងគួរតែត្រូវបាននិយាយឲ្យបានយឺតៗ និងច្បាស់។

[០៩:០៤:៥២]

ជាងនេះទៅទៀត ប្រសិនបើមានការលើកឡើងអំពីតួលេខ លោក លោកស្រី គួរតែអានឲ្យបានយឺតៗ។ ចំណែកឯឈ្មោះបុគ្គល ឬក៏ឈ្មោះទីកន្លែងក៏គួរត្រូវបានប្រកបផងដែរ ប្រសិនបើឈ្មោះនោះមានលក្ខណៈខុសប្លែកគ្នា ឬពិបាកសរសេរជាដើម។ ក្នុងករណីមានការផ្លាស់ប្តូរមតិយោបល់របស់ចៅក្រម និងភាគី សូមលោក លោកស្រីរង់ចាំដល់ការបកប្រែភាសាចប់សិន មុននឹងធ្វើការឆ្លើយតប។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនដល់ភាគី និងសាធារណជនផងដែរ ថានៅព្រឹកនេះ អង្គជំនុំជម្រះបានបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា មកចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់នេះ ដោយអនុលោមតាមអនុសាសន៍របស់គ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.កនេះ ដែលបានផ្តល់មកឲ្យអង្គជំនុំជម្រះសាលាដំបូងកាលពីព្រឹកមិញនេះ។ ហើយតាមអនុ-សាសន៍របស់គ្រូពេទ្យ គឺថាសន្និដ្ឋាន ស្ថានភាពសុខភាពរបស់លោក នួន ជា នៅព្រឹកនេះ គឺលោកអាចអង្គុយនៅក្នុងបន្ទប់សវនាការហ្នឹង ប្រមាណជា២០នាទី។

ដូច្នេះ ក្នុងរយៈពេល -- ក្រោយពីរយៈពេល២០នាទី ចាប់ពីពេលនេះតទៅ លោក នួន ជា បើសិនបើលោកមិនអាចបន្តចូលរួមសវនាការទេ គឺលោកអាចទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះបាន ដោយមានការស្នើសុំការអនុញ្ញាតពីយើង។

[០៩:០៦:២៩]

មុននឹងផ្តល់វេទិកាជូនទៅភាគីក្នុងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន អង្គជំនុំជម្រះសូមរំឭកបន្ថែមភាគី ដែលគប្បីអនុវត្តឲ្យបានខ្ជាប់ខ្ជួនតាមសេចក្តីណែនាំសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០២ ដែលបានចេញកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ E457/7។ ដើម្បីមានប្រសិទ្ធភាពនូវការអនុវត្តនៃសេចក្តីណែនាំនេះ និងដើម្បីជាប្រយោជន៍ដល់សាធារណជនដែលចូលរួមតាមដានសវនាការនេះផង យើងនឹងអាននូវខ្លឹម-សារនៃសេចក្តីសម្រេចនេះទាំងស្រុងដែលមានខ្លឹមសារដូចខាងក្រោមនេះ៖

១) ដើម្បីសវនាការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០២ ដែលនឹងចាប់ផ្តើមពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ប្រព្រឹត្តទៅដោយរលូន អង្គជំនុំជម្រះសាលាដំបូងសូមផ្តល់នូវគោលការណ៍ណែនាំដល់គ្រប់ភាគីទាំងអស់ដូចតទៅ៖ ការការពារសាក្សីសុចរិតភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង០០៣ និង០០៤ សូមរំឭកដល់ភាគីទាំងអស់អំពីអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E319/35/15 ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ដែលបាន

អនុម័តយកតាមសេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងអនុស្សរណៈ E319/35/14/3 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧។

[០៩:០៨:១៦]

អង្គជំនុំជម្រះសាលាដំបូងសូមសង្កត់ធ្ងន់ថា ការកំហិតទៅលើការសម្ភាត់នៅតែបន្តអនុវត្តចំពោះសាក្សី និងឯកសារ ដែលមាននៅក្នុងឧបសម្ព័ន្ធនៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង។ ហេតុដូច្នេះ ភាគីទាំងអស់ត្រូវតែយោងទៅរកសាក្សីទាំងអស់នោះ ដោយប្រើរហស្សនាមក្នុងករណីមានរហស្សនាម ឬប្រើលេខឯកសារកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលពាក់ព័ន្ធក្នុងករណីធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល។

ភស្តុតាងដែលមិនត្រូវបានទទួលយក និង សំណើសុំឲ្យពិចារណាឡើងវិញ។ សូមរំឭកដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះអាចពឹងផ្អែកទៅលើសេចក្ដីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងទាំងឡាយណា ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ។

អង្គជំនុំជម្រះកត់សម្គាល់ថា នៅក្នុងសារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន មេធាវីការពារក្ដី នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះពិចារណាឡើងវិញ នូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដែលបានបដិសេធក្នុងការទទួលយកសម្ភារៈដែលមាននៅក្នុងឧបសម្ព័ន្ធ១ អង្គជំនុំជម្រះនឹងដោះស្រាយសំណើសុំនៅក្នុងពេលវេលាសមស្រប។ ជាករណីលើកលែង និងដោយមិនបង្កឲ្យមានព្យសនកម្មចំពោះសេចក្ដីសម្រេចចុងក្រោយនោះ នៅក្នុងអំឡុងពេលធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលខាងមុខនេះ ភាគីត្រូវបានអនុញ្ញាតឲ្យយោងទៅរកសម្ភារៈ ដែលជាផ្នែកមួយនៃសំណើសុំឲ្យពិចារណាឡើងវិញបាន។

[០៩:០៩:៥៥]

ភាគីណាមួយដែលបានជ្រើសរើសយកការយោងទៅរកសម្ភារៈបែបនេះ ក្នុងពេលដែលធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ត្រូវបញ្ជាក់ឲ្យបានច្បាស់លាស់ដល់ភាគីដទៃទៀត ក៏ដូចជាដល់សាធារណជនផងដែរ។ នៅក្នុងបរិបទនេះ អង្គជំនុំជម្រះសាលាដំបូងសង្ឃឹមថា ភាគីទាំងអស់នឹងផ្ដោតការយកចិត្តទុកដាក់ទៅលើភស្តុតាង ដែលពួកគេពឹងផ្អែកនៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ ទោះបីជាយ៉ាងណា ក្នុងអំឡុងពេលសវនាការស្ដាប់សេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ភាគីនឹងមិនត្រូវបានអនុញ្ញាតឲ្យយោងទៅលើរកសម្ភារៈដែលមិនត្រូវបានស្នើសុំឲ្យ

ទទួលយកធ្វើជាឯកសារភស្តុតាង និងដែលមិនត្រូវបានជូនដំណឹងដល់អង្គជំនុំជម្រះ ព្រមទាំងភាគីផ្សេងៗទៀតនោះឡើយ។ ការពិចារណាឡើងវិញ អង្គជំនុំជម្រះសាលាដំបូងសូមកត់សម្គាល់ថា នៅក្នុងសារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន មេធាវីការពារក្តី នួន ជា បានស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការពិចារណាឡើងវិញ លើសំណើសុំស្តាប់សក្ខីកម្មសាក្សី និងសំណើសុំបំពេញកិច្ចស៊ើបសួរមួយចំនួនរបស់មេធាវីការពារក្តី ដែលត្រូវបានអង្គជំនុំជម្រះបដិសេធ។ អង្គជំនុំជម្រះនឹងដោះស្រាយសំណើទាំងនេះនៅក្នុងពេលវេលាសមស្រប។ ចម្លើយដែលទទួលបានដោយការធ្វើទារុណកម្ម អង្គជំនុំជម្រះសូមរំឭកយោងទៅមាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចម្លើយដែលទទួលបានក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្ត គ្មានតម្លៃជាភស្តុតាងទេ។

[០៩:១១:៣២]

បន្ថែមលើនេះ ផ្អែកលើបទប្បញ្ញត្តិមាត្រា១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម ចម្លើយទាំងឡាយណាដែលត្រូវបានកំណត់ថា ទទួលបានដោយសារការធ្វើទារុណកម្ម នឹងមិនត្រូវយកមកប្រើប្រាស់នៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ។ លើកលែងតែ ការយកមកប្រើប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានធ្វើទារុណកម្ម ដើម្បីជាភស្តុតាងថាចម្លើយនោះត្រូវបានធ្វើឡើង។ អង្គជំនុំជម្រះសម្រេចថា ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្មមិនអាចប្រើប្រាស់សម្រាប់បញ្ជាក់ការពិតនៃខ្លឹមសាររបស់ភស្តុតាងនោះឡើយ។ ទោះជាបែបនេះក្តី ព័ត៌មានបែបសត្យានុម័ត ដែលមាននៅក្នុងចម្លើយសារភាពទាំងនោះ ដូចជាកាលបរិច្ឆេទនៃការចាប់ខ្លួន ដែលមិនមែនជាផ្នែកចម្លើយ នោះអាចប្រើប្រាស់បាន។ ដូចគ្នានេះដែរ ចំពោះចំណារដែលបានចារលើចម្លើយសារភាពដោយអ្នកសួរចម្លើយ ឬថ្នាក់លើរបស់ពួកគេក៏អាចប្រើបានដែរ។ អង្គជំនុំជម្រះសូមរំឭកអំពីសេចក្តីសម្រេចរបស់ខ្លួនដែលថា ហានិភ័យពិតប្រាកដដែលកើតមានឡើងគឺថា ការធ្វើទារុណកម្មត្រូវបានប្រើប្រាស់នៅមន្ទីរសន្តិសុខស-២១ និងមន្ទីរសន្តិសុខដទៃទៀត ដើម្បីទទួលបានចម្លើយសារភាព។ ឯកសារ E350/8 កថាខណ្ឌ៧៩។ ភាគីណាមួយដែលបាន-- ដែលស្នើសុំប្រើប្រាស់ភស្តុតាងបែបនេះ អាចជំទាស់ទៅនឹងការសេចក្តីសម្រេចបឋមនេះបាន ជាពិសេសដែលផ្អែកទៅលើការបង្ហាញនៅកាលៈទេសៈជាក់លាក់ផ្សេងៗ ដែលអាចច្រានចោលនៅហានិភ័យបែបនេះ។ ដោយសារហេតុនេះហើយ ទើបនៅក្នុងសវនាការពិភាក្សាដេញដោលពិនិត្យភស្តុតាងកន្លងមក អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យប្រើប្រាស់ចម្លើយសារភាពដែលទទួលបានមកពីមន្ទីរសន្តិសុខឡើយ រាប់ទាំងមន្ទីរសន្តិសុខស-២១ ផងដែរ ដែលមិនបានបង្ហាញថា ចម្លើយទាំងនោះមិន

មែនទទួលបានដោយការធ្វើទារុណកម្ម។

[០៩:១៣:៣៧]

ដោយសារតែជនជាប់ចោទនៅក្នុងសំណុំរឿងនេះត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម អង្គជំនុំជម្រះត្រូវកំណត់បទដ្ឋាននៃការបង្ហាញភស្តុតាងផ្សេងពីនេះ និងខ្ពស់ជាងនេះមួយស្ដីពីការធ្វើទារុណកម្មបានកើតមានឡើងដែរឬទេ។ នៅពេលពិចារណាលើភស្តុតាងទាំងអស់ ដែលមាននៅក្នុងដំណាក់កាលសរសេរសាលក្រម និងផ្អែកលើបទដ្ឋានសម្រាប់ការផ្តន្ទាទោសចំពោះការធ្វើទារុណកម្មនេះ ការកំណត់បឋមរបស់អង្គជំនុំជម្រះ អំពីហានិភ័យពិតប្រាកដទៅលើភស្តុតាងបានមកដោយការធ្វើទារុណកម្មកន្លងមកអាចខុសពីសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួន។ ដោយសារតែកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលពិនិត្យភស្តុតាងត្រូវបានបញ្ចប់ហើយនោះ មិនមានគ្រោះថ្នាក់ណាមួយកើតឡើងដែលថា សាក្សីដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលរងនូវឥទ្ធិពលដោយមិនសមស្រប ដោយសារភស្តុតាងបានមកដោយការធ្វើទារុណកម្ម។ ហេតុដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីយោងទៅរកព័ត៌មានបែបនេះបាន ក្នុងករណីដែលយល់ឃើញថាចាំបាច់នៅក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ប៉ុន្តែភាគីត្រូវចងចាំ និងបញ្ជាក់នៅមុនពេលពិភាក្សាលើឯកសារបែបនេះ អង្គជំនុំជម្រះបានសន្មតថាភស្តុតាងដែលនឹងលើកយកមកពិភាក្សានេះ បានមកដោយការធ្វើទារុណកម្ម។

[០៩:១៥:០១]

ការបញ្ជាក់បែបនេះ គឺជាការផ្តល់នូវការជូនដំណឹងសមស្របមួយអំពីលក្ខណៈនៃភស្តុតាងដែលត្រូវយកមកពិភាក្សា ហើយប្រសិនបើមិនមានការបញ្ជាក់បែបនេះទេ ភាគីនានា និងសាធារណជនអាចមានការយល់ច្រឡំ។ អង្គជំនុំជម្រះអនុម័តយកវិធីសាស្ត្របែបនេះសម្រាប់ភស្តុតាងនានាដែលទទួលបានដោយសារការធ្វើទារុណកម្ម ដើម្បីសម្រួលដល់ការសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលដោយមិនមានការរំខានតាមដែលអាចធ្វើទៅបាន។

បាទ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល និងធ្វើសេចក្តីសន្និដ្ឋានស្តីពីការទាមទារសំណងស្ថាពររបស់ខ្លួន។ ហើយក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយថ្ងៃនៃថ្ងៃសវនាការ។ បាទ សូមអញ្ជើញ!

[០៩:១៦:០៤]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ពេជ អង្គ៖**

ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី សាធារណជន និងដើមបណ្តឹងរដ្ឋប្បវេណី។ ថ្ងៃអង្គារ ទី១៣ ខែមិថុនា ឆ្នាំ២០១៧នេះ ជាឱកាសមួយដ៏ល្អសម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានអនុញ្ញាតឲ្យលើកឡើងនូវសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួន ដោយរំលេចខ្លីៗអំពីហេតុការណ៍ និងព្យសនកម្មទាំងឡាយដែលពួកគាត់បានជួបប្រទះ ក៏ដូចជាទទួលរង និងលើកអំពីគម្រោងសំណងដែលខ្លួនមានសម្រាប់ជូនតុលាការទទួលស្គាល់ បន្ទាប់ពីមានសវនាការដេញដោលជាង២០០ថ្ងៃកន្លងមកនេះ។ ខ្ញុំបាទ សូមអនុញ្ញាតជម្រាបថា យើងខ្ញុំជាមេធាវីនាំមុខ និងតំណាងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺជាអ្នកតំណាងឲ្យក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី ដែលដើមឡើយក្រុមនេះ មានចំនួនដើមបណ្តឹងរដ្ឋប្បវេណី ៣.៨៦៧រូប។

[០៩:១៧:២៧]

នៅក្នុងចំណោមពួកគាត់ទាំងនោះ គឺមាន២.១៩៥រូប ស្ថិតនៅរាជធានីភ្នំពេញនិងខេត្តនៅជិតខាងនៃរាជធានីភ្នំពេញ។ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១.០៩៣រូប ស្ថិតនៅខេត្តឆ្ងាយនៃរាជធានីភ្នំពេញដែលប្រមូលផ្តុំ ជាពិសេស២១២រូបនៅក្នុងខេត្តកំពង់ធំ និង២៦៨រូបនៅក្នុងខេត្តពោធិ៍សាត់។ ចំនួនដើមបណ្តឹងរដ្ឋប្បវេណីទាំង៣.៨៦៧រូបនេះ មិនស្ថិតនៅដដែលនោះទេ។ ចាប់ពីពេលមានការចាប់ផ្តើមសវនាការមក ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៨១រូប ត្រូវបានជូនដំណឹងថាស្លាប់ និងក្នុងនោះមាន៣៤ពាក្យសុំអំពីសាច់ញាតិរបស់ពួកគាត់ ស្នើសុំបន្តបណ្តឹងរបស់ពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី។

ក្នុងសំណុំរឿង០០២ វគ្គពីរនេះ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៤រូបបានផ្តល់សក្ខីកម្ម ដែលនៅក្នុងនោះ ៦៣រូប បានផ្តល់សក្ខីកម្មបានចប់សព្វគ្រប់ ហើយ១០រូបក្នុងចំណោមពួកគាត់មានអាយុ១៦ឆ្នាំនាសម័យ១៩៧៥ ដល់ ១៩៧៩។ ហើយក៏មានប្រជាជនថ្មី និងប្រជាជនមូលដ្ឋានផងដែរ។ ហើយនៅក្នុងនោះមាន១៦រូប ជាអតីតខ្មែរក្រហមផងដែរ។

[០៩:១៩:១២]

ដូចបានបញ្ជាក់នៅក្នុងវិធាននីតិវិធី ២៣ស្ទួនបួន នៃសាលាក្តីខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមនៅក្នុងរឿងក្តីនេះគឺមានគោលដៅចំនួនពីរ៖ ទី១ ប្តឹងប្រឆាំងនឹងជនជាប់ចោទ ដោយគាំទ្រព្រះរាជអាជ្ញា ការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ ទី២ គឺស្វែងរកសំណងដែលមានលក្ខណៈជាផ្លូវចិត្ត

ផង និងជាសមូហភាពផង។ ចំពោះសេចក្ដីថ្លែងការណ៍ថ្ងៃនេះ មេធាវីនាំមុខនឹងលើកជាដំបូងអំពីការរំលេចចេញនូវហេតុការណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ដែលបានមកផ្ដល់សក្ខីកម្ម ចំពោះសវនាការនេះ ដែលសក្ខីកម្មទាំងនេះនឹងជួយទៅដល់លោក លោកស្រីចៅក្រម ពិចារណាដោយផ្ទុះបញ្ជាំងទៅធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់ ហើយក៏មានការលើកឡើងអំពីព្យសនកម្ម ការខូចខាត ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងផងដែរ។ ខ្ញុំបាទ ពេជ អង្គ នឹងលើកសេចក្ដីសន្និដ្ឋានលើការដ្ឋានការងារ និងការធ្វើទុក្ខបុកម្នេញលើប្រជាជនចាម។ ចំណែកឯលោកស្រី ជេត វណ្ណលី នឹងធ្វើសេចក្ដីសន្និដ្ឋានលើសហករណ៍ត្រាំកក់ ការធ្វើទុក្ខបុកម្នេញលើព្រះពុទ្ធសាសនា និង មន្ទីរសន្តិសុខក្រាំងតាចាន់ ដែលស្ថិតនៅទីនោះ។ ចំណែកឯលោកមេធាវី ហុង គឹមសួន នឹងឡើងធ្វើការសន្និដ្ឋានផ្ទាល់មាត់ទាក់ទងទៅនឹងមន្ទីរសន្តិសុខចំនួនបី និងការបោសសម្អាតផ្ទៃក្នុង។

[០៩:២១:០០]

ជាចុងក្រោយលោកស្រីសហមេធាវីនាំមុខ ម៉ារី ហ្គីរ៉ូដ៍ នឹងធ្វើសេចក្ដីសន្និដ្ឋានទៅលើការប្រព្រឹត្តទៅលើជនជាតិវៀតណាម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និង ការដាក់បទបញ្ជាទៅលើអាពាហ៍ពិពាហ៍។ ហើយនៅវគ្គចុងក្រោយបំផុតនៅថ្ងៃនេះ មេធាវីនាំមុខ គឺលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ហើយនិងខ្ញុំបាទនឹងលើកឡើងអំពីបណ្ដុំនៃសំណើគម្រោងសំណងសមូហភាព និងផ្លូវចិត្តមួយចំនួន ដែលមានថវិកាត្រូវបានធានារួចហើយសម្រាប់អនុវត្ត សម្រាប់ជូនលោក លោកស្រីចៅក្រមទទួលស្គាល់។ នៅក្នុងដំណើរការនៃការធ្វើបទបង្ហាញសន្និដ្ឋានផ្ទាល់មាត់នេះ យើងខ្ញុំសូមស្នើទៅដល់លោកប្រធានផងដែរថា សូមលោកប្រធានអនុញ្ញាតឲ្យយើងខ្ញុំដាក់បញ្ចាំងវីដេអូខ្លីៗ និងរូបថតនានា រួមទាំងឯកសារផ្សេងៗទៀត ដែលយើងខ្ញុំបានរៀបចំ និងប្រគល់ជូនទៅផ្នែកសោតទស្សន៍រួចហើយ ដោយមិនបាច់ស្នើសុំលោកប្រធានរាល់លើក ដែលត្រូវបញ្ចាំងនីមួយៗ។

បាទ សូមអរគុណ។ ខ្ញុំឃើញលោកប្រធានអនុញ្ញាតងក់ ក្បាល។

**ប្រធានអង្គជំនុំ៖**

បាទ យើងអនុញ្ញាតក្នុងលក្ខខណ្ឌតែឯកសារភស្តុតាងដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះរួចហើយ ដោយអង្គជំនុំជម្រះបានទទួល ហើយយកពិភាក្សាដេញដោលរួចហើយ។ អ៊ីចឹងប្រយ័ត្នប្រយែង បើសិនជាករណីខុសពីនេះ បានន័យថា សម្ភារៈផ្សេងទៀត ដែលអង្គជំនុំជម្រះមិនទាន់បានទទួលយកជាឯកសារភស្តុតាង គឺអង្គជំនុំជម្រះមិនអនុញ្ញាតទេ។

[០៩:២២:៥១]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ យើងខ្ញុំនឹងប្រើតែឯកសារដែលបានប្រើប្រាស់ -- អនុញ្ញាតរួចហើយតែប៉ុណ្ណោះ។

ជាបន្តទៅទៀតនេះ គឺខ្ញុំសូមអនុញ្ញាតនិយាយអំពីបញ្ហាដែលពាក់ព័ន្ធទៅនឹងការដ្ឋានការងារ។ ខ្ញុំសូមលើកថា នៅក្នុងសុន្ទរកថារបស់លោក ខៀវ សំផន នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ក្នុងឱកាសខួបលើកទី២ នៃជ័យជម្នះ ១៧ មេសា ១៩៧៥ លោក ខៀវ សំផន បាននិយាយនៅក្នុងសុន្ទរកថារបស់គាត់ថា គ្រប់ការដ្ឋានសាងសង់ ដែលគេកំពុងសាងសង់ទំនប់ទឹក ជីកអាងស្តុកទឹក និងជីកប្រឡាយទឹកអង្គភាពជាច្រើនបានបញ្ចប់ផែនការរបស់ខ្លួន ហើយពាក់ព័ន្ធទៅនឹងកុមារលោក ខៀវ សំផន ក៏បានលើកឡើងថា ក្មេងៗរបស់យើងសប្បាយនឹងការដេញចាប ជួយកសាងទំនប់ នឹងខឿនទំនប់ការពារទឹក ជីកអាងស្តុកទឹក និងជីកប្រឡាយ។ សប្បាយ តើពួកគាត់ជាការពិតសប្បាយនឹងអ្វីៗដែលបានលើកដោយលោក ខៀវ សំផន ដែរឬទេ? តើវាជាការពិតទេ អ្វីដែលគាត់បានលើកនេះ? ស្ថានភាពជាក់ស្តែង គឺមិនដូចអ្វីដែលបាននិយាយនោះទេ។

[០៩:២៤:១៨]

ការលើកនេះ គ្រាន់តែជាការបំបិទបាំងការពិតតែប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពីទុក្ខវេទនាដ៏ធំធេង ដែលពួកគាត់បានទទួលរងពីរបបគ្រប់គ្រងនាសម័យនោះ ដែលត្រូវបានចាត់ទុកពួកគាត់ថាជាទាសករ និងបង្ខំឱ្យធ្វើការដ៏ធ្ងន់ធ្ងរនៅតាមការដ្ឋានសាងសង់នានា។ សហករណ៍ និងការដ្ឋានត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសកម្ពុជា តាំងពីមុនឆ្នាំ១៩៧៥ គឺចាប់ពីដំណាក់កាលដំបូងនៃការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើផ្នែកខ្លះៗនៃទឹកដីមកម្ល៉េះ។ សហករណ៍ និង ការដ្ឋានទាំងនោះ បន្តដំណើរការយ៉ាងហោចណាស់រហូតទៅដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ អង្គជំនុំជម្រះសាលាដំបូង បានទទួលការប្តឹងឱ្យពិនិត្យពាក់ព័ន្ធនឹងការដ្ឋានចំនួនបី និងសហករណ៍ចំនួនមួយ គឺការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់១មករា និង សហករណ៍ត្រាំកក់។ ដីកាដំណោះស្រាយដែលបញ្ជូនរឿងមកអង្គជំនុំជម្រះសាលាដំបូង បានលើកឡើងថា គោលដៅមួយក្នុងចំណោមគោលដៅទាំងឡាយក្នុងការបង្កើតសហករណ៍ និងការដ្ឋាន គឺដើម្បីដាក់ប្រជាជនឱ្យធ្វើការផលិតស្បៀងអាហារសម្រាប់ការប្រើប្រាស់ផ្ទៃក្នុង និងការនាំចេញ។

**ប្រធានអង្គជំនុំ៖**

សូមផ្អាកបន្តិចលោក--

សូមអញ្ជើញលោកវ៉ិចទ័រ កូប៉េ!

[០៩:២៦:០៩]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំសូមទោស<ចំពោះការរំខាន> ប៉ុន្តែកូនក្តីខ្ញុំសុំអនុញ្ញាតចុះទៅក្រោមដើម្បីសម្រាក។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយអង្គជំនុំជម្រះ សូមជម្រាបជូនភាគី និងសាធារណជនថា តាមកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក នេះ ធ្វើការពីព្រឹកមិញ បានកត់សម្គាល់ពីបញ្ហាសុខភាពរបស់គាត់ថា គាត់មានអាការៈឈឺចង្កេះជាប្រចាំហើយ ក្នុងករណីអង្គុយយូរ គឺគាត់ធ្វើឱ្យកាន់តែពិបាកទ្រាំ។

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយតាមសំណើសុំណ៎ះ! ដោយមានមូលហេតុអ៊ីចឹង ហើយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា ទៅកាន់បន្ទប់ខាងក្រោមសាលសវនាការនេះ ដើម្បីឱ្យគាត់តាមដានតាមរយៈប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

ហើយបង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតក្រោមសាលសវនា-ការនេះក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ លោកមេធាវី អាចបន្តទៀតបាន។

[០៩:២៧:៣០]

**លោក ពេជ អង្គ៖**

ក្នុងចំណោមសកម្មភាពផ្សេងៗទៀត ចំណុចទាំងនេះ ពាក់ព័ន្ធផងដែរជាមួយនឹងការបង្កើនផលិតផលស្រូវយ៉ាងឆាប់រហ័ស ៣តោនក្នុង ១ហិកតា។ ការបង្កើតឱ្យមានប្រព័ន្ធស្រោចស្រពទឹក

បញ្ចូលស្រែទូទាំងផ្ទៃប្រទេស ឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ព្រលានយន្តហោះកំពង់ឆ្នាំង ទំនប់ទឹក។ មានការចោទប្រកាន់ថា គោលដៅមួយទៀតនៃការបង្កើតសហករណ៍ និង ការដ្ឋាន គឺដើម្បីអនុវត្តគោលនយោបាយពាក់ព័ន្ធទៅនឹងការស្រាវជ្រាវរកខ្មាំង ការពារទប់ទល់នឹងខ្មាំង អប់រំខ្មាំង និងកម្ទេចខ្មាំង ឬដើម្បីលុបបំបាត់របបឯកជន ដោយបំផ្លាញរចនាសម្ព័ន្ធពីមុន ហើយជំនួសមកវិញដោយរបបសមូហភាព ដែលនៅក្នុងនោះលែងមានកម្មសិទ្ធិឯកជន និងកម្មសិទ្ធិគ្រួសារទៀតហើយ។

ជាដំបូង អង្គជំនុំជម្រះនឹងសម្រេចថា តើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានកើតឡើងនៅតាមសហករណ៍ និងការដ្ឋានទាំងនោះឬយ៉ាងណា? បន្ទាប់មក ថាតើជនជាប់ចោទអាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ឬយ៉ាងណា។ គោលបំណងនៃការបង្ហាញថ្ងៃនេះ គឺដើម្បីបង្ហាញថា តើដើមបណ្ដឹងរដ្ឋប្បវេណីអាចជួយដល់អង្គជជំនុំជម្រះ ដោយរបៀបណាក្នុងការកំណត់ធាតុផ្សំ សម្ភារៈ នៃបទឧក្រិដ្ឋនានាដែលជនជាប់ចោទ ត្រូវបានចោទប្រកាន់ ដូចជា ការធ្វើឲ្យក្លាយជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ ដូច្នេះ ខ្ញុំនឹងបង្ហាញជូនភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងការដ្ឋានការងារ ដូចតទៅ ដែលដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១០០នាក់ -- ១០១នាក់ ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងបរិបទនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅទំនប់ត្រពាំងថ្ម។

[០៩:៣០:០០]

ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបួននាក់ក្នុងចំណោមនោះមានឈ្មោះថា សម ស័ក្ត, មាន លឿយ, ញ៉ឹប ផល, សែន សុផុន ដែលបានផ្ដល់សក្ខីកម្មអំពីឧក្រិដ្ឋកម្មនៃការធ្វើឲ្យក្លាយទៅជាទាសករ អំពើមនុស្សឃាត និងការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយមកលើប្រជាជនថ្មីនៅការដ្ឋាន។

ចំពោះទំនប់១មករាវិញ មានដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៤៧រូប ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងបរិបទនៃឧក្រិដ្ឋកម្មបាន -- ដែលបានប្រព្រឹត្តិនៅទីនោះ។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំរូបក្នុងចំណោមនោះមានឈ្មោះថា ហ៊ុន សុត្ថានី, អ៊ុន វ៉ន, សៀង សុវិដា, នួន ណារុំ និង ចៅ ឡាង ដែលពួកគាត់បានផ្ដល់សក្ខីកម្មអំពីការធ្វើឲ្យក្លាយទៅជាទាសករ អំពើអមនុស្សធម៌ផ្សេងៗ អំពើមនុស្សឃាត និងការសម្លាប់រង្គាល ព្រមទាំងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនថ្មី។

[០៩:៣១:១៧]

ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១១នាក់ ត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងបរិបទនៃការប្រព្រឹត្តឧក្រិដ្ឋកម្មនៅព្រលានយន្តហោះកំពង់ឆ្នាំង។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបីនាក់ក្នុងចំណោមនោះមានឈ្មោះថា គង់ សៀក, ជុំ សាមឿន និង ឆែ ប៉ាប ដែលបានផ្ដល់សក្ខីកម្មផ្ទាល់មាត់ក្នុងអំឡុងវគ្គសវនាការស្ដីពីព្រលានយន្តហោះកំពង់ឆ្នាំង។

ចំពោះឧក្រិដ្ឋកម្មស្ដីពីការធ្វើឲ្យក្លាយទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នាអំពីស្ថានភាពដែលពួកគាត់បានទទួលរង ដូចជា ការធ្វើការហួសកម្លាំងដើម្បីបង្គ្រប់តាមផែនការ ស្ថានភាពរស់នៅលំបាកលំបិន អាហាររូបត្ថម្ភមិនគ្រប់ និងកង្វះការថែទាំសុខភាពនិងអនាម័យ។

សក្ខីកម្មរបស់ពួកគេពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៃការធ្វើឲ្យក្លាយទៅជាទាសករ អំពើមនុស្សធម៌ - - អមនុស្សធម៌ផ្សេងទៀត អំពើមនុស្សឃាត និងការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយមកលើប្រជាជនថ្មី។ សក្ខីកម្មពួកគាត់គ្របដណ្ដប់ទៅលើការងាររបស់ខ្លួននៅតាមអង្គភាពនានា ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយជាក់លាក់ ព្រមទាំងព្យសនកម្ម និងការឈឺចាប់ ដែលពួកគាត់ទទួលរង។

ទីតាំងនីមួយៗមានលក្ខណៈខុសគ្នា។ នៅទំនប់ត្រពាំងថ្ម ដើមបណ្ដឹងរដ្ឋប្បវេណីពិពណ៌នាអំពីការបញ្ជូលពួកគាត់ទៅក្នុងកងរយ និងការគ្រប់គ្រងទៅលើពួកគាត់។

នៅទំនប់១មករា ដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នាយ៉ាងលម្អិតអំពីស្ថានភាពរស់នៅ និងកង្វះអនាមយនៅការដ្ឋានដែលគ្របដណ្ដប់ទៅលើតំបន់ចំនួនបី។ នៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នាអំពីការងារពលកម្មយ៉ាងលំបាកលំបិន និងធ្វើការសុទ្ធតែទៅតាមគេបញ្ជា។

[០៩:៣៣:២២]

ខ្ញុំសូមអនុញ្ញាតលើកពាក់ព័ន្ធទៅនឹងករណីការដ្ឋានទំនប់ត្រពាំងថ្មដោយជាក់លាក់។ អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវសម្រេចថា តើវិធីសាស្ត្រដែលបក្សកុម្មុយនីស្តកម្ពុជារៀបចំការរស់នៅ និងការងារនៅត្រពាំងថ្ម ជាការធ្វើឲ្យក្លាយទៅជាទាសករ ឬយ៉ាងណា? ដើម្បីបន្តកាតព្វកិច្ចនេះ អង្គជំនុំជម្រះសាលាដំបូងនឹងកំណត់អំពីវត្តមាន និងកម្រិតនៃការគ្រប់គ្រង ដែលបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តលើ

ប្រជាជន ដែលធ្វើការនៅទំនប់ ដូចជា ការគ្រប់គ្រងផ្លូវចិត្ត ការគ្រប់គ្រងការនិយាយស្តី ជីវិតគ្រួសារ បញ្ហាផ្លូវភេទ ការគ្រប់តាមរយៈការបំភិតបំភ័យ ការប្រើប្រាស់ ការប្រើការប្រជុំអប់រំតាមរយៈតួនាទីត្រួតត្រារបស់ប្រជាជនមូលដ្ឋាន ឬតាមរយៈការដាក់ទណ្ឌកម្ម។

យើងជឿជាក់ថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងនៅពេលសវនាការនឹងធ្វើការ -- នឹងធ្វើសេចក្តីសង្ខេបនៅថ្ងៃនេះ និងជួយអង្គជំនុំជម្រះសាលាដំបូងក្នុងការធ្វើកិច្ចការនេះ។

ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ជាប្រជាជនថ្មី និងមានវ័យជំទង់ ដែលបានចូលរួមក្នុងកងចល័ត ដែលមានសមាជិក៧០នាក់នៅការដ្ឋានទំនប់ត្រពាំងថ្មនាខេត្តបាត់ដំបងពេលនោះ ហើយពេលនេះគឺខេត្តបន្ទាយមានជ័យ នៅឆ្នាំ១៩៧៧ រហូតមកដល់របបនោះបានដួលរលំ បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍ជាទូទៅនៅទំនប់ត្រពាំងថ្ម ដែលត្រូវបានចាត់ទុកថាជាសមរភូមិក្តៅ។

ខ្ញុំសូមបញ្ចាំងវីដេអូទី១ របស់លោក សម ស័ក្ត។

[០៩:៣៥:៣៣]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"បាទ អរគុណលោកមេធាវី។ ខ្ញុំបើនិយាយពីរឿងផលប្រយោជន៍ និងកម្លាំង ជំនាន់នោះ ខ្ញុំដូចជាសត្វមួយក្បាលទៅចុះ ថាចាត់ទុកជាសត្វមួយក្បាលទៅចុះ។ គេប្រើអីធ្វើហ្នឹង ប្រើអីធ្វើហ្នឹង។ ចំពោះផលប្រយោជន៍ដែលថាទំនប់នោះសម្រេចលទ្ធផល ឬយ៉ាងណានោះ ខ្ញុំអត់ដឹងផែនការរបស់អង្គការ ខ្ញុំអត់ដឹង។ ខ្ញុំអត់បានដឹង។ ប៉ុន្តែខ្ញុំនេះ ដូចជាសត្វមួយក្បាលដែលគេសម្រាប់ប្រើ។ មិនដឹងជាថ្ងៃណាស្លាប់ មិនដឹងថ្ងៃណារស់ ព្រោះជំនាន់នោះអត់ដឹងទេ អត់ដឹងខ្លួនឯងថ្ងៃស្លាប់ ថ្ងៃណា។ ដឹង ដឹងអានេះរស់ ស្អែកមិនដឹងយ៉ាងម៉េចទេ អត់ដឹង យើងអត់ដឹងមុន។ ជំនាន់នោះយើងអត់ដឹងទេ។ ការស្លាប់ អត់ដឹងមុនទេ។ ដឹងថ្ងៃហ្នឹងរស់ ឬមួយល្ងាចស្លាប់ ក៏យើងមើលមិនដឹង។ អត់ដឹងថា គេតម្រូវការយើងធ្វើរម៉ានយើងក៏មិនដឹង។ ប៉ុន្តែទំនប់អាងត្រពាំងថ្មហ្នឹង ខ្ញុំក៏មិនដឹងថាគោលបំណងគេធ្វើហ្នឹង ដើម្បីអី ក៏ខ្ញុំមិនដឹង ព្រោះខ្ញុំនៅក្មេង ហើយយើងមិនចាប់អារម្មណ៍ថា គេធ្វើដើម្បីធ្វើអី យើង -- គេធ្វើនេះ ដើម្បីធ្វើអី យើងក៏មិនដឹងដែរ អត់ដឹងៗ។ ដឹងតែថា ធ្វើស្រែប្រាំងអ៊ីចឹងទៅ ដឹងតែប៉ុណ្ណឹង។ រឿងស្រែប្រាំង ដឹង អារឿងហ្នឹង។ អារឿងផលប្រយោជន៍ទៅមុខទៀត ខ្ញុំអត់ដឹង"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៣៧:១០]

ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ជាប្រជាជនមូលដ្ឋានដែលធ្វើការនៅទំនប់ត្រពាំងថ្ម នៅចុងឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៧ និងជាសមាជិកកងរយ បានផ្តល់សក្ខីកម្មថា ការប្រជុំទិតៀន និងស្វ័យទិតៀន ដែលត្រូវបានយកមកប្រើ ដើម្បីបង្កការភ័យខ្លាចក្នុងចំណោមអ្នកធ្វើការនៅមូលដ្ឋានទំនប់ត្រពាំងថ្ម។ ចំពោះទិតៀន ស្វ័យទិតៀន ខ្ញុំសុំស្រង់៖ “ចំពោះទិតៀន ស្វ័យទិតៀនហ្នឹង គឺមេកងគេអ្នកហៅយើងទៅ។ ឧទាហរណ៍ថា ក្រុម១០នាក់ ត្រូវខុស -- ទទួលខុសត្រូវក្នុងថ្ងៃនេះ គឺលើកមិនរួច នឹងត្រូវខុស។ បាទ គេហៅទៅប្រជុំ គេលើកទិតៀនអំពីយើង អំពីយើងមិនប្រឹងប្រែង យើងមិនធ្វើពលកម្មចង់ជិះជាន់ពលកម្មគេ យើងអត់មានម្ចាស់ការលើការងារ។ អ៊ីចឹងទៅ មិត្តឯងត្រូវតែខំប្រឹង បើមិនប្រឹងធ្វើអ៊ែលៗ ប្រយ័ត្នអង្គការថាហើយ ថាទុកក៏មិនចំណេញ ដកចេញក៏មិនខាត។ ដូច្នេះពាក្យទាំងអស់នេះគឺដូចរូបខ្ញុំបាទផ្ទាល់ តែឮហើយដឹងតែពីខ្លាចហើយបាទ។”

[០៩:៣៨:៣៩]

ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ ជាប្រជាជនថ្មី និងជាសមាជិកកងរយយុវជនពីខែមិថុនា ឆ្នាំ១៩៧៧ រយៈពេលប្រាំមួយខែ បានផ្តល់សក្ខីកម្មថា គាត់បានបំពេញការងារដោយសារការភ័យខ្លាច។ ខ្ញុំសុំដកស្រង់៖ “ការខ្លាចនេះ ខ្លាចគេយកទៅសម្លាប់ចោលតែម្តង។ ខ្លាចវិន័យរបស់ទិស របស់អង្គការ។” ដើមបណ្តឹងរដ្ឋប្បវេណី -- សុំបិទសម្រង់។ ដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នាអំពីរបៀបដែលគាត់បានឮថា “តាមអង្គការគេថា កង់ប្រវត្តិសាស្ត្រ ដូចថាយើងវិលមិនទាន់គេ គេប្រជុំហ្នឹង គេចេះតែអប់រំអំពីការគោរពវិន័យអង្គការចាត់តាំងប្តេជ្ញាចិត្តខ្លាចតាមគេនិយាយ បាទ”។ ហើយខ្ញុំសុំដកស្រង់ជាបន្ត៖ “ធ្វើនោះគឺធ្វើទាំងខ្លាចស្លាប់តែម្តង ធ្វើទាំងកម្លាំងចិត្ត។ បើកម្លាំងកាយ អត់មានទេ គឺកម្លាំងខ្លាចស្លាប់តែម្តង។ បើហ៊ានតវ៉ាជាមួយអង្គការ ធ្វើដោយ -- ទេ ធ្វើដោយកម្លាំងចិត្ត ធ្វើដោយចិត្តខ្លាច គឺត្រូវតែធ្វើបាទ។” សុំបិទសម្រង់។

[០៩:៣៩:៥៨]

ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក ដែលជាសមាជិកក្មេងជាងគេក្នុងកងរបស់គាត់បានពិពណ៌នាអំពីការកំណត់ផែនការការងារ និងការដែលអ្នកធ្វើការនឹងត្រូវគេដកហូតរបបអាហារ ប្រសិនបើមិនសម្រេចតាមផែនការ។ សូមស្រង់៖ “ការងារកងចល័ត គឺថាយើងគ្មានថាតូច គ្មានថាធំទេ។ ការងារបែងចែកស្មើគ្នាៗ។ បើយើងធ្វើឲ្យគេមិនគ្រប់ទេ គេនឹងកាត់របបយើង។ ក្នុងក្រុមនោះ គេកាត់របបយើង។ ទោះបីមួយចុងស្លាបព្រាក៏ដោយ មួយស្លាបព្រាក៏ដោយ ក៏គេកាត់ពីយើងទៅឲ្យអ្នកធ្វើការ

ហើយនោះ គេនឹងទៅឲ្យអ្នកដែលធ្វើការនៅ -- អំ! ធ្វើការជាមួយគ្នាយើងនោះ ដាក់ឲ្យគាត់បន្តិចៗទៅឲ្យម៉េចឲ្យដាច់ពាក់កណ្តាលរបបយើង។ ហើយពេលនោះ ខ្ញុំមកអង្គុយហើយ យំ។ ចុះខ្ញុំនៅតូចជាងគេ ខ្ញុំអង្គុយយំ យំ។ តូចចិត្តខ្លួនឯងធ្វើអត់ហើយ ក៏ប៉ុន្តែយូរៗទៅ ខ្ញុំធ្វើដូចគេដូចឯងអ៊ីចឹង ដូចគេដូចឯង។ អ្នកឯងធ្វើបានប៉ុន្មាន ខ្ញុំធ្វើបានប៉ុណ្ណឹង ដូចគ្នា ធ្វើបានដូចគ្នា។" បិទសម្រង់។

[០៩:៤១:១៧]

ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានផ្តល់សក្ខីកម្មអំពីការប្រព្រឹត្តសាហាវយង់ឃ្នងមកលើប្រជាជននៅការដ្ឋាន។ ដើមបណ្តឹងរដ្ឋប្បវេណីជាប្រជាជនថ្មី និងជាសមាជិកកងចល័តដែលមានសមាជិក៧០នាក់ រយៈពេលពីខែ -- នៅឆ្នាំ១៩៧៧ ហើយបានពន្យល់ថា "អ្នកដែលជម្លៀសចេញពីក្រុងភ្នំពេញមកនៅព្រះនេត្រព្រះនេះ អ្នកដែលនៅព្រះនេត្រព្រះ គេហៅថា ប្រជាជនចាស់។ អ្នកដែលបានជម្លៀសចេញមក គេហៅ ប្រជាជនថ្មី។ ប្រជាជនថ្មី គ្រាន់តែនិយាយទៅ គេដឹង ព្រោះអីប្រជាជនថ្មីអ្នកនោះ និយាយភាសាកណ្តាល។ បើអ្នកខាងនោះ គេនិយាយភាសារដឺនៗ"។ បិទសម្រង់។

ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានពន្យល់ថា "ប្រធានសហករណ៍ទុកជាប្រជាជនថ្មី ថាពួកខ្ញុំនេះ ទៅដល់គឺជាថ្មីហើយ។ ពួកខ្ញុំនេះហូបតែបបរទេ ហើយពួកគេហូបបាយ។" បិទសម្រង់។ គាត់បានពន្យល់ទៀតថា សូមស្រង់៖ "មាន អាហ្នឹងពួកខាងមូលដ្ឋាននោះ គេអត់សូវធ្វើការងារទេ គេសម្រាប់តែអ្នកប្រើពួក១៧មេសាហ្នឹងឯង។" បិទសម្រង់។

ដើមបណ្តឹងរដ្ឋប្បវេណីក៏បានពិពណ៌នាអំពីព្យសនកម្មដែលពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់ពួកគាត់នៅត្រពាំងថ្ម។ ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានពិពណ៌នាអំពីរបៀបដែលគាត់ស្រមៃអំពីអាហារចុងក្រោយរបស់គាត់នៅការដ្ឋានទំនប់ត្រពាំងថ្ម។ សូមបើកសម្រង់៖ "ខ្ញុំនៅកងចល័តធ្វើការធ្ងន់ហូបមិនគ្រប់គ្រាន់ ដេកមិនពេញភ្នែក គឺថាខ្ញុំ ក្នុងចិត្តខ្ញុំនេះ រកអ្វីមកប្រៀបធៀបមិនបាន គឺថាឃ្លានខ្លាំងពេក និយាយជំនុំគ្នាថា ឲ្យតែបានបាយខ្ញុំហូបឲ្យឆ្អែត មាន់ស្ងោរខ្ញុំមួយចាន ដូចពីសង្គមហ្នឹង យកខ្ញុំទៅសម្លាប់ចុះ ខ្ញុំមិនស្តាយជីវិតខ្ញុំទេ ឲ្យតែបានឆ្អែតមួយពេលបានហើយ។ ជំនុំគ្នាអ៊ីចឹង។ អំ! អ្នកខ្លះ គេថាអញបានគុយទាវមួយចាន ទឹកកកមួយកែវ គេយកទៅសម្លាប់ ក៏មិនស្តាយដូចគ្នាដែរ។" បិទសម្រង់។

[០៩:៤៣:៥៦]

ពេលនេះ ខ្ញុំសូមចូលទៅដល់សេចក្តីសន្និដ្ឋានពាក់ព័ន្ធទៅនឹងទំនប់១មករា។ ដើមបណ្តឹងរដ្ឋប្បវេ-ណីចំនួន៥នាក់ គឺ ហ៊ុន សុគ្គានី, អ៊ុំ រ៉ន, សៀង សុវិដា, នួន ណារុំ និង ចៅ ឡាង បានផ្តល់សក្ខីកម្មនៅ

ចំពោះមុខអង្គជំនុំជម្រះអំពីបទពិសោធន៍របស់គាត់ដែលបានរស់នៅ និងធ្វើការនៅទំនប់១មករា ស្ទឹងជីនិត នាខេត្តកំពង់ធំ។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗដែលបានផ្តល់សក្ខីកម្ម គឺជាស្ត្រី ហើយម្នាក់ៗ ជាប្រជាជនថ្មី ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សុគ្គានី ធ្វើការនៅកងចល័តជាមួយអ្នកធ្វើការចំនួន៨០រូប ផ្សេងទៀត នៅក្នុងការដ្ឋានទំនប់១មករា ពីខែធ្នូ ឆ្នាំ១៩៧៦ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៧។ គាត់បានផ្តល់សក្ខីកម្មថា គាត់ពុំមានជម្រើសណាផ្សេង ក្រៅពីបំពេញការងារដែលបានកំណត់។ ជាពិសេសដោយសារគាត់ជាប្រជាជនថ្មីផង។ ខ្ញុំសូមស្រង់៖ "គឺមិនអាចមានជម្រើសទេ។ ពាក្យថា "ចាត់តាំង" មួយម៉ាត់ហ្នឹងគឺខ្លាំងក្លាហើយ។ គេអ្នកស្រុកចាស់គេហ៊ានតវ៉ា ចំណែកខ្ញុំអ្នកស្រុកថ្មីហ្នឹង អ្នកថ្មីហ្នឹងគឺគ្មានទេ គឺគ្មានតែម្តង។ តែតម្រូវឲ្យទៅ គឺទៅដោយមិនប្រកែក។ ហើយយើងគ្មានសិទ្ធិនោះទេ គ្មានសិទ្ធិអីទេ គ្មានសូន្យតែម្តង ពិបាកចិត្តហ្នឹងបានត្រឹមត្រូវយំហ្នឹង បានត្រឹមតែគ្រាំគ្រាក្នុងខ្លួន តឹងទ្រូងប៉ុនណាដែលតវ៉ាមិនបាន និយាយមិនកើត អស់លោកដឹងហើយពិបាកប៉ុនណាក្នុងទ្រូង ក្នុងខ្លួនវាប៉ុន្មានទៅ។" បិទសម្រង់។

ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា ដែលមានអាយុ១១ ឬ១២ឆ្នាំ នៅពេលដែលគាត់ត្រូវបានបញ្ជូនទៅការដ្ឋានទំនប់១មករា រយៈពេលបីខែ បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍ក្នុងនាមជាប្រជាជនថ្មី ធ្វើការដូចគ្នា ក៏ប៉ុន្តែគ្មានសិទ្ធិទេ ដូចអ្នកទោសអ៊ីចឹង ដូចជាសត្រូវ។ ហើយពួកប្រជាជនមូលដ្ឋានហ្នឹង គេលើកអ្នកដែលជាជនក្រីក្រ ឬអ្នក ឬក៏មានអ្នកថែកជាពីរហ្នឹងមកកាន់អំណាច គឺធ្វើបាបពួកខ្ញុំ។ អ្នកថ្នាក់លើគាត់មិនស្គាល់មុខពួកខ្ញុំ តែពួកក្រោមនេះធ្វើបាបពួក១៧មេសា ចាំតែបន្តិចទៀត ពួក១៧ មេសាស្លាប់ទាំងអស់។ ហើយហាក់ដូចជាគ្នាសត្រូវអ៊ីចឹង ដូចទុកពួកខ្ញុំហ្នឹងជាសត្រូវស្ពួជជាមួយនឹងពួកគាត់ ធ្វើអីក៏ខុសៗ។" បិទសម្រង់។

ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ជាប្រជាជនដែលបានធ្វើការនៅទំនប់១មករា ចំនួនពីរដង ក្នុងនាមជាសមាជិកកងចល័ត បានពិពណ៌នាអំពីកម្រិតនៃការធ្វើ នៃការគ្រប់គ្រងអ្នកធ្វើការ។ សូមស្រង់៖ "បានៗ សិទ្ធិសេរីភាពមកពីណា និងទទួលខុសត្រូវខ្លួនឯង ចុះបើថ្នាំនៅលើគេ ឆ្នាំងបាយនៅលើគេ ចាននៅលើគេ បានអ្វីមកទទួលខុសត្រូវខ្លួនឯង វាគ្មាន។" បិទសម្រង់។

[០៩:៤៧:២២]

ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សុគ្គានី បានពិពណ៌នាអំពីរបៀបដែលគាត់មិនហ៊ានទាំងយំផង។

នៅពេលដែលឪពុកគាត់ស្លាប់ និងការបំបែក និងពេលដែលគាត់ត្រូវបានបំបែកចេញពីគ្រួសារ។ សូមស្រង់៖ “នៅពេលនោះធ្វើម៉េចក៏យំមិនចេញ យំអត់ចេញសោះ។ ខ្ញុំស្រែកយំបាននៅពេលដែលមានភ្លៀងធ្លាក់ធំទេ ដែលខ្ញុំស្រែកយំ គឺខ្ញុំយំឱ្យអស់ពីក្នុងខ្លួន ខ្ញុំយំមួយទំហឹងហើយ ព្រោះខ្ញុំគ្មានពេល គ្មានសិទ្ធិយំទេ ទាល់តែភ្លៀងធំ ផ្គរលាន់ក្នុងៗ បានខ្ញុំស្រែកហើយ។ ពេលណាក៏ខ្ញុំស្រែកយំដែរ ឲ្យតែភ្លៀង ខ្ញុំនឹកឃើញរឿងទាំងអស់ នៅមុខគេខ្ញុំគ្មានសិទ្ធិទេ កុំឱ្យគេថាខ្ញុំហ្នឹងសតិអារម្មណ៍ គិតអី។ អ៊ីចឹងខ្ញុំត្រូវតែទ្រាំក្នុងខ្លួន។ ទ្រាំហ្នឹងពិបាកណាស់ ទ្រាំហ្នឹងពិបាកមែនទែន សឹងតែរហែកទ្រូងងាប់ភ្លាមៗហើយ ចុកអស់ហើយក្នុងខ្លួន។ នេះគឺការអត់ធ្មត់។ ដល់ពេលភ្លៀងខ្លាំងហើយ យើងក៏បានស្រែកយំនឹកប៉ា នឹកម៉ាក់ នឹកបងប្អូនដែលបែកគ្នា និងបានយើងមានសិទ្ធិយំៗ កុំឱ្យគេឮ។” បិទសម្រង់។

[០៩:៤៨:៤០]

ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានផ្ដល់សក្ខីកម្ម អំពីការដែលអ្នកធ្វើការទទួលការព្រមានមិនឱ្យនិយាយគ្នា សូម្បីតែជាមួយបងប្អូនក៏ដោយ។ សុំដកសម្រង់៖ “សូម្បីតែបងប្អូនបង្កើតនឹងគ្នា ក៏មិនអាចឈរនិយាយគ្នាបានដែរ។ តែគេឃើញគឺគេប្រាប់ថា គេចាប់អ៊ីចឹងតែម្ដង គេមិនឱ្យទេ ពេលម៉ោងធ្វើការហ្នឹង។ ព្រោះយោធានៅយាមកៀកៗកន្លែងយើងចាក់ដីហ្នឹង។ បានជាខ្ញុំដឹងប្រាកដ ព្រោះយោធាចាប់ពីរនាក់បងប្អូនហ្នឹង។ ចាប់លើកទី១ គេថាគ្រាន់តែព្រមានទេ មកដល់គេចាប់ដៃពីរនាក់ហ្នឹងកុំឱ្យឈរនិយាយគ្នា។ មិត្តឯងមានការអី? ប្រាប់ថាខ្ញុំបងប្អូនបង្កើត។ បងប្អូនបង្កើតក៏ដោយ ចុះទៅឱ្យឆាប់ ចុះទៅក្រោម ចុះទៅរែកដី តែមានលើកទី២ អត់បានទេណ៎ា! ខ្ញុំរែកដីដើរកាត់តាមហ្នឹង គ្រាន់តែឮញ៉ាក់សាច់អស់ទៅហើយ ចិត្តអាក្រក់ម្ល៉េះ។ គ្រាន់តែបងប្អូនបង្កើតជួបនិយាយគ្នាក៏មិនបាន អារម្មណ៍ចេះតែគិតថាទៅថ្ងៃមុខមិនដឹងជាយ៉ាងម៉េចទេ តឹងឡើងៗយ៉ាងនេះ។” បិទសម្រង់។ គេអាចប្រើការគ្រប់គ្រងផងដែរ តាមរយៈការប្រជុំអប់រំ។ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា បានពិពណ៌នាអំពីភាពញឹកញាប់នៃការប្រជុំ ដែលបានធ្វើនៅការដ្ឋាន និងបានពន្យល់តាមសម្ដីរបស់គាត់នៅក្នុងកិច្ចប្រជុំតូចៗដោយមាននៅក្នុងវីដេអូដូចតទៅ។ សូមបញ្ចាំងវីឌីអូលេខ២ (សៀង សុវិដា)។

[០៩:៥០:៤៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[ប្រជុំតូចៗហ្នឹង គឺនិយាយពីការងារ ជំរុញការងារធ្វើឱ្យលឿនជាងគេ ឱ្យស្រុកយើងហ្នឹងបានលឿនជាងគេ ឆាប់ហើយជាងគេ ស្រុកគេណាគេសម្រាក ឬក៏គេធ្វើម៉េច ធ្វើយូរ ឱ្យយើងឱ្យបានលឿន*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*ចង់ដូចថា ឲ្យយើង -- ស្រុកយើងឈានមុខគេអ៊ីចឹង។ ហើយមួយទៀត គេ -- ខ្ញុំសូមនិយាយពីរឿងការភាសានៅរបបនោះ ភាសាខ្មែរក្រហម ទ្រឹស្តីរបស់គាត់។ គាត់ចូលចិត្តថា "ស្វ័យទិតៀន១" ហ្នឹង គឺឲ្យមើលគ្នាទៅវិញទៅមក ដើម្បីកែលម្អ តាមពិតគឺចាំចាប់កំហុស។ ហើយចូលចិត្តប្រើពាក្យ "ភ្នែកម្ចាស់អង្គការភ្នែកម្នាស់" ហើយកង់ប្រវត្តិសាស្ត្រហ្នឹង គឺវិល។ វិល បើយើងនេះមិនទាន់ ប៉ះដៃ គឺដៃ ប៉ះជើង គឺជើង។ ហើយចូលចិត្តនិយាយពាក្យ បើស្រែកជយឃោស "ជយោ! មហាលោតផ្លោះ មហាអស្ចារ្យ"។ ហើយឲ្យយើងធ្វើការហ្នឹងទៅ ក្បាលអ្នកណា សក់អ្នកហ្នឹងហើយណ៎ា! កុំនឹកម៉ែឪ នៅឯណោះផ្សេងអីផ្សេងអ៊ីចឹង។ ហើយខ្ញុំមិនយល់ដែរ។ ហើយ"ទុកមិនចំណេញ ដកចេញមិនខាត" ឥឡូវហ្នឹង យើងត្រូវតែប្រឹង យើងត្រូវតែអ៊ីចឹង ហើយលើកឲ្យរាប់ហើយអ៊ីចឹង។ ហើយបើប្រជុំពីរឿងនេះទៀត ឲ្យយើងប្រឹងធ្វើស្រែ ក្នុង១ហិកតា ឲ្យបាន៣តោន។ គឺនិយាយតែពីរឿងធ្វើការ ឬរឿងលោតផ្លោះមហាអស្ចារ្យហ្នឹងជំរុញពីការងាររហូត។ ហើយអ្នកឈឺ--]*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៥២:២៧]

អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវសម្រេចថា តើស្ថានភាពរស់នៅ និងការធ្វើការយ៉ាងលំបាកលំបិន រួមជាមួយនឹងកង្វះអាហារ និងសម្ភារៈប្រើប្រាស់រស់នៅ នៅទំនប់១មករា គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬយ៉ាងណា។ ភស្តុតាងដែលបានស្តាប់ នៅពេលជំនុំជម្រះពាក់ព័ន្ធទៅនឹងទំនប់១មករា បានបង្ហាញថា តើស្ថានភាពរស់នៅលំបាកលំបិន ជាពិសេសពាក់ព័ន្ធទៅនឹងស្ត្រីដោយរបៀបណា។ ដូច្នេះជាបន្ទាប់ ខ្ញុំសូមអនុញ្ញាតបញ្ចាំងវីដេអូបន្ទាប់ វីដេអូលេខ៣ របស់លោកស្រី អ៊ុន រ៉ន នៅទំនប់១មករា។ សូមបញ្ចាំង។

[០៩:៥៣:២៦]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខោអាវផ្លាប់រាល់ថ្ងៃ ស្លៀកទៅជួនកាលឈឺពោះ ១រហូតដល់ចេញៗរមាស់ណ៎ា ចេញរមាស់អេះឡើងកើតចៃ ចេញចៃតាមសាច់ អេះមកកើតចៃ ពកៗអេះ ក្បាលរមាស់ គ្មានស្គាល់ជាតិសាប៊ូ គ្មានស្គាល់ជាតិអ្វីទាំងអស់ មួយចប់ខ្មែរក្រហម។ រហូតដល់យកផេះត្រាំទឹក យកទឹកថ្លាៗមកបោកខោអាវម្តងទៅ ក្រមរឡើងក្លាំងកអាវ បែកញើស សើមបែកញើស សើម រាល់ថ្ងៃ។ ប៉ុននិយាយទៅ និយាយឲ្យអស់ ធម្មតាងមនុស្សស្រីគេតែងតែមានរដូវណ៎ា ហូរឈាមដូចអាវ-កមាន់ណ៎ាមក តស៊ូទ្រាំ ខ្លាចគេ*

*យកទៅវៃចោល។ ខោខ្លីក៏មិនដែលបើកឲ្យ អាវតូចក៏មិនដែលមានឲ្យ។ គេមិនដឹង បើថាចំពោះខ្ញុំនៅ មិត្តនៅជាមួយគ្នាជាមួយខ្ញុំដែលរែកដីជាមួយគ្នា ហែកកន្ទ្រែងចែកគ្នាម្នាងម្នាក់ ចងក្បិនស្លៀកខោពីក្រៅ ដល់ពេលភ្លៀងមកស្រាយអាក្បិននេះបោកដាក់ហាលចុងកូនឈើទៅ ខោទទេឲ្យវាត្រូវទឹកភ្លៀងទៅ វាហូរទៅ ក្រហមត្រាក់ទ្រើងពេញអារណ្តៅជីកដី បាត់អៀន បាត់ខ្មាសអស់ហើយមួយជំនាន់នោះឯង។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[០៩:៥៥:០០]

ទាំងនេះ គឺជាទុក្ខវេទនា និងការលំបាករបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតមាននៅការដ្ឋាន ១មករា នាខេត្តកំពង់ធំ។

ខ្ញុំសូមបន្តទៅការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ ដើមបណ្តឹងរដ្ឋប្បវេណីបីនាក់ គឺ គង់ សៀក, ជុំ សាមឿន និង ផែ ប៉ាប បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់ពួកគាត់នៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង។ ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក ជាសមាជិកកងនារី ជាផ្នែកនៃកងពលធំលេង៤៥០ និងត្រូវបានបញ្ជូនទៅព្រលានយន្តហោះកំពង់ឆ្នាំងរយៈពេល៦ខែ នៅឆ្នាំ១៩៧៧។ គាត់បានពន្យល់ថា នៅការដ្ឋានសាងសង់ "ខ្ញុំអត់មានប៉ានជ្រើសរើសយកខ្លួនឯងទេ គឺការងារនេះ សុទ្ធតែបញ្ជាគេបញ្ជាយើងទាំងអស់។ វិន័យរបស់គេ គេអត់ឲ្យយើងដើរហើរផ្តេសផ្តាស ហើយគេអត់ឲ្យដើរទាក់ទងគ្នា"។ គាត់បានពន្យល់ថា "ចាស! គេមិនឲ្យដើរទេ គេវិន័យរបស់គេ កាលណាយើងដើរគេដាក់វិន័យយើងព្រឹបឥឡូវហើយ ឬក៏គេថាយើងសេរី មិនស្តាប់បង្គាប់របស់គេ។ គេចាប់យើងយកទៅដាក់សន្តិសុខអីណាឯណីទៅទៀត។ យើងខ្លាចអាហ្នឹង យើងអត់ប៉ាន តែគេថាយ៉ាងម៉េចហើយ គឺយើងនៅហើយ។ ងូតទឹករួច គឺយើង បើថាទៅធ្វើការ ធ្វើការ។ បើឡើងពីធ្វើការវិញ គឺដេកហើយ អត់មាននិយាយគ្នាទេ អត់ប៉ានទេ។" បិទសម្រង់។

[០៩:៥៧:០០]

ដើមបណ្តឹងរដ្ឋប្បវេណី ផែ ប៉ាប ដែលស្ថិតក្នុងកងពលធំលេខ៣១០ បានពិពណ៌នាអំពីការទៅដល់ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ធំ និង កែន -- និងការណែនាំដែលគាត់ទទួលបាន -- បាទ ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ ខ្ញុំសូមដកស្រង់ដូចតទៅ៖ "ទៅដល់គេឲ្យខ្ញុំធ្វើជាមេក្រុមជញ្ជូនឥដ្ឋ ហើយនិងបៀកផ្ទះថ្ម គេរៀបទៅប្រហោងតិចៗ អីចឹង ដល់ក្រោយមក ខ្ញុំ ដល់ខ្ញុំទៅធ្វើការគេប្រជុំៗ គេហៅមេក្រុមហ្នឹងប្រជុំ គេថាក្រុមហ្នឹងមានពីណាត្អូញត្អែរ ឬមួយទម្រន់ការងារស្អិតស្រពន់រាយការណ៍

ខ្ញុំថា ក្រុមខ្ញុំអត់ទេ តែក្រុមគេថាមាន។ ក្រុមហ្នឹង គឺបាត់ដោយរបៀបហ្នឹង អ៊ីចឹងឯង។ បានខ្ញុំយល់ថា អូ! ការងារណាធ្វើ អ្នកហ្នឹង។ គឺថា សក់អាណាក្បាលអាហ្នឹង។ អ្នកណាខំប្រឹង អង្គការគេទុក។ អ្នកណាគេខ្ជិលច្រអូស គេមិនទុក។ ខ្ញុំដឹងពេលហ្នឹងឯង។"

ក្នុងអំឡុងពេលជំនុំជម្រះនេះ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានទទួលអនុញ្ញាតឱ្យតាំងសំណួរទៅជនជាប់ចោទផងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥១រូប ក្នុងចំណោម៦៤រូប បាន -- ដែលបានផ្តល់សក្ខីកម្មក៏បានសម្រេចសួរសំណួរទៅជនជាប់ចោទ តាមរយៈលោកប្រធានអង្គសវនាការ។ ជនជាប់ចោទបានអនុវត្តសិទ្ធិនៅក្នុងរបស់ខ្លួន នៅក្នុងការនៅស្ងៀមមិនឆ្លើយតប និងមិនបានឆ្លើយសំណួរទាំងនោះទេ។ នៅក្នុងវីដេអូទី៤ របស់យើងលោកស្រី សៀង សុវិដា ដែលត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅទំនប់ ១មករា ក៏បានលើកសំណួរ ហើយដែលមានខ្លឹមសារដូចខាងក្រោម៖

សូមបញ្ចាំងវីដេអូរបស់លោកស្រី សៀង សុវិដា វីដេអូទី៤។

[០៩:៥៩:២៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"នាងខ្ញុំសូមសួរលោកប្រធានជំនុំជម្រះសាលាក្តីខ្មែរក្រហម ខ្ញុំចង់ដឹងថា តើលោកមេខ្មែរ -- មេដឹកនាំខ្មែរក្រហមទាំងអស់ គាត់បានឃោសនាថា គាត់ជួយជាតិ ជួយប្រជារាស្ត្រ។ ផ្ទុយស្រឡះនៅពេលដែលគាត់បានជ័យជម្នះ និងអំណាចហើយ បែរជាគាត់កាប់សម្លាប់ ធ្វើបាបប្រជារាស្ត្រខ្លួនឯង បង្ខំធ្វើការ បង្អត់អាហារ ហើយគាត់ទុកប្រជារាស្ត្រជាសត្រូវស្លូតូជរបស់គាត់។ ជា -- ប្រហែលគាត់ -- ខ្ញុំយល់ថា គាត់ទាំងអស់គ្នាហ្នឹងប្រហែលជាទុកប្រជាជន១៧មេសា ហ្នឹង ឬក៏គាត់មានគំនុំអ្វីជាមួយប្រជាជន១៧មេសា បានគាត់ធ្វើបាបយ៉ាងហ្នឹង។ ហើយគាត់ធ្វើហ្នឹង ដើម្បីអ្វី? ហើយគាត់ធ្វើហ្នឹង ដើម្បីអ្នកណា? ខ្ញុំចង់ដឹង ហើយខ្ញុំសុំឱ្យគាត់ ចង់រាយការណ៍ឱ្យ រៀបរាប់ឱ្យរឿងហ្នឹងឱ្យបានល្អិតល្អន់ ដើម្បីឱ្យពួកកូនខ្មែរជំនាន់ក្រោយបានដឹងច្បាស់។ បើមិនដូច្នេះទេ ការកាត់ក្តីនេះ ហាក់ដូចជាអត់បានប្រយោជន៍អីទាំងអស់ ហើយយុត្តិធម៌ក៏គ្មានឱ្យម៉ែប៉ាខ្ញុំ បងប្អូនទាំងអស់ ប្រជារាស្ត្រនៅលើទឹកដីខ្មែរទាំងអស់ ដែលបានទទួលរងគ្រោះដោយសាររឿងហ្នឹង។ ពេលនេះ អ្នកទាំងអស់ហ្នឹង ស្តាប់មិនដឹងជាឈឺចាប់ប៉ុនណាទេ ខ្ញុំចង់បានចម្លើយពីគាត់ប៉ុណ្ណឹង ហើយឱ្យគាត់រៀបរាប់ ហើយឱ្យច្បាស់ ឱ្យពិត មិនឱ្យរៀបរាប់ទាំងខុសមកឱ្យពួកខ្ញុំស្តាប់ទេ។ គាត់ចេះតែប្រកែកថា គាត់អត់បានដឹង អត់បានអី ខាងថ្នាក់ក្រោមធ្វើ។ អ៊ីចឹងពេលជំនាន់នោះ គាត់មានតែតំណែង តែគាត់អត់មានតួនាទី ឬក៏អត់មានអំណាចអ្វីទាំងអស់ ឬយ៉ាង*

*ម៉េច ខ្ញុំឆ្ងល់។ តែគាត់មិនអាចលម្អិត។ ខ្ញុំចង់ឱ្យលោកព្រះរាជអាជ្ញា ចៅក្រម ជួយឱ្យគាត់មានពេលរាយឱ្យបានល្អិតល្អន់រឿងហ្នឹង ឱ្យបានច្បាស់សម្រាប់ទុកឱ្យប្រវត្តិសាស្ត្រខ្មែរនេះ ឱ្យបានកូនខ្មែរក្រោយដឹងផង។"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១០:០១:៣៤]

ខ្ញុំសូមអនុញ្ញាតបញ្ចប់ការសន្និដ្ឋាន ពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់១មករា ការដ្ឋានត្រពាំងថ្ម និងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងតែប៉ុណ្ណេះ។

ជាបន្តសូមអនុញ្ញាតលោកប្រធាន អំពីលោកប្រធាន ជូនវេទិកាទៅលោកស្រីមេធាវី ជេត វណ្ណលី ដើម្បីបន្តធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធទៅនឹងសហករណ៍ត្រាំកក់ ការធ្វើទុក្ខបុកម្នេញទៅលើសាសនិក និងមន្ទីរសន្តិសុខក្រាំងតាចាន់។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញលោកស្រីមេធាវី!

[១០:០២:២៥]

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ នាងខ្ញុំឈ្មោះ ជេត វណ្ណលី មេធាវី ដើមបណ្តឹងរដ្ឋប្បវេណី។ ថ្ងៃនេះ ជាឱកាសពិសេសមួយ ដែលខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានចុងក្រោយក្នុងការទាមទាររកយុត្តិធម៌ និងស្វែងរកការពិត ជូនដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខអង្គជំនុំជម្រះក្នុងសវនាការនេះ។

ជាកិច្ចបន្តពីមេធាវី ពេជ អង្គ ខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋាន ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ ក្រោយពេលផ្លាស់ទីលំនៅ ដោយបង្ខំនៅតាមទីក្រុង និងទីប្រជុំជនក្នុងខែមេសា ឆ្នាំ១៩៧៥ ប្រជាជនកម្ពុជាត្រូវបានបញ្ជូនឱ្យទៅរស់នៅនិងធ្វើការនៅតាមជនបទ។ តាមរយៈគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា សហករណ៍ និងការដ្ឋានជាច្រើនត្រូវបានបង្កើតឡើងទូទាំងប្រទេស ដែលជាកន្លែងធ្វើការរួមរបស់ប្រជាជនទាំងអស់ មិនថាក្មេង ចាស់ ប្រុស ស្រី ទាហាន មន្ត្រីរដ្ឋការ ជនស៊ីវិល ឬព្រះសង្ឃឡើយ ត្រូវធ្វើការតាមការចាត់តាំងរបស់អង្គការដាច់ខាត ដោយអនុវត្តសេដ្ឋកិច្ចតាមផែនការមហាលោតផ្លោះ មហាអស្ចារ្យ របស់ខ្មែរក្រហម។ ជាលទ្ធផលនៃគោល

នយោបាយ សហករណ៍និងការដ្ឋាននេះ ប្រជាពលរដ្ឋខ្មែររាប់លាននាក់ បានក្លាយជាជនរងគ្រោះនៃការងារដោយបង្ខំ និងភាពជាទាសករ។ ការសម្លាប់ ការឃុំខ្លួន ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញឃោរឃៅគ្រប់បែបយ៉ាង ដែលបង្កឲ្យពួកគាត់ទទួលរងនូវការឈឺចាប់ទាំងផ្លូវកាយ និងផ្លូវចិត្ត រហូតមកដល់សព្វថ្ងៃ។

[១០:០៤:៤៤]

បន្តទៀតនេះ ខ្ញុំជាមេធាវី នឹងធ្វើការបង្ហាញភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន លោក លោកស្រីចៅក្រម បទឧក្រិដ្ឋទាំងអស់ក្នុងរបបនោះ មិនមែនកើតឡើងដោយចៃដន្យទេ តែជាបទឧក្រិដ្ឋដែលកើតឡើងតាមការអនុវត្ត និងតាមការផែនការរួម និងប្រព្រឹត្តិឡើងជាប្រព័ន្ធដោយកងកម្លាំង និងកម្មាភិបាលដែលដឹកនាំដោយលោក ខៀវ សំផន និងលោក នួន ជា និងមេដឹកនាំខ្មែរក្រហមផ្សេងទៀត។

ដីកាដំណោះស្រាយលើកឡើង គិតត្រឹមខែមេសា ឆ្នាំ៧៧ ឃុំទាំងអស់នៅក្នុងស្រុកត្រាំកក់ត្រូវបានគេរៀបចំបង្កើតជាសហករណ៍។ អង្គហេតុទាំងនេះបង្ហាញពីការបង្កើត និងដំណើរការសហករណ៍ រួមទាំងលក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅរបស់ប្រជាជន ដែលត្រូវបានបញ្ជូនទៅទីនោះ។ ការកំណត់អត្តសញ្ញាណប្រជាជនថាជាខ្មាំង ការអប់រំរៀនសូត្រ ការចាប់ខ្លួន ការបាត់ខ្លួនប្រជាជនដោយសារកំហុសនានា និងការប្រព្រឹត្តលើក្រុមជាក់លាក់ ពោលគឺប្រជាជនដែលជាប់ពាក់ព័ន្ធនឹងអតីតរបបសាធារណរដ្ឋខ្មែរ ជនជាតិវៀតណាម និងពុទ្ធសាសនិក។

ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥២រូបត្រូវបានទទួលស្គាល់ដោយផ្អែកលើបទឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់នៅសហករណ៍ត្រាំកក់។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១១រូប បានផ្តល់សក្ខីកម្មនៅទីនេះនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងហេតុការណ៍ ដែលពួកគាត់ជួបប្រទះដោយផ្ទាល់នៅសហករណ៍ត្រាំកក់។

[១០:០៦:៤៤]

ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីនាក់ គឺ អ៊ុំ សុផានី, ជូ គឹមឡន និង អ៊ឹង សារឿន បានផ្តល់ភស្តុ-តាងភ្ជាប់ជនជាប់ចោទទៅនឹងបទឧក្រិដ្ឋ ដែលកើតឡើងនៅសហករណ៍ត្រាំកក់។ គាត់បានរៀបរាប់អំពីការបាត់បង់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់ពួកគាត់ ក្រោយពេលផ្លាស់ប្តូរទីលំនៅទៅកាន់សហករណ៍របស់ពួកគាត់ ដោយត្រូវធ្វើការ និងហូបចុករួម ការបែកបាក់ចេញពីគ្រួសារ និងការកាប់សម្លាប់សមាជិក

គ្រួសារ។

ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំនាក់ទៀត ដែលរួមមាន ខែប -- យ៉ែម ខុន្នី, ប៊ុន សារឿន, អ៊ឹម វណ្ណៈ, អ៊ឹម យាន និង ឡិប នាង បានផ្តល់សក្ខីកម្មអំពីលក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅ ដែលពួកគាត់បានឆ្លងកាត់ ព្រមទាំងព្យសនកម្មដែលពួកគាត់បានទទួលរងនៅវ័យកុមារ និងនៅយុវវ័យ។

ចំណែកដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ និង ថាន់ ធីម បានផ្តល់សក្ខីកម្មអំពីការផ្លាស់ទីលំនៅពួកគាត់ទៅកាន់សហករណ៍ត្រាំកក់ និងធ្វើការយូរម៉ោង គ្មានពេលកំណត់ ពុំមានអាហារគ្រប់គ្រាន់ និងការថែទាំសុខភាពឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ក៏បានរៀបរាប់ពីការចាប់ខ្លួន ឃុំខ្លួនគាត់នៅក្នុងផ្សារអង្គរកាផងដែរ។

ដើមបណ្តឹងរដ្ឋប្បវេណី តាក់ សាន់ បានផ្តល់ភស្តុតាងអំពីការធ្វើទុក្ខបុកម្នេញយ៉ាងសាហាវ និងការរំលោភបំពានដែលគាត់បានទទួលរង។

[១០:០៨:២៩]

ការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើជីវភាព ការរស់នៅ និងការងាររបស់ប្រជាជននៅក្នុងសហករណ៍ត្រាំកក់ គឺជាការរំលោភអំណាចហួសពីការគ្រប់គ្រងនៅក្នុងប្រព័ន្ធនយោបាយធម្មតា ដែលបង្កជាបទឧក្រិដ្ឋនៃការដាក់ឲ្យទៅជាទាសករ ក្នុងចំណោមបទឧក្រិដ្ឋ ដែលកើតឡើងផ្សេងទៀតជាច្រើន។

ដើម្បីសម្រេចករណីនេះបាន ត្រូវអង្គជំនុំជម្រះកំណត់កម្រិតនៃការគ្រប់គ្រងដែលបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តលើប្រជាជនមិនថាការគ្រប់គ្រងចិត្តសាស្ត្រ ដូចជាការជំរុញបរិយាកាសភ័យខ្លាច ការគ្រប់គ្រងលើម៉ោងការងារ ពាក្យសម្តី ជីវិតគ្រួសារ និងផ្លូវភេទជាដើម។

បរិយាកាសនៃការភ័យខ្លាច ត្រូវបានបង្កើតឡើងតាមរយៈការប្រើប្រាស់កិច្ចប្រជុំអប់រំរៀនសូត្រការគ្រប់គ្រងលើប្រជាជនថ្មីដោយប្រជាជនមូលដ្ឋាន និងតាមរយៈការដាក់ទណ្ឌកម្មចំពោះការគេចចេញពីរចនាសម្ព័ន្ធសង្គម ដែលទើបកំណត់ថ្មីៗ។

[១០:០៩:៥៥]

យើងជឿជាក់ថា ភស្តុតាងដែលដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ជូនក្នុងពេលសវនាការ និងការសង្ខេបនៅថ្ងៃនេះ នឹងជួយឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចសេចក្តីនាពេលខាងមុខ។ ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មអំពីតម្រុយដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលា -- តុលាការ

កំពូល ដើម្បីកំណត់អាទិភាពនៃការគ្រប់គ្រង។ ពោល គឺការគ្រប់គ្រងផ្ដាច់មុខលើបុគ្គល។ ដើមបណ្ដឹងរដ្ឋប្បវេណី រី ពៅ ត្រូវបានផ្លាស់ទីលំនៅពីកម្ពុជាក្រោមទៅកាន់សហករណ៍ត្រាំកក់។ ហើយបានរំឭកឡើងវិញថា ឯកសារអត្តសញ្ញាណរបស់គាត់ត្រូវបានគេប្រមូលយក ហើយដុតបំផ្លាញចោល នៅពេលដែលគ្រួសារគាត់បានទៅដល់។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានផ្ដល់សក្ខីកម្មថា សូមដកស្រង់ពាក្យសម្ដីផ្ទាល់របស់គាត់៖ “បាទ ខ្ញុំសូមជម្រាបជូនថា កាលពីសម័យនោះអត់មានអត្តសញ្ញាណប័ណ្ណទេ។ យើងមានចាស់ ដែលវ័យចំណាស់ចាប់ពីអាយុ២០ឡើងទៅ គឺមានកាត។ កាតខ្មៅមួយកាលនោះ សម័យដើមមានតែកាតខ្មៅនេះឯង។ កាត គឺអ្វីដែលពាក់ព័ន្ធ គឺគេប្រមូលដុតចោលអស់។” សូមបញ្ចប់ការដកស្រង់។

[១០:១១:១៩]

គាត់បានបន្តទៀតថា សូមដកស្រង់៖ “ដឹងគេយកទៅណា គេប្រាប់ថានៅទីនេះមានអង្គការគ្រប់គ្រងហើយ។ អ៊ីចឹង ខ្ញុំអត់ដឹងថាគេយកខ្ញុំទៅណាទៅណីទេ ខ្ញុំអត់ដឹងទេ។ ហើយគេបានប្រជុំប្រាប់ថា ពេលនេះ នៅទីនេះ មានសហករណ៍ មានអង្គការប្រមូលផ្ដុំហើយ មិនបាច់ឲ្យពុកម៉ែបងប្អូនពិបាកអីទៀតទេ។ មកដឹងតែពីអ្នកនិន ដឹងតែហូបទៅ កុំបាច់ខ្វល់រឿងដាំស្ល ឬអី បាទ។” សូមបញ្ចប់ការដកស្រង់។

ការបង្កើតបរិយាកាសភ័យខ្លាច គឺជារបៀបគ្រប់គ្រងមួយរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដើមបណ្ដឹងរដ្ឋប្បវេណី រី ពៅ បានផ្ដល់សក្ខីកម្មអំពីការរស់នៅនៅក្នុងបរិយាកាសភ័យខ្លាចនេះ នៅត្រាំកក់។ គាត់បានបន្ថែមទៀតថា សូមដកស្រង់៖ “សម័យនោះ ទាំងគេ ទាំងខ្ញុំ ការគោរពវិន័យរបស់អង្គការចាត់តាំងរបស់គេ គឺគ្មានអ្នកណាដើរឆ្វេចឆ្វាចទេ។ មនុស្សម្នាក់ៗភ័យខ្លាច តែអារឿងស្លាប់។ រឿងគេយកទៅសម្លាប់ ឬមួយគេយកទៅដោយសម្ងាត់ ដោយយើងមិនដឹងខ្លួន។ គឺគ្មានអ្នកណាហ៊ានដើរសេរី ហ៊ានធ្វើអ្វីខុសពីគោលការណ៍នៃច្បាប់របស់អង្គការគេឡើយ។” សូមបញ្ចប់ការដកស្រង់។

ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានវ័យក្មេងនៅជាកុមារក្នុងសម័យនោះ បានពិពណ៌នាអំពីការគ្រប់គ្រងដែលខ្មែរក្រហមបានអនុវត្តលើជីវិតគ្រួសាររបស់ពួកគេ និងរបៀបដែលគ្រួសាររបស់ពួកគេបានត្រូវបំបែកចេញ។ ហើយរៀបចំចាត់តាំងឲ្យធ្វើការងារនៅតាមកងខុសៗគ្នា។ ដើមបណ្ដឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ដែលមានអាយុ១៤ឆ្នាំ នៅពេលនោះ បាននិយាយថា សូមដកស្រង់៖ “មុនដំបូង ខ្ញុំនៅជាមួយគ្រួសារ រួចហើយគេបំបែកខ្ញុំតាមកង ឲ្យទៅនៅតាមកង ហើយឪពុកម្ដាយខ្ញុំហ្នឹង នៅតាមប្អូនខ្ញុំអ៊ីចឹងទៅ ហើយខ្ញុំទៅធ្វើការទៅ។ បងខ្ញុំ ក៏ទៅធ្វើការដែរទៅ។” សូមបិទការដកស្រង់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:១៣:២៥]

និងសូមលើកការដកស្រង់មួយទៀត៖ "ដល់ខ្ញុំបែកពីគាត់អ៊ីចឹងទៅ សុំគេមកលេង គេថាមិនទាន់ធ្វើការឲ្យគេហើយផង សុំទៅលេង។ ហើយពួកថ្មី ខ្ញុំគ្មានដឹងអី ចេះតែសុំគេទៅ ដោយសារនឹកម៉ែឪ និងបងប្អូន ហើយនឹកយាយដែលគាត់ចាស់។ គេថា ឥឡូវចង់សុំទៅអី? ខ្ញុំថា សុំទៅម៉ាកំណាត់ថ្ងៃអ្ហែ! គេថា បើសុំម៉ាកំណាត់ថ្ងៃ នុ៎ះ! បង្គី ហើយនិងចបមួយសម្រាប់ យកទៅកាប់ដីដំបូកទៅ។" សូមបិទការដកស្រង់។

ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម យាន ដែលជាកុមារភាពកាលពីពេលនោះ បានផ្តល់សក្ខីកម្មថា សូមដកស្រង់៖ "ចាស! ការបែកបាក់ពីឪពុកម្តាយហ្នឹង ខ្ញុំបែកតាំងពីឆ្នាំ៧៦ម្ល៉េះ ប៉ុន្តែគេឲ្យមកជួបឪពុកម្តាយក្នុងមួយខែបីដង។ តែដល់យូរទៅ គេកាត់បន្ថយនៅត្រឹមតែមួយខែម្តងទេ មិនដាច់រហូតទេ ប៉ុន្តែខ្ញុំត្រូវការឪពុកម្តាយខ្ញុំ ការថ្នាក់ថ្នម ហើយខ្ញុំនឹករំឭកគាត់ពេក។" សូមបិទការដកស្រង់។

[១០:១៤:២៦]

គាត់បានបន្តទៀតថា៖ "ពេលហ្នឹង ខ្ញុំនឹកពេក ខ្ញុំចង់សុំគេទៅជួបឪពុកម្តាយ តែគេមិនឲ្យទៅ ព្រោះអី គេមានផែនការគេថា ថ្ងៃដែលគេឲ្យទៅ គឺថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ បើអ៊ីចឹង គេកាត់បន្ថយរបបឬ ហើយខ្ញុំនៅតែសុំគេទៅដដែល ព្រោះខ្ញុំសុំម្តង ពីរដងអ៊ីចឹង ក៏គេនៅតែមិនឲ្យទៅ។ គេថា ឲ្យយើងដឹងតែពីធ្វើការតាមកងទៅ។" សូមបិទការដកស្រង់។

**ប្រធានអង្គជំនុំ៖**

បាទៗ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការនីតិវិធី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣០នាទី)*

[១០:៣០:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បី -- ដែលទទួលសិទ្ធិដើម្បីបន្តធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួន។

**លោកស្រី ជេត វណ្ណលី៖**

សូមគោរពលោកប្រធាន។ សូមលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ យើងខ្ញុំសូមអនុញ្ញាតបន្ត។

ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម យាន បានបញ្ជាក់បន្តថា សូមដកស្រង់៖ “ពេលនោះ គេចាប់ខ្ញុំទៅជីកដីកប់ ដោយសារខ្ញុំរត់គេចពីកង ខ្ញុំសុំមិនបាន ខ្ញុំក៏រត់គេចមកដើម្បីជួបឪពុកម្តាយខ្ញុំ” សូមបិទការដកស្រង់។ ភស្តុតាងក៏បានបង្ហាញដែរថា របៀបរបបហូបចុក និងអាហាររបស់ប្រជាជន ក៏ត្រូវបានអង្គការគ្រប់គ្រងទាំងអស់ ដូចករណីដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រជាជនថ្មីដែលត្រូវបានផ្លាស់ទីលំនៅពីក្រុងភ្នំពេញ ត្រូវបានគេបញ្ជូនទៅរស់នៅក្នុងឃុំលាយបូរ ហើយទីនោះ រហូត -- ហើយគាត់នៅទីនោះរហូតដល់ចុងរបប។ គាត់បានរៀបរាប់ថា អ្នកធ្វើការត្រូវហូបរួមទាំងអស់ សូមដកស្រង់៖ “បាយបបរមួយវែកត្រឡោក។ បបរមួយវែក និងឆ្នាំងសម្លមួយដាក់កណ្តាលហូបគ្នាបួននាក់។ មួយវែកម្នាក់ៗអស់ប៉ុណ្ណឹងគឺឈប់ហើយ អត់មានអីថែមឱ្យទេ។ យើងអត់សូវឆ្អែត ហើយយើងសម្រុកការងារ តែមានភ្លាត់មាត់ថា ហូបបាយអត់ឆ្អែត ហេរហត់ ត្រូវគេចាប់យកទៅរៀនសូត្រ។ រៀនសូត្រគឺទៅបាត់រហូត។” សូមបិទការដកស្រង់។ ក្រៅពីនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ភស្តុតាងថា អង្គការបានប្រើវិធីសាស្ត្រដាក់ទណ្ឌកម្មដើម្បីគ្រប់គ្រងប្រជាជនរបស់ខ្លួន ពួកគាត់បានរៀបរាប់ថា ពួកគាត់ត្រូវបានផ្តាច់របបអាហារ ប្រសិនបើពួកគាត់ពុំបានធ្វើការសម្រេចតាមផែនការកំណត់។

ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ដែលជាកុមារមានអាយុទើបតែ៨ឆ្នាំ ហើយត្រូវគេចាត់ទុកជាប្រជាជនថ្មី គាត់ត្រូវការ -- ត្រូវគេបញ្ចូលទៅក្នុងកងចល័តកុមារ ដែលមានមូលដ្ឋាននៅក្នុងស្រុក ១០៥ សូមបង្ហាញវីឌីអូលោកស្រី អ៊ឹម វណ្ណៈ លេខ១។

[១០:៣៣:១៤]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*“ចាស គេឱ្យពួកខ្ញុំទៅជីកសែងដីប្រឡាយហ្នឹងចាប់តាំងពីម៉ោងប្រាំមួយព្រឹក រហូតដល់ម៉ោងដប់មួយកន្លះថ្ងៃត្រង់។ បើពួកខ្ញុំធ្វើមិនហើយ គេមិនឱ្យបាយហូបទេ ពីព្រោះគេដាក់កំណត់កុមារហ្នឹងឱ្យគ្នា១០នាក់ហ្នឹងឱ្យហើយដីចំនួន១០គូប ១០ម៉ែត្រការ៉េ ហ្នឹង។ តែពួកខ្ញុំ ជួនកាលក៏ធ្វើហើយ ជួនកាលក៏*

*ធ្វើមិនហើយ។ បើកាលណាជួបប្រទះដីទន់ទៅ ពួកខ្ញុំក៏បានធ្វើក្នុងមួយថ្ងៃទល់យប់ហ្នឹងហើយ បើថាដីរឹងទៅ កុមារខ្ញុំធ្វើមិនបានទេ។ បើធ្វើមិនបាន គេមិនឲ្យបបរហូបទេ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:៣៤:០២]

សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា អង្គការបានចាត់ទុកប្រជាជនជាកម្មសិទ្ធិរបស់ខ្លួនដោយមនុស្សត្រូវបានប្រើប្រាស់ដូចសត្វធាតុ។ មិនថាការងារប្រភេទណា កន្លែងណា ពេលណា អង្គការចាត់តាំងត្រូវធ្វើឲ្យ -- អង្គការចាត់តាំងឲ្យធ្វើ ត្រូវតែធ្វើឲ្យហើយ។ មធ្យោបាយរស់នៅចិញ្ចឹមជីវិត សាលារៀន វត្តអារ៉ាម ផ្សារ កម្មសិទ្ធិឯកជនត្រូវបានបំផ្លាញ និងលុបបំបាត់ចោលទាំងស្រុង។ កម្ពុជាប្រជាធិបតេយ្យ គឺជារដ្ឋទាសករយ៉ាងពិតប្រាកដ។ ក្រៅពីឧក្រិដ្ឋកម្មនៃការដាក់ឲ្យទៅជាទាសករ ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅសហករណ៍ត្រាំកក់ អង្គជំនុំជម្រះសាលាដំបូងក៏ត្រូវពិនិត្យពិចារណា និងសម្រេចផងដែរទៅលើការថែទាំសុខភាពពុំសមស្រប លក្ខខណ្ឌរស់នៅការងារធ្ងន់ធ្ងរ ការបង្អត់អាហារ និងបទឧក្រិដ្ឋនានាផ្សេងទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការប្រើប្រាស់ថ្នាំពេទ្យដែលធ្វើឡើងពីដំឡូងមី ឬទឹកដូង ឬថ្នាំអាចម៍ទន្សាយ ដើម្បីព្យាបាលជំងឺត្រូវបានលើកឡើងនៅក្នុងសវនាការតុលាការនេះ។ ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងនៅពេលជំនុំជម្រះបង្ហាញពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរលើសុខភាពប្រជាជន ដោយសារការប្រើប្រាស់ថ្នាំសង្កូវគ្មានគុណភាព និង ការព្យាបាលដោយគ្រូពេទ្យដែលពុំមានការបណ្តុះបណ្តាល ឬវិជ្ជាជីវៈត្រឹមត្រូវ។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មថា សូមដកស្រង់៖ "ពេលនាងខ្ញុំឈឺ ស្រាប់តែតំណាងកងភូមិ គណៈកម្មការសេដ្ឋកិច្ច ដាំបាយចុងភៅ គេដកបាយខ្ញុំ ថាខ្ញុំឈឺសតិអារម្មណ៍ ហើយកាលហ្នឹង ខ្ញុំគ្រុនចាញ់ ឈឺខ្លាំង ឈឺរហូតដល់កើតថៃចេញពីខ្លួន។ ជំនាន់៧៦ ខ្ញុំឈឺខ្លាំង។ យកខ្ញុំទៅដាក់មន្ទីរពេទ្យឃុំលាយបូរ។ ពេទ្យហ្នឹងគេចែកជាមុខសញ្ញាទៀត គឺពេទ្យ១៧ ឃុំលាយបូរ។" គាត់បន្តទៀតថា សូមដកស្រង់៖ "គេយកខ្ញុំទៅដាក់សេរ៉ូម ឲ្យលេបថ្នាំគ្រាប់ដូច ធ្វើពីដំឡូងមី ហើយសេរ៉ូម ជាទឹកដូងស្រស់ យកទៅចាក់ជើងខ្ញុំ ធ្វើឲ្យជើងខ្ញុំខូច ដើរខ្ញើចៗទល់សព្វថ្ងៃ ខ្ញុំនៅឈឺដដែល។ ខ្ញុំបានតាម្នាក់នោះគាត់បានប្រាប់ថា តែទុកយូរជើងហ្នឹងនឹងស្វិតហើយ គាត់ឲ្យរកអង្រង ពន្លៃ ស្រា យកមកស្អំរឹតទៅ។" សូមបិទការដកស្រង់។

[១០:៣៦:៤៣]

កង្វះអាហារ និងការថែទាំសុខភាព បានបណ្តាលឲ្យប្រជាជនស្លាប់ជាបន្តបន្ទាប់។ នេះជាអំពើមនុស្សឃាតមួយដែលអាចត្រូវបានកំណត់ជាបទចោទ។ យោងតាមភស្តុតាងដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី លក្ខខណ្ឌរស់នៅលំបាកក្នុងសហករណ៍ត្រាំកក់ បាននាំឲ្យប្រជាជនជាច្រើនបាត់បង់ជីវិត តួយ៉ាងដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន បានបាត់បង់កូនស្រីរបស់ខ្លួនដែលមានអាយុទើបតែបីឆ្នាំ។ ខ្ញុំសូមអនុញ្ញាតបង្ហាញវីដេអូរបស់លោកស្រី ជូ គឹមឡន លេខ២។

[១០:៣៧:២០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"១៩៧៦ គឺយើងមិនអាចរកអាហារក្រៅបានទេ។ គឺអត់ អស់លទ្ធភាព ដល់ហើយឈឺទៅ វាអត់អាហារ ដូចថា មុនដំបូងកើតកញ្ជ្រើលអ៊ីចឹងលាប់ លាប់កញ្ជ្រើលអ៊ីចឹងអាចទៅជាឈឺៗ ហើយជ្រុះសក់ៗ ហើយទើបយើងយកទៅពេទ្យទៅស្លាប់ អត់មានថ្នាំព្យាបាលចាស ដើមៗមកពីអត់អាហារហ្នឹងតែម្តង ព្រោះវារើសដីហូប វារើសសំបកក្តាមហូប ចាស។ ដល់ពេលឈឺអ៊ីចឹង វាហូបអីអត់កើតទេ ដល់ពេលវាលាប់អ៊ីចឹង វាហូបបាយហូបអីអត់កើតចាស ត្រូវដាច់ៗចំណីដែលយើងគ្មានរបស់អ្វីដែលជាសម្រាប់ប៉ូវ ហូបបាយអត់កើតក៏ដាច់ចំណីពេលហ្នឹងចាស អត់មានថ្នាំពេទ្យ អត់អីទាំងអស់។ ចំណីអាហារ បើទោះបីជាមានក៏ឈឺហើយ យើងអត់មានថ្នាំ ជាពិសេសគឺអត់ថ្នាំហ្នឹងតែម្តង។ អត់ថ្នាំព្យាបាល ម៉្លោះហើយគឺទៅតាមហ្នឹង គឺត្រូវស្លាប់ដោយសារអត់មានថ្នាំ និងហូបចំណីអាហារ អត់ លែងកើតចាស។"--*

[១០:៣៨:៤៥]

ការចាប់អារម្មណ៍មួយទៀត នៃភស្តុតាងរបស់ដើមបណ្តឹង--

--*"តួបផ្សំជាមួយគ្នាទាំងពីរមុខ អត់ចំណីអាហារហូបគ្រប់គ្រាន់ ហើយនិងមានជំងឺកើតកញ្ជ្រើលចាស តួបផ្សំជាមួយគ្នា និងអត់ថ្នាំពេទ្យ បូករួមបញ្ចូលគ្នា"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:៣៩:០៧]

ការចាប់អារម្មណ៍មួយទៀត នៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ គឺការបាត់ខ្លួន។ យើងបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ពិនិត្យពិចារណាជាពិសេសលើភស្តុតាងពាក់ព័ន្ធនឹងការបាត់ខ្លួននៅតាមសហករណ៍ ដែលយើងបានរៀបរាប់លម្អិតនៅក្នុងសារណារបស់យើងខ្ញុំ។ ទោះបីការបាត់ខ្លួនអាចជួយដល់ការកំណត់បទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងទៀតក៏

ដោយ ក៏ការបាត់ខ្លួនទាំងនេះ អាចកំណត់នូវបរិយាកាសភ័យខ្លាច ដែលជាសញ្ញាបញ្ជាក់បង្ហាញនៅការដាក់ឲ្យទៅជាទាសករ។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១០នាក់ បានផ្ដល់សក្ខីកម្មពីការបាត់ខ្លួនរបស់ប្រជាជននៅក្នុងសហករណ៍ត្រាំកក់។ ក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីនេះ ដើមបណ្ដឹងរដ្ឋប្បវេណី ឡឹប នាង បានបង្ហាញពីការបាត់ខ្លួនបងប្អូនបង្កើតរបស់គាត់ថា សូមដកស្រង់៖ "ខ្ញុំកំពុងតែជីកប្រឡាយ ឃើញប្អូនខ្ញុំ ខ្មែរក្រហមដឹករទេះសេះដាក់១២នាក់ យកទៅ។ ប្អូនខ្ញុំស្រែកថា បងអើយ! ខ្ញុំទៅហើយ។ យកទៅបាត់រហូត។ បាត់បងពីរ បាត់ប្អូនពីរ។ បងក៏បាត់ ប្អូនក៏បាត់ ដល់អត់មានម៉ែមានឪ គឺនៅឯកោតែឯង។" ដើមបណ្ដឹងរដ្ឋប្បវេណី ឡឹប នាង បានពន្យល់ថា បងស្រីបង្កើតរបស់ខ្លួនឈ្មោះ ឡឹប លេខ និង ឡឹប ម៉ឺល ត្រូវបានគេយកចេញទៅក្រោយពេលអ្នកទាំងពីរធ្លាក់ខ្លួនឈឺ ដែល -- ហើយមិនដែលឃើញត្រឡប់មកវិញទេ។ សូមបង្ហាញវីដេអូ ឡឹប នាង លេខ៣។

[១០:៤០:៤៧]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខ្ញុំនៅត្នោតចាងហ្នឹង ធ្វើការនៅហ្នឹង បងខ្ញុំឈឺ បងប្រុសឈឺ បងស្រីឈឺ ដល់ឈឺហើយ យកទៅពេទ្យ ដល់យកទៅ ទៅបាត់រហូត។ អត់មានឃើញដឹងបង ដឹងប្អូន ដឹងគេយកទៅដល់ណា។ យកទៅពេទ្យ យកទៅបាត់រហូតអត់មានឃើញយក -- គាត់ឈឺរាកអាចម៍ក្ដៅ យកទៅពេទ្យ យកទៅ ទៅបាត់រហូត។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:៤១:១២]

សក្ខីកម្មរបស់ដើមបណ្ដឹង ថាន់ ធឹម មានសារៈសំខាន់ខ្លាំងណាស់ ដោយសារវាបង្ហាញអំពីការធ្វើទារុណកម្មនៅក្នុងមន្ទីរឃុំឃាំងនានា ក្រៅពីក្រាំងតាចាន់ និង ស-២១។ ដើមបណ្ដឹងរដ្ឋប្បវេណី ថាន់ ធឹម ដែលជាប្រជាជនថ្មី ត្រូវបានជម្លៀសទៅស្រុកត្រាំកក់នៅក្នុងឆ្នាំ១៩៧៧។ គាត់បានផ្ដល់សក្ខីកម្មថា គាត់ត្រូវបានគេចាប់ខ្លួនដោយសារកូនស្រីរបស់គាត់បានរត់គេចពីសហករណ៍។ ហើយក្រោយមក គាត់ត្រូវបានគេឃុំ និងធ្វើទារុណកម្មនៅផ្សារអង្គរកា។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបាននិយាយថា សូមដកស្រង់៖ "គេចាប់ខ្លួនខ្ញុំ ដោយសារកូនស្រីខ្ញុំ មីច្បងនោះ វាកងជាមួយនឹង នាង អៀម យ៉េន ដែលឡើងធ្វើសក្ខីកម្មមុនខ្ញុំ។ វាដើរលួចកាច់អំពៅគេ ដល់រួចទៅ គេចាប់វ៉ៃ។ ហើយឲ្យវាឆ្លើយថា ខ្ញុំហ្នឹងធ្វើទាហានពាក់ស័ក្ដិពីរនៅភ្នំពេញ បានគេឲ្យវារួចខ្លួន។ ហើយក្មេងវាចេះតែឆ្លើយទៅ។ វាមិនដឹងឪវាទៅ

ងាប់ឯណា។ គេចាប់ឪយកទៅវ៉ៃចោល វាមានដឹងឯណា។ បាទ ដោយសារកូនហ្នឹងឯង។" សូមបិទការដកស្រង់។ ការចាប់ខ្លួន និងការដាក់ទោសស្មានៗមិនសមហេតុផល បានធ្វើឲ្យគាត់ និងប្រជាជនមិនដឹងអីសោះផ្សេងទៀតជាច្រើន បានក្លាយជាជនរងគ្រោះនៃការឃុំខ្លួន និងការធ្វើទារុណកម្ម។ សូមបង្ហាញវីដេអូលោក ថាន់ ធឹម លេខ៤។

[១០:៤២:៥០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ចេញមកចាប់ឱបខ្ញុំបាទជាប់ បាទ។ ចាប់ឱបខ្ញុំបាទជាប់អ៊ីចឹង ហើយគេយកខ្សែគោហ្នឹង យកមកចងខ្ញុំបាទហ្នឹង ចងស្លាបសេកហ្នឹងទៅក្រោយ បីចំណងបាទ។ បីចំណងៗអ៊ីចឹងទៅ ដល់រួចទៅបន្ទាប់មក ខ្ញុំនឹកថាខ្ញុំស្លាប់ហើយពេលហ្នឹង គ្មានរស់ទេ ព្រោះស្លាប់ដោយអត់មានទោសកំហុសអីសោះ។ បាទ ដល់រួចទៅ គេវ៉ៃខ្ញុំហ្នឹង ម្នាក់ចូលអ៊ីចឹង វ៉ៃដួលត្រឡប់ត្រឡិនអ៊ីចឹងទៅ គេសួរចម្លើយ ហ្អែងនៅភ្នំពេញ នៅធ្វើស្អី? អ្អែង ឆ្លើយប្រាប់គេឲ្យត្រង់មក។ ពួកប៉ុលពត ហ្នឹងវានិយាយមកយើងអ៊ីចឹង វាថាអត់មានក្រមសីលធម៌អីទេ នៅក្នុងខ្លួនវាហ្នឹង វាសុទ្ធតែអ្អែង អ៊ីចឹងតែម្តង។ អ្អែងនៅក្នុងក្រុងភ្នំពេញអ្អែងធ្វើអី? អ្អែងធ្វើទាហាន ឬមួយក៏ធ្វើអី? ខ្ញុំបាទឆ្លើយប្រាប់គេថា ម្តាយខ្ញុំអត់មានធ្វើអីទេ អត់មានធ្វើទាហានទេ ខ្ញុំជាកម្មករ ខ្ញុំជាអ្នករកស៊ីកាប់អុស កាប់អីលក់ ខ្ញុំនៅហ្នឹងជំរំហ្នឹង ក៏ខ្ញុំអត់មានធ្វើអីដែរ ខ្ញុំជាកម្មករទេ។ ដល់អ៊ីចឹងទេ គេក៏ម្នាក់វ៉ៃអស់ចិត្ត ម្នាក់ចូលមកវ៉ៃទៀត។ សួរចម្លើយខ្ញុំ នៅតែដដែលៗ។ គេថា អ្អែងឆ្លើយប្រាប់អញឲ្យត្រង់មក បើហ្អែង ឆ្លើយប្រាប់អញត្រង់ អញលែងហ្អែងទៅឥឡូវ។ ខ្ញុំមិនដឹងបានស្អីលាតត្រដាងប្រាប់គេឲ្យត្រង់ ខ្ញុំថា ខ្ញុំជាកម្មករ អ្នកកាប់អុស កាប់អីលក់អ៊ីចឹងទៅ ចិញ្ចឹមជីវិតកូនប្រពន្ធហ្នឹង។ ខ្ញុំវាតូចចិត្តដែរ ខ្ញុំវាអត់មានរឿង ទោសកំហុសអីសោះ យកខ្ញុំទៅធ្វើទារុណកម្ម យ៉ាងធ្ងន់ធ្ងរយ៉ាងនេះ។ បើមានទោសកំហុសអី ខ្ញុំអត់ខ្លាចទេ ខ្ញុំអត់ខ្លាចនឹងទទួល ប៉ុន្តែខ្ញុំអត់មានទោសកំហុសអីសោះ។ ហើយគេបានដាក់ខ្ញុំនៅកន្លែងហ្នឹងទាំងយប់ទាំងថ្ងៃៗហ្នឹងអត់ឲ្យចេញទៅណាទេ។ បាទ គេវ៉ៃខ្ញុំបាទនឹងដំបងពីងពង់ ឬស្សីពីងពង់យើង ឫស្សីតាន់ ប៉ុនក្តៅដៃហ្នឹង សំពងតែម្តង។ អាហ្នឹងគេវ៉ៃសួរចម្លើយ វ៉ៃនឹងឫស្សីពីង -- បាទ គេវ៉ៃផ្លាស់ប្តូរគ្នា ព្រោះថាគ្នាគេប៉ុន្មាននាក់ហ្នឹងគេ -- គេអាមួយវ៉ៃហត់អ៊ីចឹងទៅ មួយចូលវ៉ៃទៀត អាមួយវ៉ៃហត់ ចូលវ៉ៃ ទាល់តែខ្ញុំហ្នឹងសន្លប់ទៅបានដឹងខ្លួនឡើងវិញ បានគេដឹក។ អ៊ីចឹងទៅ គេហៅទៅកងរទេះសេះ ដឹកទៅផ្សារអង្គរកាហ្នឹង ដាក់គុកហ្នឹង។"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៤៥:៥៧]

ចំណុចសំខាន់មួយទៀតនៅសហករណ៍ត្រាំកក់ គឺការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនា។ ការហាមឃាត់ ការគោរពរាល់ប្រភេទសាសនា គឺជាប្រធានបទមួយក្នុងចំណោមប្រធាននានានៅក្នុងការជំនុំជម្រះនេះ។ អង្គជំនុំជម្រះសាលាដំបូងបានស្ដាប់ភស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់រួចមកហើយ អំពីការលុបបំបាត់ព្រះពុទ្ធសាសនា ដែលជាសាសនាចម្បងនៅក្នុងសង្គមកម្ពុជានៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ។ ពាក់ព័ន្ធនឹងការហាមឃាត់ពុទ្ធសាសនា អង្គជំនុំជម្រះសាលាដំបូងបានទទួលអង្គហេតុជាក់លាក់ ដែលអាចចាត់ទុកជាការធ្វើការទុក្ខបុកម្នេញសាសនានៅសហករណ៍ត្រាំកក់។

ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានផ្ដល់ភស្តុតាងផងដែរ អំពីការធ្វើទុក្ខបុកម្នេញសំដៅប្រឆាំងពុទ្ធសាសនិក ជាពិសេសអំពីការកំណត់គោលបំណងនៃការប្រើប្រាស់វត្តឡើងវិញ និងការបំផ្លិចបំផ្លាញវត្ត។

ដើមបណ្ដឹងរដ្ឋប្បវេណី ប៊ុន សារឿន មានអាយុ១១ឆ្នាំនៅឆ្នាំ១៩៧៥ ដែលគេផ្លាស់ទីលំនៅគាត់ទៅភូមិត្រពាំងថែង ហើយគាត់ត្រូវបានគេបំបែកចេញពីឪពុកម្ដាយ ដើម្បីដាក់បញ្ចូលក្នុងកងកុមារ។ គាត់បានផ្ដល់សក្ខីកម្មថា ព្រះសង្ឃវត្តជិតសហករណ៍ត្រពាំងថែង ត្រូវបានគេយកចេញទៅបាត់ រួមទាំងបង និងពូរបស់គាត់។ គាត់បានរៀបរាប់ស្ថានភាពនៃវត្តដូចមានបង្ហាញក្នុងវីដេអូ។ សូមបង្ហាញវីដេអូរបស់ ប៊ុន សារឿន លេខ៥។

[១០:៤៧:៣៦]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"រឿងអារម្មណ៍ខ្ញុំ វានឹកឃើញថាវាសោកស្ដាយដែរ កន្លែងធ្លាប់បូជា កន្លែងគោរព ទាល់តែទៅអត់មានលោក គ្មានមានអីអ៊ីចឹង ដឹងជាថាវាពិបាក ធ្លាប់មានបុណ្យមានទាន ដល់ពេលអត់មានបុណ្យមានទានអ៊ីចឹង ខ្ញុំក៏វាពិបាក។ ការនឹងគោរពបូជា វាដូចថាវាគ្មានអីទីពឹងអីទាំងអស់។ វាសាសនាក៏វាអស់ណាមួយទៅវាបាត់បង់គោរពបូជា ដឹងទៅធ្វើស្អីនៅកន្លែងណាកើត វាមិនដែលជួបប្រទះ វាមិនដែលឃើញ។ ទើបតែបានជំនាន់ហ្នឹងបានខ្ញុំឃើញ របៀបរបបហ្នឹង វាដូចជាវាអស្ចារ្យពេកហើយ។ ព្រះអង្គនៅហ្នឹង បើគិតទៅលោកវាមាន១៥អង្គ តែ១៥អង្គទាំងលោកបង ហើយលោកពូខ្ញុំ។ តែមិនដឹងជាយកទៅខាងណា ព្រោះបាត់ទាំងអស់ហើយ អត់មានឃើញ។ ទៅដល់នៅសល់តែវត្ត កុដិអីវិនអត់មានឃើញទេ កុដិឈើបាត់អស់ នៅសល់តែកុដិថ្ម។ មិនដឹងជាគេយកទៅខាងណាខាងណី។ ហើយវិហារហ្នឹងឃើញចាក់សោ។"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១០:៤៨:៤៧]

ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡន បានបន្ថែមថា វត្តបានក្លាយជាកន្លែងឃុំឃាំងមនុស្សដែលមិនដឹងអី។ វត្តមួយនៅលាយបូរ បានក្លាយជាកន្លែងថែក្មេង ហើយអ្នកទោសក៏ត្រូវបានទុកនៅទីនោះដែរ។ ចំណែកដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានសម្រាលកូននៅក្នុងវត្ត ដែលខ្មែរក្រហមរៀបធ្វើជាមន្ទីរពេទ្យ។

ជាបន្តទៅនេះ ខ្ញុំលើកឡើងពីសោកនាដកម្មនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់។ នៅក្នុងសហករណ៍ត្រាំកក់ មានគុកធំមួយហៅថា មន្ទីរសន្តិសុខក្រាំងតាចាន់។ អស់លោក លោកស្រីចៅក្រមដឹងហើយថា មន្ទីរសន្តិសុខក្រាំងតាចាន់មិនមែនកើតឡើងដោយឯកឯង ឬគ្មានហេតុផលនោះឡើយ។ ហេតុការណ៍ដែលបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខនេះ ច្បាស់ណាស់ គឺកើតចេញពីគោលនយោបាយនៃការកម្ទេចខ្មាំង ដែលត្រូវបានផ្សព្វផ្សាយតាមរចនាសម្ព័ន្ធ ដែលបានរៀបចំយ៉ាងល្អដោយបក្សកុម្មុយនីស្តកម្ពុជា ហើយខ្ញុំនឹងធ្វើការបង្ហាញនូវភស្តុតាង និងឧក្រិដ្ឋកម្ម ដែលនាំឲ្យមានការកាប់សម្លាប់ ការឃុំខ្លួន ការធ្វើទារុណកម្មនៅក្នុងមន្ទីរសន្តិសុខនេះតាមអង្គហេតុជាក់ស្ដែងរបស់ជនរងគ្រោះ ដែលបានមកធ្វើសក្ខីកម្មនៅទីនេះ។

[១០:៥០:០៧]

ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីរនាក់ឈ្មោះ សយ សែន និង សូត្រ សាំង បានផ្ដល់សក្ខីកម្មអំពីហេតុការណ៍ដែលពួកគាត់ជួបប្រទះផ្ទាល់នៅមន្ទីរសន្តិសុខ។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបួននាក់ ប៊ុន សារឿន, អ៊ុង សារឿន, រី ពៅ និង អ៊ូ ដាវ បានផ្ដល់សក្ខីកម្មអំពីសមាជិកគ្រួសារនិងមិត្តភក្តិរបស់ពួកគាត់ ដែលត្រូវបានគេយកចេញទៅមន្ទីរសន្តិសុខក្រាំងតាចាន់។ ជនរងគ្រោះដែលជាអ្នកទោសនៅក្រាំងតាចាន់ ត្រូវបានដកហូតទាំងស្រុងនូវសិទ្ធិសេរីភាព ដោយពុំមានការកាត់សេចក្ដីស្វែងរកភាពខុសនិងត្រូវណាមួយឡើយ។ អ្នកដែលត្រូវជាប់សង្ស័យថាជាខ្មាំងរបស់អង្គការត្រូវបានចាប់មកឃុំនៅទីនេះ ដែលមានទាំងកុមារនិងទារកផងដែរ តាមការធ្វើសក្ខីកម្មរបស់ សូត្រ សាំង។

ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ត្រូវបានគេឃុំខ្លួននៅមន្ទីរសន្តិសុខក្រាំងតាចាន់ពីឆ្នាំ៧៤ រហូតដល់ដួលរលំ -- រហូតដល់ការដួលរលំនៃរបបខ្មែរក្រហម ដោយសារតែឪពុករបស់គាត់ធ្លាប់ធ្វើជាមេស្រុកជំនាន់លន់ នល់ និងជំនាន់សម្ដេច សីហនុ ដែលគេចាត់ទុកថាជាពួកសក្តិភូមិ នាយទុន។ ពាក់ព័ន្ធ

នឹងលក្ខខណ្ឌនៃការឃុំខ្លួន សយ សែន បាននិយាយថា សូមដកស្រង់៖ “បញ្ជាក់ពីប្រវត្តិរូបរបស់ខ្ញុំអាចបញ្ជាក់បាន។ កាលពីដើមខ្ញុំនៅក្មេង ខ្ញុំមិនអាចចាំបានពីរឿងបញ្ហាមូលហេតុដែលរឿងរ៉ាវខ្ញុំមិនអាចដឹង ប៉ុន្តែតាមខ្ញុំស្មានទៅគឺថា រឿងខ្ញុំវាពាក់ព័ន្ធនឹងឪពុកធ្វើមេស្រុកជំនាន់លន់ នល់ និងសម្តេច សីហនុ -- និងជំនាន់សម្តេច សីហនុ។ ហើយពាក់ព័ន្ធតែប៉ុណ្ណឹងរឿងខ្ញុំ អត់ដែលមានរឿងហេតុអ្វីពីបញ្ហាណាមួយក៏អត់មាន មានពាក់ព័ន្ធដែលហៅថាជំនាន់ហ្នឹងគេរើសប្រវត្តិរូបថាសក្តិភូមិ និងនាយទុន។ គេនិយាយពីសក្តិភូមិនិងនាយទុនជំនាន់នោះ។” សូមបិទការដកស្រង់។

[១០:៥២:០៣]

ពាក់ព័ន្ធនឹងស្ថានភាពឃុំខ្លួន ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា សូមដកស្រង់៖ “បាទ អ៊ីចឹងមែន កាលណាអ្នកទោសធ្ងន់ ឬមិនដឹងថាធ្ងន់ ឬក៏ស្រាល នាំមកដល់ដំបូងគេដាក់ខ្នោះជើងទាំងពីរ ដាក់ជើងទាំងពីរហើយ គេដាក់ដៃពីលើទៀត ដាក់រនុកដែកលើនេះមួយទៀត” សូមបិទការដកស្រង់។ អ្នកទោសទាំងអស់មានទាំងប្រជាជនចាស់ ប្រជាជនថ្មី អតីតមន្ត្រីរដ្ឋការនៃរបបចាស់ ដែលរយៈពេលនៃការឃុំខ្លួននៃអ្នកទោស មិនដូចគ្នានោះឡើយ អាស្រ័យទៅលើប្រភេទរបស់អ្នកទោស។

តាមការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីដដែលថា សូមដកស្រង់៖ “បាទ មានអ្នកទោសដែលជាប់ហ្នឹងដូចខ្ញុំអ៊ីចឹង ជាប្រជាជនមូលដ្ឋាន។ កាលណាមូលដ្ឋានជាប់បានយូរ បើថា១៧មេសាវិញជាប់អត់បានយូរទេ ជួនកាលយកទៅដល់អ៊ីចឹង ជាពិសេសអ្នកល្បីៗឈ្មោះអ៊ីចឹង យកទៅល្ងាច ល្ងាចបន្តិចគេយកទៅសម្លាប់ចោលហើយ។ ឧទាហរណ៍ដូចតួកុនលោកស្រី គឹម ណូរ៉ា, លោក ណុប ណែម ជាដើម។”

ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មបន្ថែមថា ក្រោយពេលឃុំខ្លួនគាត់បានមួយខែ គាត់ត្រូវបានគេឲ្យទៅធ្វើការនៅខាងក្រៅអគារគុក។ សេនារីយ៉ូនេះ គឺជាបញ្ហាចម្បងសម្រាប់អង្គជំនុំជម្រះសាលាដំបូង ពោលគឺនៅពេលអ្នកទោសត្រូវបានគេអនុញ្ញាតឲ្យធ្វើការងារនៅក្នុងបរិវេណខាងក្រៅមន្ទីរឃុំឃាំង តើពួកគេមានឋានៈអ្វី?

[១០:៥៣:៣៩]

អង្គជំនុំជម្រះសាលាដំបូង បានទទួលសំណួរស្រដៀងគ្នាមួយចំពោះអ្នកទោសដែលត្រូវបានអនុញ្ញាតឲ្យនៅ -- ឲ្យធ្វើការងារនៅស-២១។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា អំពើដាក់ឲ្យទៅជាទាសករត្រូវបានកំណត់ជាបទឧក្រិដ្ឋនៅក្នុងករណីនោះ។ យើង

ជឿជាក់ថា វិធីសាស្ត្រស្រដៀងគ្នាត្រូវបានអនុវត្តតាមចំពោះមន្ទីរសន្តិសុខក្រាំងតាចាន់នេះដែរ។ សយ សែន បានបន្តទៀតថា សូមដកស្រង់៖ "គេព្រលែងខ្ញុំឲ្យចេញធ្វើការខាងក្រៅ គេឃើញថាខ្ញុំនៅក្មេងជាងគេ ហើយម៉្យាងគេពន្យល់ប្រាប់ខ្ញុំថា អ្អែងនៅមាត់ឲ្យស្ងៀម អ្អែងគេទុកឲ្យរស់ហើយ បើអ្អែងមាត់អត់ស្ងៀមទេ អត់មានមាត់រអេចរអូច មាត់ដាចពីនេះពីនោះទេ អត់ទេ អ្អែងមាត់ឲ្យស្ងៀម អញទុកឲ្យរស់។ គេលែងខ្ញុំធ្វើការនៅក្នុងហ្នឹង ឲ្យមើលក្របី។ មើលក្របីរួច គេឲ្យទៅកាប់រណ្ដៅសម្រាប់សពហើយនិងខ្មោចស្លាប់នៅក្នុងគុក គេវ៉ៃសួរចម្លើយបង្អត់បាយនៅក្នុងគុកហ្នឹង កាលណាស្លាប់ហើយគេហូតខ្នោះចេញ ហើយខ្ញុំសែងយកទៅដាក់កប់តាមជួររបង។ កប់ហើយដាក់ដាំដូងពីលើជាមួយ តាចិនពីរនាក់ តាចិន ហ្នឹងឯង។"

តាមរយៈសក្ខីកម្មនេះបង្ហាញថាអ្នកទោសមួយចំនួនត្រូវបានបញ្ចេញឲ្យមកធ្វើការខាងក្រៅអគារគុក ដោយមានការឃ្លាំងមើលពីអ្នកយាម។ ដូចនឹងករណីឪពុករបស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៊ុន សារឿន ដែលបានឃើញឪពុកគាត់ផ្ទាល់ភ្នែកនៅក្នុងបរិវេណក្រាំងតាចាន់។ គាត់ស្លៀកខោខ្លី មានរូបរាងស្គមស្គាំងមើលសឹងតែមិនស្គាល់ កំពុងតែរែកទឹកស្រោចបន្លែ។ ឪពុករបស់ដើមបណ្ដឹងនេះ គឺជាអតីតអ្នកធ្វើការជាមួយប្រធានភូមិ។ ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បាននិយាយរៀបរាប់ថា អ្នកជាប់ឃុំត្រូវបានគេសួរចម្លើយ ដោយមានការធ្វើទារុណកម្មធ្ងន់ធ្ងរនៅមន្ទីរសន្តិសុខក្រាំងតាចាន់។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មបន្តទៀតថា សូមដកស្រង់៖ "មិនអាចកំណត់បានទេ អ្នកស្លាប់។ អ្នកមកថ្មីអ៊ីចឹង គេយកទៅវ៉ៃសួរចម្លើយ។ វ៉ៃសួរចម្លើយហើយ មកកន្លែងអត់រួច ខ្ញុំទៅគ្រាពីកន្លែងសួរចម្លើយយកមកដាក់នៅកន្លែងគុក ហើយបើគ្រាមិនរួច ក៏សែងមកអ៊ីចឹងទៅ។ វ៉ៃសួរចម្លើយ ទារុណកម្មប៉ុណ្ណឹងហើយ យកមកដាក់ខ្នោះដៃខ្នោះជើងទាំងពីរវិញដដែល។ ប៉ុន្តែបាយគេអត់ឲ្យហូបទេ អត់ដួសបាយឲ្យទេ បបរក៏អត់ដែរ សម្រាប់អ្នកដែលគេចោទថាទោសក្បត់ជាតិ។ ជំនាន់ហ្នឹង គេហៅថាទោសក្បត់ជាតិអត់ឲ្យបាយហូបទេ។" សូមបិទការដងស្រង់។

[១០:៥៦:៤០]

ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង បានរៀបរាប់អំពីសម្រែកនៃការឈឺចាប់របស់អ្នកទោសដែលត្រូវបានគេសួរចម្លើយថា សូមដកស្រង់៖ "ក្នុងសម្រែកបងប្អូនអ្នកទោស ខ្ញុំរស់នៅទីហ្នឹង ពិតជាឮច្បាស់ហើយ។ ឮដោយសារគេវ៉ៃសួរចម្លើយ ជាក់ស្ដែងតែម្ដង" សូមបិទការដកស្រង់។ ដោយសារលក្ខខណ្ឌរស់នៅ របៀបនៃការឃុំខ្លួន ការផ្ដាច់របបហូបចុក បានធ្វើឲ្យអ្នកទោសស្លាប់ច្រើននៅក្នុង

គុក។ តាមការបង្ហាញរបស់លោក សយ សែន ដូចមាននៅក្នុងសេចក្ដីដកស្រង់ សូមកស្រង់៖ "គេដាក់ខ្នោះដៃ ខ្នោះជើងទាំងពីរវិញដដែល។ ប៉ុន្តែបាយ គេអត់ឲ្យហូបទេ អត់ដួសបាយឲ្យទេ បបរក៏អត់ឲ្យដែរ។ អ្នកដែលគេហៅថា ទោសក្បត់ជាតិ។ ជំនាន់ហ្នឹង គេអត់ឲ្យបាយហូបទេ។ ទៅដល់ គេដាក់ខ្នោះចោលហ្នឹង ចេះតែចោលទៅ ចោលទាល់យប់ ចោលទាល់ព្រឹក រហូត។ បើមនុស្សប្រុសវិញ អត់បាយអត់ទឹក បាន១៨ថ្ងៃ គឺស្លាប់។ ខ្ញុំអត់បានរាប់ទេ តែខ្ញុំកាច់ខ្ចាច់ស្លឹកត្នោត។ មួយថ្ងៃកាច់ស្លឹកត្នោតមួយសន្លឹក។ កាច់មួយកំណាត់ដាក់ចោលនៅក្បែរកន្លែងដេក ខ្ញុំដេក។ ដល់ស្អែកឡើង កាច់មួយស្លឹកទៀត ខ្ញុំរាប់មើល ១៨ថ្ងៃគត់ គឺដាច់ខ្យល់ម៉ាត់។ គេឲ្យខ្ញុំយកចេញ។ យកសពហ្នឹងទៅទុកដាក់ ហើយលុបនិងកប់ដី។" សូមបិទការដកស្រង់។

[១០:៥៨:១០]

ចំពោះអ្នកទោសដែលត្រូវបានគេសួរចម្លើយ ទោះបីជាពួកគេមិនបានយកទៅសម្លាប់ក៏ដោយ ក៏មិនអាចទ្រាំទ្ររស់ចំពោះការឈឺចាប់ និងអត់ឃ្លានបានឡើយ។ តាមការរៀបរាប់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន។ សូមលើកការដកស្រង់៖ "អ្នកដែលគេដាក់គុក និងវ៉ៃសួរចម្លើយ។ ទារុណកម្មមិនអាចរត់រួចលើសពីមួយខែទេក្នុងម្នាក់។ ព្រោះគេអត់ឲ្យអីហូបទាំងអស់ អត់មានអីទាំងអស់។ គេដាក់ខ្នោះចោលតែម្ដង។" សូមបិទការដកស្រង់។

ចំពោះអ្នកទោសដែលមានជំងឺ ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង បានបញ្ជាក់ផងដែរថា សូមលើកការដកស្រង់៖ "អ្នកទោសដែលត្រូវឃុំខ្លួននៅទីនោះ គាត់មិនដែលបានឃើញថា បានទទួលការព្យាបាលឡើយ"។ សូមបិទការដកស្រង់។

ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ក៏សាក្សីផ្ទាល់ភ្នែកយ៉ាងសំខាន់ផងដែរ ដែលបានដឹងពីការសម្លាប់អ្នកទោសនៅមន្ទីរក្រាំងតាចាន់។ សូមបង្ហាញវីដេអូ លោក សយ សែន លេខ៦។

[១០:៥៩:១៤]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"មុននឹងយកមនុស្សទៅសម្លាប់ គឺទៅដល់គេបើកទ្វារ បើកទ្វារគុកហ្នឹង គេប្រាប់ថា ឥឡូវបើកទ្វារគុកហ្នឹង គេប្រាប់ថា បងប្អូនទាំងអស់បានរួចទៅតាមសហករណ៍វិញហើយ បើអ៊ីចឹង យើងត្រូវនឹងគោរពនឹងផែនការ និងអង្គការ ប៉ុន្តែមិនបានទៅអស់គ្នាទេ បានទៅមួយចំនួន។ ប៉ុន្តែគាត់យកក្រដាសមួយមក សម្រាប់មើលបញ្ជី។ ដល់ផ្សាយប្រាប់គាត់ ធ្វើនាមក្នុងនាមនយោបាយ គាត់ថាបើបានរួចទៅ*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាមសហករណ៍វិញ ហ្នឹងយើងគោរពនឹងអង្គការ គោរពនឹងផែនការអង្គការ កុំខ្វាស់នឹងកង់ប្រវត្តិសាស្ត្ររបស់អង្គការ យើងគោរពនឹងអង្គការ។ ដល់គាត់ហៅឈ្មោះម្តងពីរ។ ហៅឈ្មោះម្តងពីរៗ ទៅហូតខ្នោះ ហូតខ្នោះចេញខ្វាច់ ឈ្មោះនេះ ឧទាហរណ៍ថាឈ្មោះ "ក" ឈ្មោះ "ខ" អ៊ីចឹង ចេញមកក្រៅមកដល់ដើរចេញមកក្រៅ ហួសកន្លែងគុកហ្នឹង ហួសមកដល់ខាងត្បូងបន្តិច មានព្រៃដំឡូងមី ព្រៃដំឡូងមីដល់មានកងទ័ពនៅចាំហ្នឹងពីរនាក់។ ចាំហ្នឹងពីរនាក់ ដល់នេះថា ហ៊ឺ!យើងបាន បានរួចទៅតាមសហករណ៍វិញ យើង ជួបនឹងអង្គការ សុំចងដៃ ចងដៃហើយចងមុខ។ ស្រាប់តែហួសកន្លែងដែលគុកហ្នឹងឆ្ងាយបន្តិចដែរ ដីប្រហែលជាអាច១០ម៉ែត្រ សុំចងដៃចងមុខថា ហេតុខ្ញុំត្រូវចងដៃចងមុខ មិនឲ្យនឹងឃើញនឹងអង្គការ គុំក្លួនជាមួយអង្គការ។ គាត់បណ្តើរទៅដល់ គាត់ឲ្យអង្គុយ អង្គុយហើយគាត់វ៉ៃនឹងត្បូងចប ត្បូងចបពីក្រោយហើយ គាត់ធាក់ប្រមៀល –ខ្ញុំបានមានប្រសាសន៍ពីមុនមកហើយថា– ធាក់ប្រមៀលហើយ ដែលប្រុសៗនឹងចាស់ៗគេអាចយកដាវមួយ ហើយដាវវែងៗផ្តែប្រហែលជាអាចជា៤តឹក និង៥តឹកផ្តែដាវហ្នឹង។ វ៉ៃពីក្រោយហើយ យកដាវកាត់បំពង់ក ហើយកាត់បំពង់កហើយ អូសទម្លាក់រណ្តៅហើយស្រាតខោអាវចេញទាំងអស់។ ខោអាវមិនថាស្ត្រីមិនថាបុរស ស្រាតទុកគរមួយកន្លែង។ បាទ ស្រាតទុកគរមួយកន្លែងហ្នឹង បោះគរហ្នឹង តែពេលវ៉ៃមួយថ្ងៃហ្នឹង វ៉ៃចប់ថ្ងៃហ្នឹងអ៊ីចឹង ថ្ងៃល្ងាចឡើងគាត់ឲ្យខ្ញុំទៅប្រមូលខោអាវ និងខោអាវយកទៅត្លុក ត្លុកយកទៅទុកចោលនៅត្រពាំងលិចខាងលិច មានត្រពាំងភូមិមួយខាងលិចមួយទៀត យកទៅគរចោលហ្នឹង។ បានហាលទុកចោលហ្នឹងពីរបីថ្ងៃបានប្រមូលខោអាវហ្នឹងដាក់ យកមកដាក់ក្នុងឃ្លាំង ឃ្លាំងជិតកន្លែងសួរចម្លើយហ្នឹង។ ប្រមូលទុកដាក់បានយូរបន្តិច បានមានឡានឡង់រ៉ូវែរ គាត់ដឹកចេញទៅចែកតាមសហករណ៍។"

(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)

[១១:០១:២៨]

លោកប្រធាន លោក លោកស្រីចៅក្រម សោកនាដកម្មទាំងអស់ដែលបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសហករណ៍ត្រាំកក់ ដូចបង្ហាញតាមភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពិតជាកើតចេញពីការអនុវត្តតាមផែនការរៀបទុកជាមុនរបស់ជនជាប់ចោទ នួន ជា, ខៀវ សំផន និងបក្សពួក។ ហើយឧក្រិដ្ឋកម្មស្រដៀងគ្នានេះ ក៏បានកើតឡើងនៅក្នុងទីតាំងឧក្រិដ្ឋកម្មផ្សេងទៀត ដែលសហភាគារបស់ខ្ញុំនឹងធ្វើការបង្ហាញជូនអង្គជំនុំជម្រះបន្តទៀត។

សូមអរគុណលោកប្រធាន។ សូមអញ្ជើញ -- សូមលោកប្រធាន សូមអនុញ្ញាតឲ្យសហភាគាខ្ញុំ

បន្ត។

**ប្រធានអង្គជំនុំ៖**

បាទៗ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១១:០២:២៩]

**លោក ហុង គីមសួន៖**

សូមអរគុណបាទ។

ខ្ញុំបាទ ហុង គីមសួន ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី នៃក្រុមអង្គការ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ហៅកាត់ថា ស៊ី.ឌី.ភី។ សូមគោរពលោកប្រធាន លោកស្រី លោកចៅក្រមជំនុំជម្រះជាទីគោរព និងសាធារណជនទាំងអស់ជាទីគោរព។ ខ្ញុំបាទនឹងធ្វើសេចក្ដីថ្លែងការណ៍ទាក់ទងទៅនឹងប្រធានបទ មន្ទីរសន្តិសុខមួយចំនួន និងការបោសសម្អាតផ្ទៃក្នុងដូចតទៅ។ ទាក់ទងនឹងមន្ទីរសន្តិសុខ មន្ទីរសន្តិសុខជាច្រើនត្រូវបានបង្កើត និងដាក់ឱ្យដំណើរការនៅទូទាំងប្រទេសកម្ពុជា។ ជិតការចាប់ផ្ដើមរបបកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានដំណើរការរហូតដល់របបនេះបានដួលរលំ។ អង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្ដឹងពីអង្គហេតុពាក់ព័ន្ធនឹងមន្ទីរសន្តិសុខចំនួនបួន គឺមន្ទីរសន្តិសុខស-២១ ឬសព្វថ្ងៃនេះគេហៅថា គុកទួលស្លែង មន្ទីរសន្តិសុខភ្នំក្រោល មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលបានពិភាក្សាតាំងពីពេលមុនពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ ដែលសហភាតាបានលើកឡើងអម្បាញ់មិញ។ ដីកាដំណោះស្រាយដែលបានប្ដឹងទៅកាន់អង្គជំនុំជម្រះបានបញ្ជាក់ថា កម្មវត្ថុក្នុងការបង្កើត និងដាក់ឱ្យដំណើរការមន្ទីរសន្តិសុខទាំងនោះ គឺដើម្បីអនុវត្តនិងការពារបដិវត្តន៍សង្គមនិយម គឺការលត់ដំនៅសមាសភាពមិនល្អ និងការសម្លាប់ខ្មាំង ទាំងនៅក្នុងជួរបក្ស និងក្រៅជួរបក្ស តាមគ្រប់មធ្យោបាយដូចមានចែងនៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌលេខ១៧៨ ដល់ ១៧៩។

អង្គជំនុំជម្រះសាលាដំបូង ជាដំបូងនឹងកំណត់ថា តើអង្គហេតុទាំងនោះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអំពើការដាក់ក្នុងពន្ធនាគារ ការដាក់ឱ្យទៅជាទាសករ មនុស្សឃាត ការសម្លាប់រង្គាល ការដាក់នៅក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និង/ឬ អំពើអមនុស្សធម៌ផ្សេងទៀត ដែលកើតឡើងនៅក្នុងមន្ទីរសន្តិ-សុខក្នុងសំណុំរឿង០០២/០២ ឬយ៉ាងណា។ ហើយទី២ អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែកំណត់ថា តើជនជាប់ចោទនឹងត្រូវទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងនោះឬយ៉ាងណាដែរ។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន២៩៦នាក់ ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋាននៃបទឧក្រិដ្ឋ ដែលបានចោទប្រកាន់នៅតាម

មន្ទីរសន្តិសុខ និងវាលពិឃាត។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីរនាក់ បានផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល និងមន្ទីរក-១១ ស្ថិតនៅខេត្តមណ្ឌលគិរី។ និងដើមបណ្ដឹងរដ្ឋប្បវេណីចំនួន១០នាក់ទៀតបានផ្ដល់សក្ខីកម្មពាក់ព័ន្ធមន្ទីរសន្តិសុខស-២១។ គ្មានដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់បានធ្វើសក្ខីកម្មពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែងនោះទេ ទោះបីជាឯកសារជាច្រើនត្រូវបានបង្ហាញក្នុងអំឡុងសវនាការលើឯកសារកន្លឹះនោះក៏ដោយ។

[១១:០៥:៣៥]

អំពីមន្ទីរសន្តិសុខភ្នំក្រោលនៅស្រុកកោះញែក ខេត្តមណ្ឌលគិរី។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីរនាក់គឺលោក សុន វុត និងលោក កុល ណែម បានផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល និងមន្ទីរក-១១។ ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត គឺជាជនរងគ្រោះដោយផ្ទាល់ពីអំពើទារុណកម្ម និងការដាក់ក្នុងពន្ធនាគារនៅមន្ទីរសន្តិសុខភ្នំក្រោល និងបានផ្ដល់សក្ខីកម្មអំពីព្យសនកម្មដែលពួកគេបានទទួលរង។ ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត រូបនេះបានចូលបម្រើកងទ័ពខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៥ គឺបន្ទាប់ពីថ្ងៃរំដោះក្រុងភ្នំពេញ១៧ មេសា ១៩៧៥។ ដើមបណ្ដឹងរូបនេះបានពន្យល់ថា អង្គការបានបញ្ជូនកងពលរបស់លោក គឺកងពល៩២០ ទៅការពារព្រំដែនទប់ទល់វៀតណាមនៅស្រុកកោះញែក ខេត្តមណ្ឌលគិរី។ បន្ទាប់មកដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានតែងតាំងជាប្រធានកងអនុសេនាធំ។ នៅពេល សុន វុត បញ្ឈរជើងនៅខេត្តមណ្ឌលគិរី ថ្នាក់ដឹកនាំរបស់គាត់ ក៏ត្រូវបានអង្គការហៅទៅរៀនសូត្រ ហើយឮថាពួកគេត្រូវបានគេសម្លាប់ដោយចោទថាក្បត់អង្គការ។ ពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ១៩៧៧ នៅរដូវច្រូតកាត់ ដើមបណ្ដឹងរដ្ឋប្បវេណីក៏ត្រូវបានគេចាប់ខ្លួន និងយកទៅឃុំខ្លួនដោយចោទថាក្បត់អង្គការផងដែរ។ គាត់ត្រូវបានគេឃុំឃាំងនៅមន្ទីរសន្តិសុខភ្នំក្រោលពី ៣ទៅ៦ខែ ដោយគាត់ត្រូវបានគេសួរចម្លើយ ឆក់ខ្សែភ្លើង និងវាយដំធ្វើទារុណកម្មយកចម្លើយ។ គាត់បានពិពណ៌នា សូមដកស្រង់សម្ដីរបស់គាត់៖ "ដែលគេហៅខ្ញុំទៅ ក៏គេយកទៅកន្លែងខ្ទមនោះឯង កន្លែងខ្ទមសម្ងាត់នោះបាទ។ សួរចម្លើយមុនដំបូងគេដាក់ឆក់ខ្សែភ្លើងបាទ ឆក់ខ្សែភ្លើងខ្ញុំ ក៏ខ្ញុំវាដូចជាថាបាត់ស្មារតីអស់ ហើយឲ្យខ្ញុំឆ្លើយ ៗថាខ្ញុំមិនឆ្លើយទៅ គេឆក់ទៀត។ ដល់ឆក់ទៅ ខ្ញុំដូចថាវាសន្លប់ គឺអត់ដឹងខ្លួនផង វាដូចថា ដឹងថាខ្លួនស្លាប់តែប៉ុណ្ណឹងឯង។ ដល់ខ្ញុំដឹងខ្លួនប៉ាច់ វាសួរទៀត វាឈប់ឆក់ តែគេវ៉ៃបណ្ដោយ គេវ៉ៃ។ វាឆក់ទៅ ខ្លាចខ្ញុំមិនបានឆ្លើយសំណួរឲ្យបានឲ្យគេបានអស់ គេក៏ឈប់ឆក់ គេវ៉ៃ ដល់វ៉ៃវាអាចឆ្លើយបាន។" សូមបិទសម្រង់។

ដើមបណ្ដឹងរូបនេះបានបរិយាយដូចមានការបញ្ចាំងវីដេអូតទៅនេះ សូមបញ្ចាំងវីដេអូ លេខ១។

[១១:០៨:២០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"បាទ ដែលវ៉ៃខ្ញុំនោះគឺដំបងយើងគឺវាធំដែរ ធំប៉ុនកដៃ កំភួនដៃនេះគឺវ៉ៃ បាទ។ វ៉ៃល្មមតែយើងពីរបីដំបង ក៏វាបាត់ស្មារតី ដឹងខ្លួនវាសន្លប់ ខ្ញុំសន្លប់ វាវ៉ៃម្តងក៏សន្លប់ ពីរដងក៏សន្លប់ៗក៏វាមិនបានយូរ វាចាប់កន្ត្រាក់ វាសួរចម្លើយទៀត ក៏អាចដឹងខ្លួនមួយភ្លែតទៅវិញទៅបាទ។ ដល់ខ្ញុំមិនឆ្លើយទៅ វាវ៉ៃផ្តាច់ទៀត វាវ៉ៃយកងាប់ អញដាក់អ្នែងឲ្យងាប់ គេថា មិនបាច់ឆ្លើយក៏ហីទៅ វ៉ៃអ្នែងឲ្យងាប់តែម្តង។ ខ្ញុំក៏អត់ដឹងដែរ ក៏វាវ៉ៃខ្លាំងទៅ វាចូលអាបាត់បង់សតិវិញ្ញាណទៅ សន្លប់បានដឹងអីនឹងៗឆ្លើយ នឹងនិយាយកើត វាអស់បាទ ដំបងធំៗបាទ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:០៩:១៥]

បាទ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏បានពន្យល់ពីផលប៉ះពាល់នៃការចាប់ខ្លួន និងការធ្វើទារុណកម្មមកលើគ្រួសារគាត់ផងដែរ សូមដកស្រង់៖ "ក៏នឹកឃើញថាឈឺចាប់ដែរ ខ្ញុំខំតស៊ូដើម្បីការពារប្រទេសជាតិ បម្រើបក្ស បម្រើអង្គការ ប៉ុន្តែអង្គការមកចោទប្រកាន់ មើលមួយពូជខ្ញុំស្លាប់អស់ ចុះបើខ្ញុំធ្វើការសម្រាប់ការពារប្រទេសជាតិ ហើយឲ្យវ៉ៃបងប្អូនម៉ែឪចោល ចុះតើខ្ញុំជាអ្នកបម្រើអង្គការទៅការពារព្រំដែននោះវាចិត្តល្អប៉ុនណា ខ្ញុំវាឈឺចាប់របៀបម៉េច។ បាទ ខ្ញុំវាអន់ចិត្តណាស់សព្វថ្ងៃ តែកាលណាឮគេនិយាយ ខ្ញុំចង់តែអួលដើមក។" សូមបិទសម្រង់។

ទាក់ទងជាមួយនឹងមន្ទីរសន្តិសុខមួយនៅកណ្តាលក្រុងភ្នំពេញ ដែលជាមន្ទីរសន្តិសុខគេហៅថាមន្ទីរសន្តិសុខស-២១ ឬសព្វថ្ងៃហៅថា "គុកទួលស្លែង"វិញ។ ករណីសំណុំរឿង ០០២/០២ វគ្គមន្ទីរសន្តិសុខស-២១ មិនមែនចម្រុះដែលទៅនឹងសំណុំរឿង០០១ នោះទេ។ យើងឃើញមានដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជា១១៤នាក់ ដែលមានសាច់ញាតិ ឬមិត្តភក្តិត្រូវបានគេឃុំឃាំង ឬសម្លាប់ចោលនៅស-២១ដូចបានគូសបញ្ជាក់នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញរបស់យើងខ្ញុំ តាមរយៈការវិភាគលើឯកសារនាសម័យខ្មែរក្រហមនោះ នៅក្នុងសំណុំរឿង។ យើងជឿជាក់ថា ករណីរបស់បុគ្គលនីមួយៗនឹងជួយដល់អង្គជំនុំជម្រះក្នុងការកំណត់ពីឧក្រិដ្ឋកម្មនៃការអនុវត្ត និងការសម្លាប់នៅមន្ទីរសន្តិសុខស-២១។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១០នាក់ បានផ្តល់សក្ខីកម្មអំពីបទឧក្រិដ្ឋនៅមន្ទីរសន្តិសុខស-២១ ដូចជាលោក ជុំ ម៉ី ដែលជាជនរងគ្រោះដោយផ្ទាល់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំបីនាក់ទៀត ដូចជា

លោក ផែ ប៉ាប, ភួង យ៉ាត, រស់ ជួរស៊ីអ៊ី, កាន់ សុន្ទរ៉ា, ចៅ ឃឹម, ខៀវ នាប, អ៊ុំ សុផានី និងដើមបណ្ដឹងរដ្ឋប្បវេណី សុន អែម ជាដើម។ បានផ្ដល់សក្ខីកម្មអំពីព្យសនកម្មដោយប្រយោល ដែលពួកគាត់បានទទួលរង ដែលបានកើតចេញពីមរណភាពនៃអ្នកជាទីស្រឡាញ់របស់ពួកគេនៅមន្ទីរសន្តិសុខស-២១។

[១១:១១:៤១]

ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានផ្ដល់សក្ខីកម្មថា ពួកគេត្រូវបានគេធ្វើបាប និងបន្តឈឺចាប់ដោយសារតែការបាត់បង់ទ្រព្យសម្បត្តិ ដែលបានរឹបអូសក្នុងរបបខ្មែរក្រហមនោះផងដែរ។ ជនរងគ្រោះដោយផ្ទាល់ពីមន្ទីរសន្តិសុខស-២១ គឺលោក ជុំ ម៉ី ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៨ ពីកងជួសជុលម៉ាស៊ីន ដែលគាត់ជាសមាជិកក្រុមជាងសហជីព។ ប្រពន្ធ និងកូនស្រីរបស់គាត់មិនបានដឹងពីការចាប់ខ្លួនគាត់ទេ ឬពីការបញ្ជូនគាត់ទៅមន្ទីរសន្តិសុខស-២១ឡើយ។ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ត្រូវបានគេចាប់ដាក់គុក និងវាយដំធ្វើទារុណកម្មសួរចម្លើយអស់រយៈពេល១២ថ្ងៃ នៅពេលដែលពួកយោធាសន្តិសុខត្រូវការជាងជួសជុលគ្រឿងម៉ាស៊ីន ពេលនោះហើយដែលស្ថានភាពរបស់គាត់ត្រូវបានផ្លាស់ប្ដូរ និងត្រូវគេឲ្យគាត់ជួសជុលអង្គលីលេខ។ ការឃុំខ្លួនរបស់គាត់នៅមន្ទីរសន្តិសុខស-២១ ត្រូវបានបង្ហាញនៅក្នុងឯកសារបញ្ជីឈ្មោះរបស់អ្នកទោសនាសម័យនោះចំនួនប្រាំ។ ចម្លើយសារភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ក៏មាននៅក្នុងសំណុំរឿងនេះផងដែរ។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានផ្ដល់សក្ខីកម្មថា គាត់ត្រូវបានដើរចេញពីគុកនោះ ជាមួយនឹងអ្នកទោស១៨នាក់ទៀត នៅថ្ងៃទី០៧ ខែ មករា ឆ្នាំ១៩៧៩ គឺនៅពេលដែលកងទ័ពវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញ។

[១១:១៣:១៦]

ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្ដល់សក្ខីកម្មអំពីទុក្ខវេទនាក្នុងការដាក់ពន្ធនាគារ ការដាក់ឲ្យទៅជាទាសករ ទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលគាត់បានទទួលរង។ លទ្ធផលនៃអំពើសាហាវព្រៃផ្សៃជាប់មកដល់សព្វថ្ងៃនេះ គាត់នៅតែបន្តមានបញ្ហាស្ដាប់ពុំឮ និងងងឹតភ្នែកមើលពុំសូវច្បាស់ ដោយសារអំពើទារុណកម្មយង់ឃ្នងដែលបានប្រព្រឹត្តមកលើរូបគាត់។ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី គាត់បានរៀបរាប់ទៅកាន់អង្គជំនុំជម្រះអំពីការធ្វើទារុណកម្មរបស់គាត់ ដែលទទួលរងនៅមន្ទីរសន្តិសុខស-២១ ថា -- សូមបង្ហាញវីដេអូរបស់លោក ជុំ ម៉ី លេខ២។

[១១:១៤:០៥]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ពេលនោះ គឺថាគេវ៉ៃអ៊ំ សួរថាគ្នាអ្នែងមានប៉ុន្មាននាក់ចូល សេ.អ៊ី.អា ចូល កា.ហ្សេ.បេ អ៊ីចឹង? ហើយយើងប្រាប់គេថា ខ្ញុំអត់ស្គាល់ សេ.អ៊ី.អា, កា.ហ្សេ.បេ ទេ ពេលនោះ អាសេង ហ្នឹងទាញរំពាត់រ៉ាវមក វ៉ៃខ្ញុំផ្ទូងៗទៅ។ ពេលវ៉ៃខ្ញុំយកដៃរងអ៊ីចឹង បាក់អាកូនដៃហ្នឹងមួយ ហើយបន្ទាប់មកវាយកអាដង្កាប់មួលអាក្រចកជើង មេជើងហ្នឹងទាញផ្តាច់ បាទទាញផ្តាច់។ យើងឆ្លើយថា យើងអត់ស្គាល់ សេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹងទេ។ ពេលនុំង គឺថាវាវ៉ៃថែមទៀត គឺថាវ៉ៃហើយ វាយកអាខ្សែភ្លើងមកញាត់ស្ពឹកត្រចៀកយើងហ្នឹង ញាត់ផាច់អ៊ីចឹងទៅ ប៊ឹង! ដូចរយះ ដូចបែករំពិលរំពែកអ៊ីចឹង យើងសន្លប់មួយសន្ទុះធំ។ ឆក់ខ្សែភ្លើងហ្នឹង មានពីរដង ជម្រាបលោកមេធាវី ឆក់ពីរដង បាទ។ តែមុននេះ អាត្រចៀកម្ខាងហ្នឹង ភ្នែកម្ខាងហ្នឹង ឥឡូវប្រើការអត់កើតទេ។ អាត្រចៀកស្តាប់ទៅអត់ឮទេ ភ្នែកមើលឃើញព្រិលៗទេ បានតែម្ខាងនេះទេ។ ស៖ តើហេតុផលនៃការស្តាប់ មិនសូវឮ ឬក៏ភ្នែកមើលមិនសូវឃើញម្ខាងហ្នឹងចាប់តាំងពីពេលណាមក? ឆ៖ ពេលដែលវាដាក់ខ្សែភ្លើងឲ្យឆក់អ៊ំ ទៅគឺថា ចាប់ពេលហ្នឹងមក ឆក់ខ្សែភ្លើងហ្នឹង បាទ។"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១១:១៥:៥៨]

បាទ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី រូបនេះ គាត់ក៏បានពន្យល់ថា គាត់មិនព្រមសារភាពទេពេលនោះ ប៉ុន្តែព្រោះតែការឈឺចាប់ ដែលគាត់បានទទួលរងគាត់ក៏ចេះតែឆ្លើយ។ ខ្ញុំបាទសូមដកស្រង់សម្តីគាត់៖ "ការដែលខ្ញុំឆ្លើយការពិតមួយចំនួន ហើយឆ្លើយការមិនពិតនោះ ក៏មួយចំនួន។ មួយចំនួនដែលវាវ៉ៃខ្ញុំឲ្យឆ្លើយ ថាខ្ញុំជា សេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹង អាហ្នឹងគឺថា វាមិនមែនពិតទេ ព្រោះខ្ញុំអត់ដែលស្គាល់ សេ.អ៊ី.អា, កា.ហ្សេ.បេ ហ្នឹងទេ ដល់វាវ៉ៃខ្លាំងពេក ដាក់ខ្សែភ្លើងខ្លាំងពេក ម្ល៉ោះហើយខ្ញុំទ្រាំអត់បាន ខ្ញុំចេះតែឆ្លើយទៅដែរ។" សូមបិទការដកស្រង់។

ទាក់ទងនឹងជនរងគ្រោះដោយប្រយោលពីមន្ទីរសន្តិសុខស-២១ ម្នាក់ទៀត គឺលោក ផៃ ប៉ាប បានពិពណ៌នាអំពីការដែលគាត់បានបញ្ជាក់អំពីមរណភាពរបស់បងប្រុសរបស់គាត់។ សូមដកស្រង់៖ "បាទ ឯកសារនេះ ខ្ញុំនៅផ្ទះ តែឮគេផ្សាយវ៉ាដ្យូដែរ ប៉ុន្តែខ្ញុំគ្មានថវិកាមកមើលទូលស្លែង។ តែក្រោយមកឃើញអង្គការឯកសារកម្ពុជា បានយកឯកសាររូបថតបងខ្ញុំនេះទៅសួរដល់ស្រុកភូមិខ្ញុំហ្នឹងទៅ សួរចំគេអ្នកដទៃនោះទេ ហើយទៅដល់គេប្រាប់ថា ផ្ទះខ្ញុំ។ ខ្ញុំឃើញរូបថតហ្នឹង ខ្ញុំយំម៉្យែ។ អាណិតបង គេធ្វើបាបមុននឹងសម្លាប់។ ហើយឃើញស្គម ដែលខ្ញុំតែងតែនៅជាមួយ ទៅលេង ខ្ញុំឃើញគាត់សាច់ឈាមគាត់

គ្រាន់ ដល់ឃើញស្គមហើយ ឃើញអ្នកជាប់ឃុំឃាំងទៀត ខ្ញុំស្រក់ទឹកភ្នែករហូត។ បាទ ហ្នឹងហើយជារូបបងខ្ញុំ។ រួចប្រវត្តិនេះ ក៏ត្រកូលក៏ដូចខ្ញុំ។ ម៉ែខ្ញុំក៏ត្រកូលអ៊ីចឹងដែរ។ ហើយទៅ ទៅគាត់ជាបងខ្ញុំ ហើយមុខមាត់ក៏បងខ្ញុំដែរ។ ប៉ុន្តែខ្ញុំឃើញស្គម។ ឯកសារកម្ពុជាបង្ហាញមកខ្ញុំ ខ្ញុំយំមួយកំណាត់ថ្ងៃ អាណិតគាត់។" សូមបិទការដកស្រង់។

[១១:១៨:០៣]

នៅមានដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតឈ្មោះ ភួង យ៉ាត គាត់ក៏បានរៀបរាប់អំពីការឃើញរូបថតរបស់បងស្រី និងបងប្រុសបីនាក់របស់គាត់តាំងនៅឯគុកទួលស្លែងថា សូមដកស្រង់៖ "ខ្ញុំស្រឡាញ់គាត់ គាត់នៅគ្រប់គ្រងប្អូនថែទាំ ងូតទឹក ងូតភក់ឲ្យថែប្អូន។ ម្តាយខ្ញុំទៅធ្វើការបាត់ទៅ គាត់នៅផ្ទះថែទាំប្អូន។ ចុះទៅណាក៏គាត់នាំប្អូនទៅ គាត់ខ្លាចកាលហ្នឹង ទាហានលន់នល់ បើគាត់នៅក្រមុំ ចុះដើរទៅគេចាប់។ ទាហានចាប់ហើយ។ គាត់ទុកខ្ញុំនៅជាមួយគាត់ អត់ឲ្យទៅណាទេ។ គាត់ចុះតែទៅដងទឹក ក៏គាត់យកខ្ញុំទៅដែរ ព្រោះខ្លាចគេចាប់។ ខ្ញុំអាណិតអាសូរណាស់។ ដល់ពេលគាត់បាត់ដំណឹងឈឹងទៅ ដឹងថាគាត់ស្លាប់នៅទួលស្លែង មិនដឹងពិបាកវេទនាយ៉ាងណាទេ។ គេចង គេវ៉ៃ ទាល់សន្លប់ ដឹងអី។ ខ្ញុំបានឃើញរូបថត បងស្រីខ្ញុំនៅគុកទួលស្លែង ឡើងភ្នែកស្ពក់ មិនដឹងគេវ៉ៃ ធ្វើបាបគាត់យ៉ាងណាទេ។" សូមបិទការដកស្រង់។"

ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ក៏បានរៀបរាប់ពីការឃើញរូបថតបងប្រុសទាំងបីនាក់ នៅទួលស្លែងផងដែរថា សូមដកស្រង់៖ "ខ្ញុំមានអារម្មណ៍ក្តុកក្តួល ខ្ញុំឃើញរូបថតគាត់ ខ្ញុំរកនិយាយមិនរួចខ្ញុំគិតតែពីយំ យំៗឡើងចង់បាត់ស្មារតី"។ សូមបិទការដកស្រង់។ នៅមានដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត គឺលោកស្រី រស់ ជួរស៊ីអ៊ី ដែលជាជនរងគ្រោះដោយប្រយោល នៅមន្ទីរសន្តិសុខស-២១។ គាត់បានរៀបរាប់ពីការដែលគាត់បានដឹង ពីជោគវាសនារបស់ស្វាមីគាត់ ឈ្មោះ រស់ សារិន។ នៅពេលដែលគាត់មកទស្សនាគុកទួលស្លែងនៅក្រោយថ្ងៃរំដោះ។ សូមបង្ហាញវីដេអូរបស់អ្នកស្រី ជួរ ស៊ីអ៊ី លេខ៣។

[១១:១៩:៥៧]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"អាគេហៅថា សាលានយោបាយអ៊ីចឹងចុះ។ អ្នកហ្វឹកហ្វឺននាំអ្នកសិក្សាហ្នឹងឲ្យទៅមើលមន្ទីរប្រល័យពូជសាសន៍នៅទួលស្លែងចាស។ ខ្ញុំដើរមើលគ្រប់បន្ទប់ កន្លែងធ្វើទារុណកម្ម ប្រដាប់ប្រដាធ្វើទារុណកម្ម មានសព្វគ្រប់ហើយ ខ្ញុំមិនចង់និយាយឡើងវិញបានទេចាស។ ហើយទៅមើលកន្លែង ទីបំផុត*

*ហើយទៅមើលកន្លែងតាំងរូបថតអ្នកទោស។ នៅពេលហ្នឹងហើយដែលខ្ញុំ ជីពចរខ្ញុំវាកាន់តែលោតខ្លាំងឡើងៗ ខ្ញុំខំសម្លឹងរកមើលគ្រប់រូបថត ហើយឃើញមានរូបអ្នកដែលខ្ញុំស្គាល់ខ្លះៗ ហើយទីបំផុតទៅឃើញរូបថតប្តីខ្ញុំតែម្តង។ ពេលនោះខ្ញុំស្ទើរនឹងស្រែកទ្រហោយំ។ ស្ទើរបាត់ស្មារតី សន្លប់ តែមានសំឡេងមួយបានមកប្រាប់ខ្ញុំ ដូចមកជួយដាស់តឿនថា កុំៗយំអី តាំងចិត្តឲ្យរឹង កុំសន្លប់ដួលនៅនឹងមុខពួកហ្នឹង។ ចាស ដល់អ៊ីចឹងទៅ ខ្ញុំដូច ហាក់ដូចជាមានកម្លាំងចិត្តបន្តិចឡើងវិញ ដោយខំតាំងស្មារតីឡើងវិញ។ រួចតាំងពីពេលនោះមក ខ្ញុំក៏នឹកថា ខ្ញុំមិនអាចរស់នៅក្នុងប្រទេសរបៀបហ្នឹងទេ។ ហើយធំបំផុតហ្នឹង គឺថាខ្ញុំត្រូវរកអនាគតឲ្យប្តី -- ឲ្យកូនៗខ្ញុំហើយ ព្រោះថាបើអត់ពីឪពុកគេទៅហ្នឹង ខ្ញុំថាខ្ញុំជាម្តាយ មេម៉ាយមែនពិត តែខ្លាំង ត្រូវខំតាំងចិត្តឲ្យរឹងមាំដើម្បីចិញ្ចឹមកូនតទៅទៀត។ ពេលនោះ ដល់មើលចប់អីទៅ ចាស ក៏ម្នាក់ៗហ្នឹង វាមានចិត្តស្រងូតស្រងាត់។ តែចំពោះខ្លួនខ្ញុំផ្ទាល់ ដែលបានឃើញរូបគាត់មក គឺថាខ្ញុំដូចថាចេះតែរឹងរឹក្នុងខ្លួនណាស់ចាស ហើយខ្ញុំក៏សម្រេចចិត្តថារករត់ចេញមកប្រទេសបារាំង។"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១១:២៣:៥០]

បាទ លោកប្រធាន ទាក់ទងជាមួយនឹងជនរងគ្រោះដោយផ្ទាល់ និងដោយប្រយោលទាក់ទងនឹងមន្ទីរសន្តិសុខ ខ្ញុំបាទសូមសង្ខេបបញ្ចប់ត្រឹមនេះ ហើយសូមបន្តទៅវគ្គស្តីអំពីការបោសសម្អាតនៅភូមិភាគបូព៌ា។

សេចក្តីផ្តើមនៃវគ្គសវនាការជាសង្ខេប អង្គជំនុំជម្រះសាលាដំបូងត្រូវបានប្តឹងអំពីអត្ថិភាព និងការអនុវត្តគោលនយោបាយ ដើម្បីសម្រេចបាន និងការពារបដិវត្តន៍សង្គមនិយម គឺការលត់ដំនូវសមាសភាពមិនល្អ និងការសម្លាប់ខ្មាំងនៅក្នុងជួរបក្ស និងក្រៅជួរបក្សតាមគ្រប់មធ្យោបាយ ដែលរួមបញ្ចូលការបោសសម្អាតនៅភូមិភាគបូព៌ាផងដែរ។

ការបោសសម្អាតនៅភូមិភាគបូព៌ាត្រូវបានចាប់ផ្តើមពីពាក់កណ្តាលឆ្នាំ១៩៧៦ ដែលមានចាប់ខ្លួនអតីតលេខាតំបន់២៤ និងអតីតកម្មាភិបាលកងពល១៧០។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១១៨នាក់ត្រូវបានទទួលយក ដោយផ្អែកលើមូលដ្ឋាននៃការបោសសម្អាត។ ដើមបណ្តឹងរដ្ឋប្បវេណីបីនាក់បានពិពណ៌នាអំពីបទពិសោធន៍របស់ពួកគេក្នុងនាមជាអតីតកម្មាភិបាល និងបានទទួលរងព្យសនកម្មដោយផ្ទាល់ដោយសារការកំណត់គោលដៅចំពោះកម្មាភិបាល និងកងទ័ពមកពីភូមិភាគបូព៌ា។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានផ្តល់សក្ខីកម្មស្តីពីព្យសនកម្ម និងអារម្មណ៍នៃការក្បត់ ដែលពួកគេបានទទួលរងដោយការបោស

សម្អាតនៅភូមិភាគបូព៌ា។ បទពិសោធន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណីដោយសារព្យសនកម្ម និងការឈឺចាប់ គឺដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ យន់ ប៊ីន ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន និងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-1040 គឺជាជនរងគ្រោះផ្ទាល់ពីការកំណត់គោលដៅចំពោះកងទ័ពនិងកម្មាភិបាលនៅភូមិភាគបូព៌ា។ ក្នុងអំឡុងពេលបោសសម្អាតនោះ ពួកគេម្នាក់បានផ្ដល់សក្ខីកម្មអំពីការឈឺចាប់ផ្នែករាងកាយរយៈពេលយូរអង្វែង ដោយសាររបួសដែលពួកគេបានទទួលរងនៅពេលគេបញ្ជូនទៅសម្លាប់ ដោយសារពួកគេជាកងទ័ពភូមិភាគបូព៌ា។

ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលបានរងគ្រោះដោយសារការបោសសម្អាតនៅភូមិភាគបូព៌ាបានផ្ដល់សក្ខីកម្មអំពីទុក្ខវេទនានិងការឈឺចាប់ដែលពួកគេបានទទួលដោយសារសមាជិកគ្រួសាររបស់ពួកគេបាត់ខ្លួន ឬស្លាប់ក្នុងរបបនោះ។ ដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងវិញពីអារម្មណ៍នៃការក្បត់ដោយសារអង្គការកំណត់គោលដៅចំពោះពួកគេ និងបានវាយប្រហារទៅលើពួកគេ និងអារម្មណ៍ភ័យខ្លាចរបស់ពួកគេ។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានផ្ដល់សក្ខីកម្មផងដែរថា ពួកគេបានទទួលរងព្យសនកម្ម និងបន្តទទួលរងព្យសនកម្មដោយសារការបាត់បង់ទ្រព្យសម្បត្តិដែលត្រូវគេរឹបអូសក្នុងរបបនោះ។

[១១:២៦:៤៣]

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ឈុន សាម៉ន បានផ្ដល់សក្ខីកម្មអំពីបន្ទុកបន្ថែមត្រូវធ្លាក់មកលើរូបគាត់ក្នុងការមើលថែរក្សាគ្រួសាររបស់បងប្អូនស្រីគាត់ ដោយសារគេសម្លាប់ប្ដីរបស់គាត់ក្នុងរបបនោះ។

មុនឆ្នាំ១៩៧៥ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ឈុន សាម៉ន រស់នៅភូមិថ្មី ឃុំក្បៀត្រ ស្រុកកំពង់ពោធិ៍ ខេត្តស្វាយរៀង និងមានអាយុប្រហែល១៨ឆ្នាំ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច។ គាត់បានចូលរួមជាមួយខ្មែរក្រហមនៅខែឧសភា ឆ្នាំ១៩៧៥ ហើយពីដំបូងគាត់ជានីរសារនៅអង្គភាពគ-៧៥។ ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ត្រូវបានចាប់ខ្លួននៅខែសីហា ឆ្នាំ១៩៧៨ និងបានគេចខ្លួនរួចយ៉ាងលំបាកពីការសម្លាប់ដូចសមាជិកផ្សេងទៀតនៅក្នុងអង្គភាពរបស់គាត់ ដោយបានភៀសខ្លួនទៅប្រទេសវៀតណាម។ ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន បានជម្រាបអង្គជំនុំជម្រះនូវការឈឺចាប់របស់គាត់ ដោយសារការបោសសម្អាតផ្ទៃក្នុងនៅភូមិភាគបូព៌ាថា សូមបង្ហាញវីដេអូឃ្លីប លេខ៤។

[១១:២៧:៥៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខ្ញុំបានចូលបម្រើកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យនៅខែ៥ ឆ្នាំ១៩៧៥ ពេលនោះរូបខ្ញុំបាទ*

*មានការជឿជាក់នឹងអង្គការថ្នាក់លើដឹកនាំពិតប្រាកដ ហ៊ានលះបង់អាយុជីវិតដើម្បីប្រទេសជាតិនិងមាតុភូមិ និងប្រជាជនពិតៗដោយអស់ពីកម្លាំងកាយចិត្ត មិនខ្លាចពលីជីវិតឡើយ។ ខ្ញុំបាទគោរពតាមផែនការរបស់បក្ស អនុវត្តវិន័យបានត្រឹមត្រូវ និងចុះប្រឡូកជាមួយគ្រាប់រំសេវ ប្រយុទ្ធជាមួយខ្មាំង ទាំងយប់ទាំងថ្ងៃមានថ្ងៃខ្លះដាច់ស្បៀងអាហារពីរថ្ងៃ ទៅបីថ្ងៃ ឬជួនអត់ទឹកផឹកក៏មានដែរ គឺមានការលំបាកណាស់លោកប្រធានហ្នឹងហើយ។ ប៉ុន្តែជាលទ្ធផលរូបខ្ញុំបាទនិងក្រុមទាហានបូព៌ាជាច្រើននាក់ទៀតត្រូវបានអង្គការចោទប្រកាន់ថាក្បត់បក្ស និងចាប់យកទៅសម្លាប់ចោលទៅវិញ ធ្វើឱ្យខ្ញុំមានការតក់ស្លុតជាខ្លាំង។ ខ្ញុំពិតជាហួសនឹងរបបហ្នឹងនោះ"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:២៩:២០]

បាទ សូមអរគុណ។ ខ្ញុំបាទសូមលើកអំពីដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម -- សូមទោស ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ យ៉ុន មីន ដដែលគាត់បាន -- ត្រូវបានគេនាំទៅរណ្តៅមួយដែលពោរពេញទៅដោយសាកសព។ ហើយត្រូវគេយកពូថៅវាយក្បាលបីដងមុនពេលគេរុញទម្លាក់ទៅក្នុងរណ្តៅ។ គាត់បានផ្តល់សក្ខីកម្មថា សូមអនុញ្ញាតបញ្ចាំងវីដេអូឃ្លីប ទី៥។

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"បាទ ប្អូនគាត់ដែលគេយកទៅសម្លាប់ជាមួយនឹងខ្ញុំ បងគាត់ក៏គេយកទៅសម្លាប់ ហើយខ្ញុំប្រាប់ថា ឲ្យគាត់ទៅប្រាប់ថា មិនបាច់ឲ្យទៅទេ ព្រោះគេយកទៅសម្លាប់ហើយ គាត់ទៅប្រាប់ ហើយបងគាត់ហ្នឹងវាថា បក្សយើងមិនដែលយើងយកមនុស្សទៅសម្លាប់ចោលទេ។ បាទ ក៏គាត់យកទៅ ឥឡូវបាត់ទាល់សព្វថ្ងៃ ងាប់បាត់ហើយ គេយក។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:៣០:៣២]

បាទ សូមអរគុណ។ ខ្ញុំបាទសូមអនុញ្ញាតជម្រាបលោកប្រធាននៅដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតដែលមានរហស្សនាម 2-TCCP-1040 ដែលត្រូវបានបញ្ជូន -- ដែលត្រូវបានបញ្ជូនចេញពីខេត្តព្រៃវែងទៅខេត្តពោធិ៍សាត់ ហើយគាត់ជាអតីតកងទ័ពភូមិភាគបូព៌ា។ គាត់ត្រូវបានគេធ្វើបាបយ៉ាងធ្ងន់ធ្ងរនៅពេលទៅដល់ ដោយគាត់បានរៀបរាប់អំពីទុក្ខលំបាករបស់គាត់ និងបានសួរទៅជនជាប់ចោទតាមរយៈលោកប្រធាន ដូច្នេះ សូមអនុញ្ញាតបញ្ចាំងវីដេអូ លេខ៧។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:៣១:១៦]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ដែលចង់ខ្ញុំយកចាប់បានចងយកទៅបាញ់ចោល ដែលធ្វើឲ្យខ្ញុំត្រូវរបួសពិការភាព បាក់ដៃរហូតនឹងវាយដំនឹងស្វ័យកាំភ្លើង គឺគ្រាំគ្រាខ្លួនដែលមកដល់សព្វថ្ងៃនេះ។ បើខ្ញុំដើរព្យាបាលតាមពេទ្យឯកជន តាមពេទ្យរដ្ឋ ហើយបាត់បង់កម្លាំងពលកម្ម។ ការរកទទួលទានមិនកើតតើ ហើយលោកប្រធានសួរទៅជនជាប់ចោទ តើអ្នកណាទទួលខុសត្រូវទៅលើបញ្ហាដែលខ្ញុំមានជីវប្រវត្តិដូច្នេះ ហើយនិងមានជំងឺនិងរបួសពិការដែលបាក់ឆ្អឹងដៃមួយចំហៀង និងដកសរសៃ ដាច់សរសៃ ដូចជាសរសៃសត្វធាតុអ៊ីចឹងគឺហើយអ្នកណាទទួលខុសត្រូវ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:៣២:៤៧]

បាទ នេះជាសម្ដីរបស់ជនរងគ្រោះដែលបានធ្វើសក្ខីកម្មរួចមកហើយ ដែលខ្ញុំបានបញ្ជាក់ជូន។ ហើយខ្ញុំបាទសូមបញ្ចប់ការថ្លែងការណ៍របស់ខ្ញុំបាទតែប៉ុននេះ និងសូមបន្តវេទិកាទៅលោកមេធាវីនាំមុខបន្តទៅទៀត។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ មានអីទេលោកមេធាវី?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ដោយសារថាការគិតគូរពេលវេលាទៅយើងឃើញថា យើងខ្ញុំមានការ -- ត្រូវការពេលវេលាថែមប្រហែលជា១៥នាទី។ ដូច្នេះ សម្រាប់ជាការស្នើសុំជូនលោកប្រធានលោកស្រីចៅក្រម ដើម្បីអនុញ្ញាតអាចបន្ទាយពេលបន្តសវនាការនាពេលល្ងាចនេះ បន្ថែមដោយអនុញ្ញាតឲ្យយើងខ្ញុំថ្លែងបន្ថែមក្នុងរយៈពេល១៥នាទីបន្ថែមទៀត ប្រសិនបើថាអាចធ្វើបាន។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឥឡូវហ្នឹង បន្តឥឡូវតែម្ដងទៅ ហើយត្រូវការ -- កិច្ចការអីខ្លះ បាទ?

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមសាជាថ្មីជាបន្តទៀត ខ្ញុំនឹងលើកឡើងអំពីសេចក្តីថ្លែងដោយផ្ទាល់មាត់ ចំពោះការប្រព្រឹត្តទៅលើប្រជាជនចាម។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលយកដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤៦រូប ហើយអង្គបុរេជំនុំជម្រះបានទទួលយកដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមចំនួន ៩៥រូប។ ជាសរុប ១៤១រូប ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តទៅលើជនជាតិចាម។ ហើយនៅក្នុងនោះគឺមានដើមបណ្តឹងរដ្ឋប្បវេណីជនជាតិចាម ចំនួនប្រាំមួយរូប បានមកផ្តល់សក្ខីកម្មនៅចំពោះអង្គសវនាការនេះ ដែលមានលោក សុះ មីន, លោកស្រីនោ សាទះ, លោក ម៉ាន ស្លេះ, លោក ហ៊ីម ម៉ាន, លោក ម៉ី ពៅ និងលោកស្រី ឡិប នាង។

ចំពោះបញ្ហាធ្វើទុក្ខបុកម្នេញដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពាក់ព័ន្ធជាពិសេសនៅក្នុងការធ្វើឲ្យប៉ះពាល់ទៅដល់សាសនានៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ដោយដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងអំពីរបៀបកំណត់គោលដៅចំពោះមេដឹកនាំសាសនាអ៊ីស្លាម របៀបបំផ្លិចបំផ្លាញវិហារអ៊ីស្លាម ឬក៏យកមកប្រើប្រាស់ក្នុងគោលបំណងផ្សេង។ របៀបបំផ្លិចបំផ្លាញគម្ពីគូរ៉ាន់ និងរបៀបហាមឃាត់មិនឲ្យប្រជាជនចាមធ្វើការបួងសួង។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានពិពណ៌នាផងដែរ អំពីរបៀបដែលស្ត្រីត្រូវបានកាត់សក់។ ចាម ប្រជាជនចាម ត្រូវបានហាមឃាត់មិនឲ្យពាក់ក្រមាគ្របក្បាល និងរបៀបប្រជាជន និងបង្ខំឲ្យប្រជាជនចាមបរិភោគសាច់ជ្រូក។

ខ្ញុំសូមអនុញ្ញាតបញ្ចាំងវីឌីអូរបស់លោក ហ៊ីម ម៉ាន។ សូមបញ្ចាំង។

[១១:៣៦:១៧]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ទៅប្រជុំ គេប្រជុំប្រាប់ថា ពួកជនជាតិនេះឲ្យកាត់សក់ ឲ្យអ្លែងកុំឲ្យទទូរក្រមា ហើយឲ្យហូបសាច់ជ្រូក ហើយកុំឲ្យសំពះយ៉ាំង គ្រប់បែបយ៉ាងទាំងអស់ដែលសាសនាមូស្លីម គាត់ឃាត់ឃាំងទាំងអស់។ បើសិនជាមិនស្តាប់ទេ បងប្អូនកង់ប្រវត្តិសាស្ត្រវិលទៅហើយ លូកដៃដាច់ដៃ លូកជើងដាច់ជើង។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:៣៧:០០]

ដើមបណ្តឹងរដ្ឋប្បវេណីបន្ត គឺលោក ម៉ី ពៅ ក៏បានលើកអំពីការប្រព្រឹត្តទៅលើអ្នកកាន់សាសនាអ៊ីស្លាមយ៉ាងតឹងរ៉ឹងផងដែរ ដែលនៅក្នុងនោះ ឪពុកខ្ញុំស្លាប់ដោយសារមូលហេតុគាត់ជាជនជាតិចាមគាត់កាន់សាសនាអ៊ីស្លាម ហើយគាត់គឺជឿជាក់ទៅលើសាសនា គាត់មិនធ្វើតាមអង្គការកំណត់។ ពេល

នោះ គេយកសាច់ជ្រូកមកឲ្យគាត់ពិសា តែគាត់មិនព្រមពិសា គាត់មិនព្រមទេ។ អ៊ីចឹងអង្គការបានដាក់ផែនឲ្យគាត់ បើមិត្តមិនហូបសាច់ជ្រូកទេ អង្គការមានសាច់ជ្រូកឲ្យមិត្តហូប ហើយបើមិត្តមិនហូបទេ អង្គការមិនដឹងជារកអ្វីឲ្យមិត្តហូបនោះទេ។ អ៊ីចឹងហើយពេលនោះ ឪពុកខ្ញុំគ្រាន់តែហូបតែទឹក ហើយគាត់រកលួចលាក់បេះស្លឹកឈើ ស្លឹកព្រៃ រស់ៗទាំងត្រដរ។ រហូតការវេទនារបស់គាត់នេះ គឺកាលពីសម័យនោះ ខ្ញុំគិតថាបើគេសម្លាប់គាត់ហ្នឹង ល្អជាងធ្វើទារុណកម្មគាត់បែបនេះ។ ពួកខ្មែរក្រហមវាមិនៗធ្វើអ្វីទេ អ្វីដែល -- នេះគឺជាទុក្ខវេទនា ហ្នឹងហើយដែលជាគំរូរបស់អ្នកក្រោយៗទៀត។ ពេលនោះហើយគឺគាត់រស់នៅដោយស្បែកដណ្ដប់ឆ្អឹង ឪកូនក៏ព្រាត់ប្រាស ប្រពន្ធក៏ព្រាត់ប្រាស សាច់ញាតិក៏ព្រាត់ប្រាស រហូតដល់គាត់ស្លាប់តែម្តង។

ពាក់ព័ន្ធទៅនឹងការបះបោរ និងព្រឹត្តិការណ៍ដែលកើតមានក្រោយពីនោះ ខ្ញុំសូមលើកថា ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មអំពីអំពើមនុស្សឃាត ការធ្វើទារុណកម្ម ការឃុំឃាំងក្នុងគុក និងការបាត់ខ្លួនប្រជាជនចាមក្នុងអំឡុងពេល និងក្រោយពេលមានការបះបោរនៅស្វាយឃ្លាំង នៅខែតុលា ឆ្នាំ ១៩៧៥។ ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានផ្ដល់សក្ខីកម្មថា ប្រជាជនចាមជាច្រើនបានស្លាប់ក្នុងពេលបះបោរ គាត់បានពន្យល់តាមសម្ដីរបស់ខ្លួនថា “ពេលនោះខ្ញុំក៏បានចូលរួមកាន់កំបិត ចូលរួមជាមួយគេដែរ គ្រាន់តែខ្ញុំនៅជួរក្រោយ ឃើញអ្នកស្លាប់ជាច្រើននៅសងខាង តែពួកខ្ញុំ ខ្មែរក្រហម តែពួកខ្ញុំ -- ពួកខ្មែរក្រហមស្លាប់តិចជាង ព្រោះអាវុធយើងខ្លី អាវុធគេវែង”។

[១១:៣៩:៤០]

ចំពោះការផ្លាស់ទីលំនៅប្រជាជន ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន, នោ សាទះ និង ម៉ាន ស្លេះ បានពិពណ៌នាអំពីរបៀបដែលពួកគេត្រូវបានជម្លៀសដោយបង្ខំចេញពីភូមិរបស់ខ្លួន។ ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន បានពិពណ៌នាថា “អ្វីដែលខ្ញុំរួចចេញពីមន្ទីរឃុំឃាំងមក គេឲ្យខ្ញុំទៅជួបជុំគ្រួសារ ហើយគ្រួសារខ្ញុំទាំងអស់ គេមិនឲ្យចូលភូមិទេ ទាំងអ្នកភូមិស្វាយឃ្លាំងទាំងអស់ចេញពីមន្ទីរឃុំឃាំង គេដាក់ទូកទៅ ជម្លៀសទៅស្រុកដំបែ។ គេមានស្រុកនៅស្ទឹងត្រង់ មាននៅខាងបារាយណ៍ មានអីវាគ្រប់កន្លែង ខ្ញុំមិនអាចចាំបានទេ”។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនេះ បានពិពណ៌នាអំពីការជម្លៀសជាច្រើនដង និងត្រូវបានគេធ្វើ -- ឲ្យធ្វើការក្នុងស្ថានភាពលំបាកដោយគ្មានអាហារគ្រប់គ្រាន់ ពួកគេត្រូវការ -- ត្រូវបានបំបែកចេញពីមនុស្សជាទីស្រឡាញ់ អ្នកខ្លះត្រូវបានគេសម្លាប់ ឬលែងបានឃើញ ឬដឹងដំណឹងជារៀងរហូត។

ពាក់ព័ន្ធទៅនឹងវត្តអូរត្រកួន ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលា -- អំពីការសម្លាប់ប្រជាជនចាមនៅអូរត្រកួន នៅខែសីហា ឆ្នាំ១៩៧៧ គាត់បានពន្យល់ថា គេបានប្រមូលផ្ដុំប្រជាជនចាមពីភូមិរបស់គាត់ ហើយនាំយកទៅវត្តអូរត្រកួន រួមទាំងសមាជិកគ្រួសាររបស់គាត់មួយចំនួនផង។ គាត់បានពិពណ៌នាអំពីរបៀបដែលប្រជាជននោះ ត្រូវបានគេយាមកាមដោយមានកាន់អាវុធ និងរបៀបដែលគាត់នាំពួកគាត់ទៅវត្តនោះ។

ដូច្នេះ សូមបញ្ចាំងវីដេអូរទី២ របស់លោក ហ៊ឹម ម៉ាន។

[១១:៤១:៥១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"វាមានហេតុការណ៍ហើយ ចេះតែសង្ស័យខ្ញុំនៅក្នុងខ្លួន មានហេតុការណ៍ហើយ បានគេឲ្យពួកយើងនៅទាំងអស់ហ្នឹង ហើយដល់អ៊ីចឹង គឺថ្ងៃម៉ោងបី វាប្រមូលតែម្ដង មានអាក្រុមដាវវែងមកប្រមូលតែម្ដង។ ប្រមូលអាខ្លះទៅស្លៀកខោទៅ ខ្លះស្លៀកក្រមាទេ ខ្លះអត់មានអាវទេ។ ព័ទ្ធជុំៗគ្នា គៀងយកទៅតែម្ដង ដោយទាំងខ្ញុំអីយកទៅទាំងអស់ បានអ៊ូ!ដោយមែន ដូចគិតមែន បាទ។ យកទៅរណ្ដៅ វត្តអូរត្រកួន ហើយអ៊ីចឹងទៅ ខ្ញុំឮសម្រែក ខ្ញុំនៅពួនហ្នឹង សម្រែកប្រហែលជា អើ! ងងឹតហើយ ប្រហែលជាម៉ោងប្រាំពីរ ប្រាំមួយ-ប្រាំពីរហ្នឹង តាមស្មានទេ ពីមុនហ្នឹងសុទ្ធតែស្មានទាំងអស់ហ្នឹង។ បើងងឹតហ្នឹងម៉ោងប្រាំមួយ ម៉ោងប្រាំពីរបាទ។ អ៊ីចឹងសម្រែកថា អល់ឡោះប៉ូលីយ! អ៊ីចឹងខ្ញុំក៏ផ្ដេកផ្ដួលថា ប្អូនខ្ញុំម៉ែខ្ញុំ ដែលគេចាប់ទៅជាមួយខ្ញុំ ហើយខ្ញុំរត់រួច ហើយឥឡូវឮស្នូរស្រែក អល់ឡោះប៉ូលីយ! ព្រះអើយ! ប៉ូលីយ! អ៊ីចឹង ស្រែកអ៊ីចឹងមានន័យថា ពួកសាសនាមហាម៉ាត់ហើយ ដែលទៅក្នុងភូមិនុំងទាំងអស់គ្នាហ្នឹង ជាប់ខ្ញុំ ខ្ញុំទៅពួនហ្នឹង ខ្ញុំបានស្ដាប់បាន។ បាទ បានខ្លួនខ្ញុំហ្នឹងវាទ្រុឌទ្រោមពីថ្ងៃនុំងមក វាគ្មានអីសង្ឃឹមបាទ ចិត្តខ្ញុំហ្នឹងវាចង់ឆ្កួតបន្តិច អីបន្តិចហើយ ព្រោះវាអស់ពូជអំបូរ វាអស់ខាងសាសនាអីរលីងទាំងពីសាច់ញាតិ សាច់សាលោហិតក្នុងភូមិ រលីងខ្ញុំគ្មានសង្ឃឹមទេ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:៤៣:៥៤]

ចំពោះនៅភូមិទ្រាវិញ ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះអំពីការសម្លាប់ប្រជាជនចាមនៅភូមិទ្រា ដោយលើកអំពីការដែលមេស្រុកបានសួរចម្លើយពួកគេ និងរបៀបដែលមេស្រុកសួរស្ត្រីម្នាក់ៗថាតើគាត់ជាខ្មែរ ឬជាចាម។ ដូច្នេះ សូមបញ្ចាំងវីដេអូរបស់លោក

ស្រី នោ សាទះ វីដេអូលេខ៣ សូមបញ្ចាំង។

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...ផ្លូវទៅមានឃោធាពីរនាក់ ស្រីម្នាក់នោះកាន់ខ្សែអង្រឹងទៀត ចៅហ្វាយស្រុកឈ្មោះ ហ៊ ថា ក្អួយៗយើងក្រោកឡើង ពូសុំចង ហើយពួកខ្ញុំក៏ក្រោកដែរ ក្រោកឡើងមកឲ្យគេចងដោយស្រួលគ្មានអីថា ងាកវេទៅខាងណាខាងណីទេ ឲ្យគេចងរួច ៗគេតម្រង់មួយជួរៗទៅ ប្រហែលជា៣០០នាក់ ៤០០នាក់ ក្នុងមួយផ្ទះហ្នឹងនោះ មិនមែនតិចទេណ៎ា សុទ្ធតែនារីពេញទំហឹងតែម្ដងហើយ។ រួចដល់អ៊ីចឹងទៅ គេចងរួចៗហ្នឹង គេចាប់ផ្ដើមសួរយើងហើយ។ គេសួរថា កូនចាម កូនខ្មែរ អ្នកដែលឆ្លើយត្រង់ថា កូនចាម កូនចាមចុះ មានអាវុធមួយដើមអាកាស្វាយបត់ ហើយនិងកាំបិតដុកមួយដើមទៀត លីទៅជាមួយគ្នា។ ស្រីម្នាក់ហ្នឹងណ៎ា ពួកខ្ញុំហ្នឹងចុះទៅហ្នឹង អ្នកដែលគេសួរថាកូនចាមនោះ។ ពាក្យថា កូនចាមចុះៗ ហ្នឹងទៅ សុទ្ធតែមានអ្នកជូនទៅ សុទ្ធតែមានប្រដាប់អាវុធទាំងអស់ អត់មាននេះទេ។ រួចទៅហ្នឹង អត់មានផ្លូវមកវិញទេ អត់ឃើញទេ អ្នកដែលទៅនោះ អត់មកវិញទេ បាត់សូន្យទាល់ឥឡូវនេះ។ រួចខ្ញុំគេចងខ្ញុំរួច គេសួរខ្ញុំរួចហ្នឹងណា រួចមកដល់ពួក ដល់ខ្ញុំនេះ សួរខ្ញុំថា នាងឯងកូនចាមកូនខ្មែរ? ក្អួយឯងកូនចាម កូនខ្មែរ? ខ្ញុំឆ្លើយ ខ្ញុំថា ខ្ញុំកូនខ្មែរ។ រួចគេច្បិចពិល មើលខ្ញុំនេះ។ គេ...ហេ! មិនមែនកូនខ្មែរទេ កូនយួនទេអេ្ហ? ខ្ញុំថា ខ្ញុំកូនខ្មែរ ខ្ញុំមិនមែនកូនយួនទេណា មើលមុខឲ្យច្បាស់ទៅ អ៊ំប្រកែកជាមួយចៅហ្វាយស្រុកទៀត។ បីដង ឆ្លើយជាមួយវាថា ខ្ញុំកូនខ្មែរ បានវាទទួលស្គាល់ថា ខ្មែរមែន។ រួចដល់ពួកហ្នឹង វាទៅអស់ទៅ ពួកចាមៗហ្នឹងចុះទៅអស់ហើយ នៅសល់ពួកខ្ញុំប្រហែល៣០នាក់ហ្នឹង គាត់ថា គាត់ចងរួច គាត់សួរហ្នឹងណា គាត់ស្រាយឲ្យវិញទៅ។ ប៉ុនថា សំណាងហើយបានពូមកសួរនេះ កុំអីទៅអស់ហើយ។ គាត់និយាយអ៊ីចឹងណ៎ា។"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១១:៤៦:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សូមភាគី និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោយ

សាលសវនាការដែលរៀបចំបន្ទប់សម្រាប់គាត់ ហើយនិងឲ្យនាំខ្លួនគាត់ ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៤៧ នាទី ដល់ម៉ោង ១៣:២៩ នាទី)*

[១៣:២៩:៣៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**លោក ពេជ អង្គ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងសាធារណជនសាជាថ្មី។ ខ្ញុំនឹងបញ្ចប់ការថ្លែងដោយផ្ទាល់អំពីវគ្គការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម។

ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗបានផ្តល់សក្ខីកម្មអំពីព្យសនកម្ម ដែលពួកគាត់បានទទួលរង។ ដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នាអំពីទុក្ខវេទនា ដែលពួកគេទទួលរងដោយសារសមាជិកគ្រួសាររបស់គេបានបាត់ខ្លួន ឬក៏ស្លាប់នៅក្នុងរបបនោះ។ ពួកគេបានផ្តល់សក្ខីកម្មអំពីការឈឺចាប់ ដែលពួកគេបានជួបប្រទះ ដោយសារមិនបានប្រតិបត្តិសាសនារបស់ខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ បានផ្តល់សក្ខីកម្មថា ពួកគេបានប្តូរឈ្មោះ ដើម្បីលាក់អត្តសញ្ញាណរបស់ពួកគេថាជាជនជាតិចាមមិនឲ្យគេដឹង។

ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនបានផ្តល់សក្ខីកម្មអំពីព្យសនកម្មលើរូបរាងកាយដោយផ្ទាល់និងផ្លូវចិត្តដែលពួកគេទទួល ដោយសារពុំមានអាហារបរិភោគ និងការបង្ខំឲ្យធ្វើការហួសកម្លាំង។ ពួកគេក៏បានរំឭកផងដែរ អំពីការភ័យខ្លាចជាប្រចាំ និងការឃើញអំពើហិង្សា ឬការគំរាមកំហែង ប្រើអំពើហិង្សាទៅលើអ្នកដទៃ ដែលនៅជុំវិញខ្លួនរបស់ពួកគេ។

[១៣:៣១:៣២]

ដើមបណ្តឹងរដ្ឋប្បវេណីក៏បានផ្តល់សក្ខីកម្មផងដែរ អំពីព្យសនកម្មផ្នែកសម្ភារៈ ដែលពួកគេបានទទួលរង។ ដើមបណ្តឹងរដ្ឋប្បវេណីពិពណ៌នាអំពីរបៀបដែលជីវភាពរស់នៅ និងក្តីសង្ឃឹមរបស់ -- សម្រាប់ពួកគេយូរអង្វែងត្រូវបានកាត់បន្ថយ និងដោយសារពួកគេពុំមានឱកាសទទួលនៅក្នុងការអប់រំ ឬដោយសារគ្រួសាររបស់គេបានបាត់បង់ទ្រព្យសម្បត្តិអស់ ហើយនៅទីចុងបញ្ចប់សក្ខីកម្មរបស់ពួកគាត់ត្រូវបានលើកឡើង ហើយជាពិសេសត្រូវបានលោក សុះ មីន គាំទ្រ ហើយនិងបានលើកចោទជាសំណួរតាមរយៈលោកប្រធានសវនាការទៅជនជាប់ចោទ ដែលខ្ញុំសុំអនុញ្ញាតបញ្ចាំងវីដេអូទី៤ ដែលថ្លែងដោយលោក សុះ មីន ដូចតទៅនេះ។

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"តើមូលហេតុអ្វីបានជាបំបាត់ជំនឿសាសនាទាំងអស់ ដូចជាខ្ញុំបាទ សាសនាខ្ញុំបាទជាជនជាតិចាមត្រូវរងការធ្វើទុក្ខបុកម្នេញគ្រប់ពេលវេលា?"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៣:៣៣:០៨]

បាទ ជនជាតិចាម ដែលរស់នៅស្រុកខ្មែរនៅព្រះរាជាណាចក្រកម្ពុជាគ្រាន់តែចង់បានរស់នៅឲ្យមានសុភមង្គលដូចជនជាតិខ្មែរដែរ ក៏ប៉ុន្តែផ្ទុយមកវិញ គាត់បានទទួលរងទុក្ខវេទនាជាច្រើននៅក្នុងសម័យទី១៧ មេសា ១៩៧៥ រហូតទៅដល់ ០៦ មករា ១៩៧៩។ ខ្ញុំសូមថ្លែងសេចក្តីសន្និដ្ឋានត្រឹមនេះ ត្រឹមនេះ និងសូមវេទិកាបន្ត ផ្ទេរវេទិកាបន្តជូនលោកស្រីមេធាវីនាំមុខអន្តរជាតិ លោកស្រី ម៉ារី ហ្គីរ៉ូដ៍ ដើម្បីថ្លែងអំពីការធ្វើទុក្ខបុកម្នេញទៅលើជនជាតិវៀតណាម។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

<> សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមទាំងអស់ជាទីគោរព។ គោរពភាគីទាំងអស់។ ខ្ញុំនឹងចំណាយពេលវេលានេះ ដើម្បីនិយាយជាបឋមអំពីការប្រព្រឹត្តទៅលើជនជាតិវៀតណាម ហើយបន្ទាប់មក ហើយនិងនិយាយអំពីបញ្ហាបទបញ្ជានៃការរៀបការ ហើយបន្ទាប់មក ខ្ញុំនឹងធ្វើសេចក្តីសន្និដ្ឋានទាក់ទងទៅនឹងតម្លៃភស្តុតាងនៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

ទាក់ទងនឹងបញ្ហាការប្រព្រឹត្តិទៅលើជនជាតិវៀតណាម<ក្នុងអំឡុងពេលរបបនោះ។> អង្គជំនុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជម្រះបានទទួលដីកាដំណោះស្រាយ ដែលការកត់សម្គាល់ឃើញថា ជនជាតិជាតិវៀតណាមជាក្រុមជាតិ<ពន្ធុ>មួយ<>និងកាន់សាសនាមួយ។ អង្គជំនុំជម្រះបានទទួល<អង្គហេតុនានា>ទាក់ទងទៅនឹងការបណ្តេញជនជាតិវៀតណាមនៅឆ្នាំ១៩៧៥ និង ៧៦ ហើយនិងការប្រព្រឹត្តឧក្រិដ្ឋកម្មទ្រង់ទ្រាយធំប្រឆាំងទៅលើជនជាតិវៀតណាម នៅព្រៃវែង ស្វាយរៀង និងនៅក្នុងកន្លែងផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ដែលមាននៅក្នុងបញ្ជី គឺនៅក្នុងកថាខណ្ឌ៨០៣ នៃដីកាដំណោះស្រាយហើយជាពិសេសមាននៅក្រចេះ។ នៅក្នុងការធ្វើមនុស្សឃាតដែលកំណត់ជាគោលដៅនេះ គឺអង្គជំនុំជម្រះត្រូវតែសម្រេចលើអង្គហេតុថា តើឧក្រិដ្ឋកម្មទាំងអស់នេះត្រូវការ -- ត្រូវបានប្រព្រឹត្តហ្នឹង ដោយឈរលើមូលដ្ឋាននៃទ្រឹស្តីពូជសាសន៍ ឬក៏ដែលយកម្តាយជាធំ ឬក៏យ៉ាងណា។ <សរុមមក> មានដើមបណ្តឹងរដ្ឋប្បវេណី៧៣នាក់ដែលបានចូលរួមក្នុងនីតិវិធីលើមូលដ្ឋាននៃព្យសនកម្មដែល<ពួកគាត់ទទួលរងការឈឺចាប់ ពាក់ព័ន្ធទៅនឹងការ>ប្រព្រឹត្តទៅលើជនជាតិវៀតណាម។ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំពីរនាក់បានមកផ្តល់សក្ខីកម្មនៅទីនេះទាក់ទងនឹងប្រធានបទនេះ។

[១៣:៣៦:១១]

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជឿង យ៉ាំងចែត ដែលជាជនជាតិវៀតណាមសុទ្ធតែម្តង ដែលបានមកទីនេះផ្តល់សក្ខីកម្ម ហើយដើមបណ្តឹងរដ្ឋប្បវេណីប្រាំមួយនាក់ទៀតគឺជាខ្មែរសុទ្ធ ដែលបានផ្តល់សក្ខីកម្មទាក់ទងនឹងជោគវាសនាអំពីបងប្អូន ឬក៏អ្នកញាតិជិតខាងដែលមានដើមកំណើតជាវៀតណាម។ គាត់បានរៀបរាប់អំពីការបញ្ជូនគាត់ទៅវៀតណាម -- ជម្លៀសគាត់ទៅវៀតណាមនៅចុងឆ្នាំ១៩៧៥ គាត់ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីមួយទៀតគឺ ប្រាក់ ឌឿន បានធ្វើសក្ខីកម្មទាក់ទងនឹងបទពិសោធន៍របស់ខ្លួននៅក្នុងខេត្តកំពង់ឆ្នាំង។

[១៣:៣៦:៥២]

ដើមបណ្តឹងរដ្ឋប្បវេណីពីរនាក់ទៀតគឺ ឡាច គ្រី ហើយនិង ដួង អឿន នេះបានធ្វើសក្ខីកម្មទាក់ទងនឹងការសម្លាប់មនុស្ស និងដែលត្រូវជាបងប្អូនរបស់គាត់ ហើយនិងអ្នកមានដើមកំណើតជាវៀតណាមនៅក្នុងភូមិពោធិ៍ចន្ទាំ នៅក្នុងខេត្តព្រៃវែង។ <សក្ខីកម្មរបស់>ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះបាននិយាយថា <ជនជាតិវៀតណាមទាំងអស់នៅក្នុងភូមិពោធិ៍ចិន្តាំ>ត្រូវបានគេនាំចេញទៅ ហើយមិនដែលឃើញត្រឡប់មកវិញទេតាំងពីឆ្នាំ<១៩៧៧>។ ដើមបណ្តឹងរដ្ឋប្បវេណីមួយទៀតឈ្មោះ <សៀងចាន់ថី> បាននិយាយអំពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មទាក់ទងទៅនឹងការប្រព្រឹត្តលើជនជាតិវៀតណាមនៅ

ក្នុងខេត្តស្វាយរៀង។ អ៊ុច ស៊ុនឡាយ បានផ្តល់សក្ខីកម្មទាក់<ទងនឹង>ការសម្លាប់ប្រពន្ធគាត់ដែលជនជាតិវៀតណាម ហើយនិងកូនរបស់គាត់នៅខែកញ្ញា ឆ្នាំ១៩៧៨ នៅខេត្តក្រចេះ។

[១៣:៣៧:៥២]

ខ្ញុំសូមផ្តោតទៅលើសម្រង់នៃការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលអាចជួយឲ្យអង្គជំនុំជម្រះកំណត់ប្រភេទ<ធាតុផ្សំនៃ>បទឧក្រិដ្ឋចំនួនពីរដែលគេកំពុងតែកាត់ក្តីជនជាប់ចោទទាំងអស់នេះគឺបទឧក្រិដ្ឋជម្លៀស ហើយនិងឧក្រិដ្ឋបទប្រល័យពូជសាសន៍<តាមរយៈការចេញបទបញ្ជាឲ្យសម្លាប់>។ ជឿង យ៉ាំងចែត នេះ គឺដូចខ្ញុំបានជម្រាបជូន<នៅក្នុងសេចក្តីផ្តើម>អ៊ីចឹង គឺថាគាត់ជា<ដើមបណ្តឹងរដ្ឋប្បវេណីមួយដែលមានដើមកំណើត>ជនជាតិវៀតណាមសុទ្ធតែម្តង គាត់កើតនៅប្រទេសកម្ពុជា គាត់រស់នៅខេត្តកំពង់ឆ្នាំង<>រហូតដល់ពីរបីខែក្រោយ<ខែ>មេសា ឆ្នាំ៧៥។ <មួយខែក្រោយពីបានឃើញ>ការសម្លាប់ក្រុមគ្រួសាររបស់គាត់<មក>គាត់<នៅ>រស់រានមានជីវិត ហើយគាត់បានឮគេថា វៀតណាមនុំងត្រូវទៅត្រឡប់ទៅវៀតណាមវិញ<> ហើយគាត់ អង្កាល់ណោះគាត់មានអាយុប្រហែល១៣-១៤ឆ្នាំ <នៅពេលដែល>គាត់បានជិះ<កាណូត>ពីកំពង់ឆ្នាំងមកភ្នំពេញ។ <ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់រឿងរ៉ាវនោះ ហើយ>ខ្ញុំសូមដកសម្រង់៖ "គេ<បានជ្រើសរើសមនុស្ស>ឲ្យមនុស្សហ្នឹងឡើងជិះសាឡាង ហើយសួរថាអ្នកណាជនជាតិវៀតណាម? អ្នកណាជាជនជាតិចិន? អ្នកណាជាជនជាតិខ្មែរ? ហើយដោយសារវៀតណាមហ្នឹងនិយាយខ្មែរប៉ែឡាំៗ អ៊ីចឹងស្រួលដឹងថាពួកគាត់ជាអ្នកណា។ ហើយចខ្មែរវិញនេះ គេដឹងថាខ្មែរនោះស្រួល ដោយសារទម្រង់មុខ ហើយបើអ្នកណានិយាយខ្មែរប៉ែឡាំៗនោះមិនអាចកប៉ាល់បានទេ។ នៅពេលដែលគាត់ទៅដល់អ្នកលឿងក្នុងខេត្តព្រៃវែង ជឿង យ៉ាំងចែត នេះគាត់និយាយថា មានដោះដូរអំបិលហើយនិងស្រូវហ្នឹងជាមួយនឹងជនជាតិខ្មែរ រវាងវៀតណាមនិងខ្មែរ។ នៅក្នុងសម្រង់វីដេអូទី១នោះ គាត់ពិពណ៌នាពីការដោះដូរគ្នាដូចតទៅនេះ។

[១៣:៤០:១៣]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"បាទ ខ្ញុំ តែក្នុងហ្នឹងខ្ញុំស្គាល់ មិនឃើញម៉េច ខ្ញុំទៅសាឡង់ហ្នឹងដែរ ខ្ញុំនៅគោក ខ្ញុំឃើញគេលើកអំបិល លើកអង្ករមកសាឡង់ខាងខ្មែរយើងហ្នឹងឯង។ ហើយខ្ញុំទៅសាឡង់អង្ករអំបិលហ្នឹង ទៅស្រុកប្រទេសយួនហ្នឹងហើយ។ ពីព្រោះខ្ញុំឮថា វៀតណាគេដើរ គេនិយាយជាមួយខ្ញុំអ៊ីចឹងដែរ។ គេថា ខ្ញុំរស់*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*នឹងអង្គរអំបិលហ្នឹងហើយ ខ្ញុំដូរលោកឯងទៅស្រុកយួនហ្នឹងហើយ។ ខ្ញុំនៅសាតុងណុង។ នៅហ្នឹងគេរុញឲ្យខ្ញុំឡើងសាលារៀនសាតុងណុងហ្នឹង។ ហើយគេចាំខ្ញុំ៧ថ្ងៃនៅសាលាហ្នឹង គេបាន គេស៊ីញេសំបុត្រអីគេ បានគេបញ្ជូនទៅទឹកជូរ ទឹកផឹកមិនបាន គេហៅទឹកជូរ។ ហើយគេឲ្យនៅហ្នឹង។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៤១:១៥]

ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ហើយហ្នឹង ដួង អឿន បាននិយាយពិពណ៌នាអំពីការសម្លាប់អ្នកដែលមានដើមកំណើតជាវៀតណាម ហើយការណ៍នេះកើតឡើងនៅភូមិពោធិ៍ចិន្ដាំ នៅក្នុងខេត្តព្រៃវែងក្នុងឆ្នាំ១៩៧៧។ ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី នេះគាត់បានទទួលសិទ្ធិពីដើមបណ្ដឹងរដ្ឋប្បវេណី ឡាច នី <គឺម្នាក់>ស្ថិតនៅក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើន ដែលបានស្លាប់<មុនពេលចប់>ការកាត់សេចក្ដីនេះ។ ឡាច នី នេះគាត់បានរៀប<>ការជាមួយ<ស្ត្រីម្នាក់ដែលមានដើមកំណើតជា>ជនជាតិវៀតណាម<> ហើយ<>បងប្អូន<ប្រុស>ពីរនាក់<ហ្នឹងគឺ>រស់នៅក្នុងភូមិជាមួយគ្នា <គឺភូមិពោធិ៍ចិន្ដាំ>។ ឡាច គ្រី នេះគាត់ជាសាក្សីឃើញពីការបាត់ប្រពន្ធរបស់បងប្រុសរបស់គាត់ ហើយនិងកូនទាំងប្រាំរបស់បងប្រុសគាត់។ ហើយ<ឥឡូវនេះ ខ្ញុំសូមចាក់បញ្ចាំងវីដេអូលេខ២ ដែល ឡាច គ្រី> និយាយ<ពន្យល់ ដែលគាត់បានឃើញផ្ទាល់ភ្នែកអំពីការចាប់ខ្លួនប្រពន្ធ និងកូនរបស់បងប្រុសគាត់។>

[១៣:៤៣:៣៤]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ពេលដែលគេចាប់ សាន ហ្នឹងទៅឲ្យឡើងរទេះសេះ បានកូន១ទាំងអស់ហ្នឹង ឡើងរទេះសេះចំនួនបួននាក់ កូន ហ្នឹងអត់ទាន់យក-- អត់ មីបងទៅនៅធ្វើការឆ្ងាយ ហើយឲ្យឈ្លបទៅយកមីបងហ្នឹងឲ្យមកឲ្យៗមក។ ហើយ សាន ហ្នឹង ហើយនិងកូនបួននាក់ហ្នឹង គេឲ្យដាក់រទេះសេះទៅមុន។ បាទ ខ្ញុំបាទឃើញ គឺឈ្លបឈ្មោះ ង៉ុយ ហ្នឹង។ ឈ្មោះ ង៉ុយ អ្នកទៅយក ហើយពីរនាក់ដែលខ្ញុំបាទអត់ស្គាល់ហ្នឹង គឺអ្នកនាំរទេះសេះទៅ។ ហើយឈ្មោះ ង៉ុយ ហ្នឹង អ្នកទៅយកកូនបងហ្នឹង កូនបង ឌុប១កង់ ឌុបកង់មក ហើយសាក្រោយ។ ប៉ុនថាប្រហែលជាទៅឆ្ងាយហើយបានកូនទៅៗតាមក្រោយ។ ឃើញច្បាស់ បាទៗ ខ្ញុំបាទឃើញច្បាស់។ បាទ កូនបងទី១ ឈ្មោះដាលីត។ ដាលីត កាលទៅនោះអាយុ១៤ឆ្នាំ – ដាលីត។ ហើយ ដាឡា នោះ អាយុ១២ឆ្នាំ កូនទី២។ កូនទី៣ ឈ្មោះ ស្រីម៉ៅ ១អាយុ៧ឆ្នាំ។ បើកូនទី៤នោះ អាយុវាអាយុ៣ឆ្នាំៗ កូនទី៤។ កូនទី៥ ២ឆ្នាំ កូនតូច មីតូចនៅកំពុងបៅ"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៤៤:០២]

ឡាច គ្រី ហ្នឹងគាត់បានផ្ដល់សក្ខីកម្មនៅក្នុងសវនាការយើងនេះអំពីការឈឺចាប់ទុក្ខវេទនារបស់បងប្រុសរបស់គាត់បន្ទាប់ពីគាត់បាត់បង់ប្រពន្ធ ហើយនិងកូន<ទាំងប្រាំ>របស់គាត់។ អ៊ីចឹង ខ្ញុំសុំស្នើឱ្យទស្សនាខ្សែ វីដេអូលេខ៣ ដែល ឡាច គ្រី នេះគាត់បាននិយាយ<>។

[១៣:៤៤:៣១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ខ្ញុំបាទអាចរៀបរាប់អំពីបងឈ្មោះ ឡាច នី ហ្នឹងបាន។ ព្រោះ ឡាច នី ហ្នឹង ដល់ដួលសន្លប់ហើយ គាត់ដើរប្រហែល២គីឡូ ដល់យប់ ប្រហែលជាម៉ោងប្រាំមួយល្ងាច គាត់វិលត្រឡប់មកវិញ មកផ្ទះវិញ។ មកផ្ទះគាត់ហ្នឹង ទៅជាហៅថាវិកលចរិត។ វិកលចរិតអស់រយៈប្រាំខែ គ្រាន់តែវិកលចរិតហើយដើរឱបតែប្រពន្ធគេ ដើរឱបតែកូនគេ។ គាត់ឆ្កួតគាត់ គាត់អត់ដឹង ឯណាលិចកើតទេ។ ដូច្នេះ ឡាច នី ហ្នឹង គឺថារយៈពេលប្រាំខែ គឺត្រូវវិកលចរិតប្រាំខែ។ ដើរអ៊ីចេះ គឺពេលដែលគាត់នឹកពេក កូនចេះតែហៅកូនៗ ប្រពន្ធគេ អូន ប្រពន្ធអ៊ីចឹង ហើយកូន កូនៗអ៊ីចឹង។ ប៉ុនថាពួកហ្នឹងគេដឹងៗគេមិនប្រកាន់គាត់ទេ ដឹងថាគាត់ហ្នឹងវិកលចរិតហើយ ពីព្រោះគេយកប្រពន្ធកូនទៅអស់ហើយ គាត់ចង់វិកលចរិត។ ដូច្នេះ ហើយគេថាគេមិនប្រកែប្រកាន់គាត់ទេ ចំពោះ ឡាច នី នេះ"។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៤៥:៣៥]

បាទ ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានផ្ដល់សក្ខីកម្មលើជោគវាសនានៃប្ដីរបស់គាត់ ដែលមានដើមកំណើតជាជនជាតិវៀតណាម ទេព <ជុយ> នេះគាត់បានបាត់ខ្លួននៅឆ្នាំ១៩៧៧។ ហើយដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន នេះមិនដែលបានឃើញប្ដីគាត់វិញទេ។ គាត់បានឆ្លើយនៅចំពោះមុខតុលាការយើងនេះ ខ្ញុំសូមដកស្រង់៖ គេឱ្យគាត់ទៅកាប់វល្លិរំពាក់។ ហើយក្រោយមកមិនដែលបានឃើញគាត់ទៀតទេ បាត់ឈឹងពីពេលហ្នឹងតែម្ដង។ អង្កាល់ហ្នឹងគឺរដូវច្រូតកាត់ ហើយកាលហ្នឹងខ្ញុំនៅស្រែនោះ ហើយខ្ញុំច្រូតកាត់ ហើយនៅពេលដែលខ្ញុំត្រឡប់មកផ្ទះវិញហ្នឹង គេយកគាត់ទៅបាត់ហើយ។ ខ្ញុំមិនដឹងថាគេយកគាត់ទៅកន្លែងណានោះទេ។ ខ្ញុំអត់ដឹងថាគាត់ទៅណាទេ។

បាទ ឥឡូវយើងចូលទៅនិយាយអំពីខេត្តស្វាយរៀងនៅឃុំចំលង ភូមិឫស្សីព្រៃ ដែលដើមបណ្ដឹង

រដ្ឋប្បវេណី សៀង ចាន់ថី រស់នៅទីនោះ។ សៀង ចាន់ថី នេះបានផ្តល់សក្ខីកម្មទាក់ទងទៅនឹងជោគវាសនានៃគ្រួសារពីរដែលមានដើមកំណើតជាជនជាតិវៀតណាមបាត់ខ្លួននៅឆ្នាំ១៩៧៧ នៅពេលដែលកូនស្រីរបស់ពួកគាត់ពីរនាក់ត្រូវបានរំលោភ។ ហើយគាត់បានផ្តល់សក្ខីកម្មទាក់ទងទៅលើការ ផលប៉ះពាល់នៃការបាត់បង់បុគ្គលទាំងអស់នេះ ហើយនិងទៅលើឳពុកម្តាយ -- របស់ឳពុករបស់គាត់ ដែលមានដើមកំណើតជាវៀតណាមដែរ។ អ៊ីចឹងខ្ញុំសូមស្នើឲ្យចាក់ខ្សែវីដេអូ លេខ៤ អំពីបញ្ហានេះ។

[១៣:៤៧:៣២]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"គេយកពីរគ្រួ -- គេយកគ្រួសារទី១ទៅ កូនស័ក្តិប្អូន ដែលម្តាយគាត់ជាជនជាតិវៀតណាម។ ពេលទុំងហើយដែលប៉ាខ្ញុំគាត់ពិបាកចិត្ត ព្រោះគាត់បានឃើញគេចាប់រំលោភកូនស្រីទាំងពីររបស់គ្រួសារវៀតណាម ដែលគេយកទៅ។ គាត់មកខ្សឹបប្រាប់ម្តាយខ្ញុំ ហើយម៉ែខ្ញុំថាអ្ហែងអើយ! ខ្ញុំឃើញគេចាប់រំលោភកូនស័ក្តិប្អូន ថុន។ ដូច្នេះ ខ្ញុំមិនចង់រស់ទេ។ ខ្ញុំសាច់ឈាមមិនដូចគេទេ សាច់ឈាមខុសគេ ខ្ញុំមិនឲ្យគេយកទៅទេ ព្រោះគេយកទៅសម្លាប់ឈឺណាស់។ ខ្ញុំប្រហែលជាអត្តឃាតហើយ។ [...] ចាស ខ្ញុំអាចរៀបរាប់បាន ព្រោះជនរងគ្រោះពីរនាក់ហ្នឹង គាត់ម្តាយគាត់ជាវៀតណាម។ ហើយគាត់រស់នៅក្នុងភូមិជាមួយគ្នាខ្ញុំ ហើយគាត់ទាំងពីរនាក់ធ្វើការរែកដីជាមួយខ្ញុំ។ ពេលដែល អឺ...គេចាប់គាត់យកទៅខ្ញុំអត់បានដឹងទេ ប៉ុន្តែគ្រាន់ថាបាត់គាត់ពីកន្លែងធ្វើការ ខ្ញុំក៏សួរ មិត្តភក្តិហ្នឹងខ្សឹបសួរ មិនមែនសួរឮៗទេ ខ្សឹបសួរគ្នាថា៖ អ្ហឺ! បងសាអែម ឌី ហើយនិង ស្រីទូច ទៅណាហើយ? គេថា៖ អ្ហឺ! គេយកទៅវាយចោលហើយ។ ដល់ពេលហ្នឹងខ្ញុំមកផ្ទះ មកផ្ទះពេលយប់បានឮសួរប៉ាខ្ញុំខ្សឹបប្រាប់ខ្ញុំទៀត គាត់ថាកូនអើយ ក្នុងភូមិយើងគ្រួសារស័ក្តិប្អូន ថុន ហ្នឹងគេយកទៅវៃចោលអស់ហើយ។ ដូច្នេះ ប៉ាខ្លាច។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៤៩:២៣]

បាទ ឪពុករបស់ សៀង ចាន់ថី ហ្នឹងគាត់បានធ្វើអត្តឃាត ពេលចុងក្រោយហ្នឹង ដោយសារគាត់គិតចង់ការពារកូនចៅគាត់ និង ប្រពន្ធគាត់។

ឥឡូវយើងនិយាយចូលទៅខេត្តក្រចេះ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ បានផ្តល់សក្ខីកម្មលើជោគវាសនារបស់ប្រពន្ធគាត់ ដែលជាជនជាតិវៀតណាមមានដើមកំណើតជាវៀតណាម ហើយនិងកូនប្រុសរបស់គាត់ដែលត្រូវបានសម្លាប់ខ្លួននៅខែកញ្ញា ឆ្នាំ១៩៧៨ នៅកោះក្បាល<ទ្រង់> សម្លាប់

ជាមួយនឹងស្ត្រីជនជាតិវៀតណាមផ្សេងទៀតជាមួយនឹងកូនរបស់<ពួក>គាត់ដែរ។ អ៊ុច ស៊ុនឡាយ នេះគាត់ពន្យល់នៅក្នុងខ្សែវីឌីអូលេខ៥នេះ អំពីកាលៈទេសៈ<ដែលគាត់បានដឹងអំពី>ការស្លាប់របស់ប្រពន្ធរបស់គាត់ និងកូនៗរបស់គាត់។ សូមអនុញ្ញាតចាក់លោកប្រធាន។

[១៣:៥០:២០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"នៅពេលដែលគេសម្លាប់កូនក្មេងនេះ កូនខ្ញុំបាទហ្នឹងមានបីនាក់ គឺប្រុសពីរនាក់ ស្រីមួយនាក់។ កូនច្បងឈ្មោះ សុធីរ៉ា អាយុ៨ឆ្នាំ កើតឆ្នាំ៧០ មកទល់នឹង៧៨។ កូនបន្ទាប់ឈ្មោះ សុធីរៈ កើតឆ្នាំ១៩៧៥។ រីឯកូនប្អូនឈ្មោះ សុធីតា ប្រហែលជាជាងមួយខួបប៉ុណ្ណោះទេបាទ ជា -- ឈ្មោះ មឿន និងគណៈសហករណ៍ហ្នឹងបានចាត់តាំងពួកក្រុម ដែលជាមានប្រពន្ធជាកូនកាត់វៀតណាម ចៅកាត់វៀតណាមនោះឲ្យទៅកាប់ឫស្សីបង្គោងត្នោតនៅឯអូរឬស្សង ដែលមានរយៈពេលធ្វើដំណើរហ្នឹង មិនតិចពី២យប់ទេតាមរយៈការចែវទូក។ ខ្ញុំបាទ ក៏ទៅជាមួយនឹងគេហ្នឹង ក៏ប៉ុន្តែដែលក្ដុកក្ដួលខ្លាំងមែនទែននោះ គឺពេលដែលត្រឡប់មកវិញ គណៈសហករណ៍បានហៅអ្នកទាំងនោះ រួមទាំងខ្ញុំបាទផង ដើម្បីមកទទួលការអប់រំសតិអារម្មណ៍។ ពេលនោះ ដែលឈ្មោះ មឿន គណៈសហករណ៍ បានក្រោកឡើងនិយាយថា សមមិត្តមានគុណសម្បត្តិខ្ពស់ណាស់ជាមួយនឹងបក្សវណ្ណៈកម្មករយើង។ សមមិត្តបានខិតខំបំពេញការងារ កម្លាត់ធាតុដើម លះបង់ខ្ពស់ជូនបក្សវណ្ណៈកម្មករ កសិករ។ តែប្រពន្ធកូនរបស់មិត្ត យើងខ្ញុំបានប្រមូលទៅទុកម្ដុំហើយ សូមសមមិត្តកាត់សាច់ស្អុយនេះចេញចុះ!"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៥២:២៤]

ដើមបណ្ដឹងរដ្ឋប្បវេណីបួននាក់បានពិពណ៌នាអំពីការសម្លាប់នេះដែលមានយកស្ត្រីជនជាតិវៀតណាម ហើយនិងកូន<របស់ពួក>គាត់ជាគោលដៅ ដែលយើងៗអាចហៅថាជាទ្រឹស្ដី<ខ្សែខាង>ម្ដាយ<>។ <តាមការគូសបញ្ជាក់នេះ លោក> ឡាច គ្រី ហើយនិង ដួង អឿន បាននិយាយអំពីជោគវាសនាដែលគេកំណត់ទុកឲ្យ<ប្រពន្ធ>របស់<ឡាច នី និង>ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ប្រាក់ ឌឿន ដែលរស់នៅកំពង់ឆ្នាំង ហើយប្រពន្ធគាត់មានដើមកំណើតជាវៀតណាម កូនគាត់ទាំងអស់ហ្នឹងក៏ត្រូវបានសម្លាប់នៅ<>ចុងឆ្នាំ១៩៧៧។ ហើយ<ចុងក្រោយ>ដើមបណ្ដឹងរដ្ឋប្បវេណីលេខ៤នោះ អ៊ុច ស៊ុនឡាយ ហ្នឹងក៏បានពន្យល់អំពីទ្រឹស្ដីដែលថាម្ដាយជាខ្សែវៀតណាមហ្នឹងផងដែរ <ហើយគាត់បានពន្យល់

ថា>ប្រពន្ធ ហើយនិងកូនរបស់គាត់ត្រូវបានសម្លាប់នៅចុងឆ្នាំ១៩៧៨ <ក្នុងខេត្តក្រចេះ> ដោយសារប្រពន្ធគាត់ជាជនជាតិវៀតណាម។ អ៊ីចឹង<ខណៈពេលនេះ> យើង<នឹងស្ដាប់នូវ>សម្រង់ទាំងបួនហ្នឹង គឺសុទ្ធតែបង្ហាញអំពីថាម្ដាយហ្នឹង មានដើមកំណើតជាជនជាតិវៀតណាមទាំងអស់។ ឥឡូវសូមបញ្ចាំងខ្សែវីដេអូទី៦។

[១៣:៥៣:៤៥]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[ប្រជាជន ក៏ដូចរូបខ្ញុំបាទដែរ អាចដឹងៗថា បើសិនជាប្ដីហ្នឹងខ្មែរ គឺអត់មានយកកូនទៅមុនរួចទេ អត់មានទេ។ ហើយប្ដី -- ប្រពន្ធហ្នឹងវៀតណាមគឺទាំងកូន ទាំងប្រពន្ធយកទៅ។ ហើយបើសិនជាប្ដីហ្នឹងវៀតណាម ប្រពន្ធហ្នឹងខ្មែរ គឺយកតែប្ដីទេ អត់មានយកកូនទេ។*

*ថាម៉ែយួន គេយកទៅហ្នឹង។ ឲ្យតែម៉ែយួនគេយកទៅហើយ។ តែមួយគេមិនទុកឲ្យផង។ គេវាមកចាប់មែន កាលហ្នឹងអត់មានអ្នកណាយកទៅទេ ខ្មែរកូនខ្មែរ អ៎! ម៉ែខ្មែរ កូន -- ម៉ែអត់យកទៅទេ គេយកទៅតែឪពុកទេ បានតែកូនខ្ញុំនៅនោះ បើគេយកទៅៗទាំងអស់ហើយ។ ចេះតែលោភ ចេះតែបិទបាំងអ៊ីចឹងដែរ។ ជនជាតិវៀតណាមនោះ យកទៅទាំងអស់ហើយ វាមិនទុកទេជំនាន់ហ្នឹងនោះ។ ប៉ុន្តែទាស់ម៉ែខ្មែរ យកតែប្ដីទៅៗ។*

*នែ៎! ជនជាតិវៀតណាម គេធ្វើយកប្ដីទៅសម្លាប់ តែបើជនជាតិខ្មែរយើង គេម្ដាយនៅរស់អ៊ីចឹងដែលគេអត់ឲ្យទៅជាមួយកូននុ៎ង ក៏នៅរស់ដែរបាទ។*

*អរគុណ។ ខ្ញុំបាទហ្នឹងច្បាស់ហើយថា ប្រពន្ធនឹងកូនជាវៀតណាម។ ដូច្នេះកូនហ្នឹង គឺជាចៅកាត់វៀតណាម ពីព្រោះទ្រឹស្ដីរបស់មេដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង បានផ្សព្វផ្សាយទៅដល់ថ្នាក់ក្រោមទាំងអស់ថា ជីកស្មៅ ត្រូវជីកទាំងឫស។ បានន័យថា បើយកប្រពន្ធ និងកូនដែលជាចៅកាត់វៀតណាម អាចៅទួត ចៅលួត ចៅអីក៏ដោយ ក៏ជាវៀតណាម ជាខ្មែរ កា.ហ្សេ.បេ ទាំងអស់ដែរ បាទ។]*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៥៦:២៧]

ឥឡូវ ខ្ញុំសូមចូលនិយាយអំពីបទបញ្ញាស្ដីអំពីការរៀបការ អង្គជំនុំជម្រះបានទទួលបណ្ដឹងអំពីអង្គហេតុទាក់ទងទៅនឹងការរៀបការបុរស និង ស្ត្រីនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នៅទូទាំង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រទេសកម្ពុជាតែម្តង។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៥នាក់ បានផ្តល់សក្ខីកម្មទៅលើអង្គហេតុទាំងអស់នេះនៅក្នុងសវនាការ។ ដើមបណ្តឹងរដ្ឋប្បវេណី១២នាក់ បានផ្តល់សក្ខីកម្មនៅក្នុងវគ្គទាក់ទងនឹងការរៀបការនេះតែម្តង។ ដើមបណ្តឹងរដ្ឋប្បវេណីប្រាំបីនាក់ បានត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មទៅលើអង្គហេតុ<>ផ្សេងទៀត ត្រូវបានស្តាប់ពាក់ព័ន្ធទៅនឹងការរៀបការរបស់ខ្លួនគាត់ផ្ទាល់ ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីប្រាំនាក់ទៀត <និង>បានផ្តល់សក្ខីម្មទាក់ទងទៅនឹងការរៀបការ<របស់ពួកគេផ្ទាល់តែម្តង។ ហើយដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំនាក់ បានមកផ្តល់សក្ខីកម្មអំពីការរៀបការរបស់សាច់ញាតិ>របស់<ពួក>គាត់។ អ៊ីចឹង<ហើយ សក្ខីកម្មរបស់>ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៥នាក់ <ត្រូវបានវិភាគ ដាក់ចូលទៅក្នុងសារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់យើង និង>ការរៀបការដោយពិពណ៌នានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ គឺមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៧នាក់ ដែលបាននិយាយអំពីរៀបការដែលកើតឡើងនៅផ្នែកទី២ នៃរបបកម្ពុជាប្រជាធិបតេយ្យ គឺពីឆ្នាំ១៩៧៧ និង ១៩៧៨។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំពីរនាក់ បានរៀបការនៅក្នុងពិធីមួយដែលមានរៀបការទាំងអស់៣០គូ។ ការរៀបការទាំងអស់នេះ គឺកើតឡើងនៅក្នុងភូមិភាគទាំងអស់តែម្តង គឺភូមិភាគកណ្តាល ភូមិភាគបូព៌ា ភូមិភាគពាយ័ព្យ ភូមិភាគឧត្តរ ភូមិពាយ័ព្យ ភូមិភាគនិរតី ហើយនិងតំបន់<ស្វយ័ត>ភ្នំពេញ តំបន់១០៥ តំបន់ស្វយ័តមណ្ឌលគិរី។ អ៊ីចឹងទាំងអស់ ដើមបណ្តឹងរដ្ឋប្បវេណី<ទាំងនោះ មានស្ត្រី>អាយុប្រហែលជា២០ឆ្នាំ ហើយបុរសវិញ ២៥ឆ្នាំ។ មុននឹងចូលដល់ការរៀបរាប់នេះ ខ្ញុំសូមនិយាយពីបញ្ហាច្បាប់បន្តិចសិន តើយើងនិយាយអំពីបទឧក្រិដ្ឋណាច្បាស់តែម្តង? តើធាតុផ្សំណាដែលត្រូវបង្ហាញឲ្យហួសពីវិមតិសង្ស័យ។

[១៣:៥៨:៥៤]

បើបញ្ហាទាំងអស់នេះចោទឡើង ពីព្រោះថាបើយើងដឹងតាំងពីដើមនៃការជម្រះសេចក្តីនេះហើយ គឺថាការរៀបការជាឧក្រិដ្ឋនោះ គឺថាអាចកើតមានឡើងនៅក្រោមទម្រង់មួយគេហៅថា អំពើអមនុស្សធម៌ផ្សេងៗទៀត។ អង្គជំនុំជម្រះ<តុលាការកំពូល>បានបំភ្លឺពីធាតុផ្សំនៃឧក្រិដ្ឋកម្មនេះ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងបណ្តឹងឧទ្ធរណ៍នៅសំណុំរឿង០០២/១ <ក្នុងខណៈវគ្គនៃការរៀបការនេះ ត្រូវបានបិទបញ្ចប់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ>។ អង្គជំនុំជម្រះ<តុលាការ>កំពូលបានពន្យល់ថា មិនសមហេតុផលទេ នៅក្នុងកំណត់ប្រភេទបទល្មើស ឬក៏បទឧក្រិដ្ឋ ដូចជានៅ ថានៅក្នុងសំណុំរឿង <០០២/០១> ឧក្រិដ្ឋកម្មជម្លៀស<ប្រជាជន>ដោយបង្ខំ <ក៏ដូចជា>ឧក្រិដ្ឋកម្មដែល<ធ្វើ>

ឲ្យបាត់ខ្លួនដោយបង្ខំ <ដែលមើលទៅធាតុផ្សំទាំងអស់នោះ>មិនទាន់លេចឡើង<ឲ្យច្បាស់>នៅឆ្នាំ ១៩៧៥<នៅឡើយទេ>។

អ៊ីចឹង <ហេតុផលដូចគ្នានេះ ត្រូវយកមកអនុវត្តចំពោះបញ្ហាដែលយើងមានបច្ចុប្បន្ន គឺបញ្ហាការរៀបការ។ ដូច្នេះ វាជា>សំខាន់ណាស់<ក្នុងការលម្អិតការបង្ហាញផ្លូវ ដែលផ្ដល់ដោយ>អង្គជំនុំជម្រះ<តុលាការកំពូល ហើយត្រូវមើលថាតើការ>បង្ហាញផ្លូវយើងឲ្យធ្វើយ៉ាងម៉េច ហើយទាក់ទងទៅនឹងការពន្យល់ហេតុផលនៃ<ការ>យកច្បាប់មកអនុវត្តទាក់ទងនឹងការរៀបការនេះ យើងធ្វើយ៉ាងណាដែរ។ អង្គជំនុំជម្រះតុលាការកំពូលគាត់បានពន្យល់ថា សញ្ញាណនៃអំពើអមនុស្សធម៌នេះ តើវាមានទំនាក់ទំនងយ៉ាងម៉េច និងអត្តចរិតយ៉ាងម៉េចនៅក្នុងសំណុំរឿង០០២/១នេះ។ ឧទាហរណ៍ ដូចការជម្លៀសលើកទី១ ក៏គេយល់ឃើញថា មានអត្តចរិត ឬក៏លក្ខណៈដូចគ្នាដែរ។ ចំពោះបញ្ហារៀបការ--

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីទេ?

*(មានបញ្ហាបច្ចេកទេស)*

បាទ អញ្ជើញជាបន្តទៀតបាទ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

អំមិញហ្នឹង ខ្ញុំបាននិយាយអំពីអ្វី -- សេចក្ដីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលដែលគាត់និយាយអំពីការបែងលំដាប់ថ្នាក់ទាក់ទងនឹងការរៀបការ។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ -- ខ្ញុំឃើញចៅក្រម ហ្វេនស៍ -- តុលាការកំពូលបានពន្យល់ថា សញ្ញាណនៃអំពើអមនុស្សធម៌ផ្សេងៗទៀតនេះគឺវាពាក់ព័ន្ធទៅនឹងគេហៅការប្រព្រឹត្ត ឬក៏ចរិតលក្ខណៈ ទាក់ទងទៅនឹងការជម្លៀសទី១ – ជម្លៀសដំណាក់កាលទី១ ឬជម្លៀសលើកទី២ ហ្នឹងវា<បង្កើតបាន>ជាការប្រព្រឹត្តមួយហើយ។ ហើយទាក់ទងទៅនឹងការរៀបការនេះ គេហៅថា ការប្រព្រឹត្តដែលអង្គជំនុំជម្រះសាលាដំបូងនេះត្រូវពិចារណាហ្នឹង គឺទាក់ទងទៅនឹងបទបញ្ជានៃការរៀបការដែលជាការប្រព្រឹត្តមួយដែលភាគីទាំងអស់ទទួលស្គាល់ទាំងអស់ក្រុម នួន ជា ក៏ដោយ ក្រុម ខៀវ សំផន ក៏ដោយ មិនដែលបានជំទាស់<លើអង្គហេតុ>ថា បក្សកុម្មុយនីស្តកម្ពុជាបានចេញបទបញ្ជាស្ដីអំពីការរៀបការនេះទេ។

[១៤:០២:២០]

ចំណុចទី២ នៃការ<បង្ហាញផ្លូវ>របស់<អង្គជំនុំជម្រះ>តុលាការកំពូល <គឺបានពន្យល់>ថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ត្រូវតែវិភាគទាំងមូលតែម្តង រឿងរ៉ាវទាំងមូលតែម្តង<លើធាតុផ្សំនៃការប្រព្រឹត្ត>។ ដូច្នេះ យើងយល់ឃើញថា ការប្រព្រឹត្តទាក់ទងទៅនឹងការចេញបទបញ្ជានឹងការរៀបការនេះ ធាតុផ្សំផ្សេងៗទៀតដែលអង្គជំនុំជម្រះសាលាដំបូងត្រូវតែយកមកវិភាគនោះគឺមានដូចតទៅនេះ ទី១ គឺការចូលទៅរៀបការ<គឺជា>ការចាប់ផ្តើមរៀបការគឺថា <ដោយ>បរិយាកាសដែលសម្រេចឲ្យរៀបការ ហើយលទ្ធភាពដែលៗនៃការបដិសេធ ឬមិនជំទាស់ ហើយនិងអត្ថិភាពនៃការដាក់ទណ្ឌកម្មចំពោះអ្នកដែលជំទាស់មិនព្រមរៀបការ ឧទាហរណ៍ដូចជា ការធ្វើបាប ឬក៏រំលោភ ឬការធ្វើឲ្យបាត់ខ្លួនជាដើម។ ចំណុចទី២ នៃការប្រព្រឹត្តនេះគឺថា បញ្ហារើសគូស្រករនោះ ថាតើមានសិទ្ធិរើសគូស្រករដែរឬទេ ហើយនិងកម្រិតនៃការត្រួតពិនិត្យរបស់អង្គការទៅលើដំណើរការនេះ។

ចំណុចទី៣ នៃការប្រព្រឹត្តនេះ គឺពិធីរៀបការផ្ទាល់តែម្តង។ អ៊ីចឹងត្រូវដឹងថាតើ គូស្រករនោះមានដឹងថាខ្លួនបានរៀបការជាមុនដែរឬទេ? ហើយតើគាត់ស្គាល់អត្តសញ្ញាណគូស្រកររបស់ខ្លួនដែរ ឬទេ? តើគ្រួសាររបស់គាត់មានអាចចូលរួមក្នុងពិធីនេះដែរបានឬទេ? តើអង្គការមានតួនាទីអ្វីខ្លះនៅក្នុងការរៀបការនេះ? តើគូស្រករនោះ ត្រូវតែប្តេជ្ញាចំពោះអង្គការដែរឬទេ? តើមានការបន្តការប្រណិប័តន៍ប្រពៃណី ទាក់ទងទៅនឹងការរួមដំណេកអីនោះដែរឬទេ? ចំណុចទី៤ ត្រូវគិតដែរ គឺទំនាក់ទំនងរវាងគូស្រករក្រោយពេលដែលរៀបការហើយ គឺ ឧទាហរណ៍ដូចជាថា គូស្រករត្រូវជួបគ្នា ហើយមានគេតាមឃ្លាំមើលគូស្រករហ្នឹង តើដើម្បីឲ្យគាត់ផ្សំដំណេក ហើយនិងការ<ដាក់ពិន័យ>ផ្សេងៗទាក់ទងទៅនឹងការជំទាស់<>មិនផ្សំដំណេក ហើយនិងការដាក់ទណ្ឌកម្មទៅលើអ្នកដែលមិនព្រមរួមដំណេក។ ហើយបន្ទាប់មកគឺការរួមដំណេកហ្នឹង តើត្រូវធ្វើយ៉ាងម៉េចដែរ។

[១៤:០៥:00]

ចំណុចទី៥ គឺ<ចំណុចចុងក្រោយគេ គឺ>ផលវិបាកនៃការរៀបការហ្នឹង។ គឺថាមានទម្ងន់ ហើយនិងរលូតកូន។ អ៊ីចឹងយើងឃើញថា<>ឧក្រិដ្ឋនៃអំពើអមនុស្សធម៌ ទាក់ទងទៅនឹងការចេញបទបញ្ជាឲ្យរៀបការ គឺមានទម្រង់ភាពទូលំទូលាយជាងបញ្ហានៃការ<យល់ព្រម>រៀបការ <ឬក៏អ្វីដែលយើងសំដៅថាជាការរៀបការដោយបង្ខំ>នេះទៅទៀត។

ចំណុច<ទី៣ នៅក្នុងការបង្ហាញផ្លូវរបស់អង្គជំនុំជម្រះ>តុលាការកំពូល<គឺមានដូចតទៅ៖> គឺអង្គជំនុំជម្រះសាលាដំបូង<នឹង>ត្រូវ<កំណត់អំពីសិទ្ធិ ហើយ>អង្គ<ជំនុំជម្រះ>តុលាការកំពូលបាននិយាយថាត្រូវការផ្សារភ្ជាប់គ្នារវាង<សិទ្ធិ> និងការហាមឃាត់នៅក្នុងបរិបទច្បាប់ ដែលជាធរមាននៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្នុងឆ្នាំ១៩៧៥ ដែលរំលោភបំពានដោយ<ការប្រព្រឹត្តនៃការចេញបទបញ្ជារៀបការនេះ>។ <អង្គជំនុំជម្រះតុលាការកំពូល បានផ្តល់ឧទាហរណ៍ អំពីអត្ថបទច្បាប់មួយចំនួនធំ ដែលមានជាធរមាននៅក្នុងឆ្នាំ១៩៧៥ ហើយក៏>ដូចជាមានសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្សនៅឆ្នាំ១៩៤៨ជាដើម។ អ៊ីចឹងបើយើងគិតពីសេចក្តីប្រកាសនេះ គឺថាមានមាត្រា<៣> ដែលថាមនុស្សទាំងអស់ហ្នឹងមានសិទ្ធិរស់<រស់រានមានជីវិត> សេរីភាព ហើយនិងមានសុវត្ថិភាព<របស់បុគ្គល>។ មាត្រាទី៥ និយាយចែងថា គ្មានអ្នកណាត្រូវបានគេបង្ខំឱ្យធ្វើទារុណកម្ម ការប្រព្រឹត្តលើខ្លួន ឬក៏ការដាក់ទណ្ឌកម្មឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ។ មាត្រា១២ថា គ្មានមនុស្សណាមិនត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្តក្នុងជីវិតឯកជន និង<ជីវិត>គ្រួសារទីលំនៅ<>។ មាត្រាទី១៦<> អាពាហ៍ពិពាហ៍នឹងអាចប្រព្រឹត្តិទៅបានលុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតទាំងសងខាង។

[១៤:០៧:១៤]

ចំណុចទី៤ នៃការណែនាំរបស់តុលាការកំពូលនោះ ទាក់ទងទៅនឹងកម្រិតនៃភាពធ្ងន់ធ្ងរនៃការរំលោភបំពាន ដើម្បីឱ្យដឹងថាតើវាមានធាតុផ្សំគ្រប់គ្រាន់ ដើម្បីឱ្យកើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬទេ។ ដើម្បីឱ្យយល់ពីចំណុចនេះ អង្គតុលាការកំពូលបានឱ្យយើងបង្កើតជានិយាមមួយ ដែលយើងគួរតែគិតអំពីមាត្រាទី១៦ ស្តីអំពីការព្រមព្រៀងគ្នាដោយសេរី ហើយនិងពេញលេញ និងការរៀបការ។ <អង្គជំនុំជម្រះអាចពិចារណា អនុសញ្ញាអន្តរជាតិ>ស្តីអំពីសិទ្ធិមនុស្ស <ស្របតាមសេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស ដែលបានចែងគ្រប់សិទ្ធិទាំងអស់ និងសេរីភាពព្រមព្រៀងរៀបការរួមបញ្ចូលទាំងអនុសញ្ញាអន្តរជាតិ>នៃអង្គការសហប្រជាជាតិនៅឆ្នាំ<១៩៦៦> ហើយនិងការអនុសញ្ញាស្តីអំពីការបំបាត់នូវការរើសអើសប្រឆាំងនឹងស្ត្រី។ អ៊ីចឹងអង្គជំនុំជម្រះ<ក៏អាចស្វែងរកអត្ថបទច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៃ>ការបង្ខំរៀបការ <នៅក្នុងយុត្តិធិការជាតិ>ក្រោយឆ្នាំ១៩៧៥ ក៏ដូចជាយុត្តិសាស្ត្រនៃតុលាការពិសេស សម្រាប់ប្រទេសសៀរ៉ាលេអូន <ក្នុងសំណុំរឿងស៊ីសេ>។ អ៊ីចឹងនៅចុងក្រោយអង្គជំនុំជម្រះត្រូវតែគិតថាតើការរំលោភទាំងអស់នេះបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរផ្នែកផ្លូវកាយ និងផ្លូវចិត្តដែរឬទេ ជាការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើរូបរាងកាយ និងភាពថ្លៃថ្នូរនៃមនុស្សដែរឬទេ។

[១៤:០៨:៥៣]

ការផ្តល់សក្ខីកម្ម<>និងការផ្តល់<កំណត់ហេតុនៃការស្តាប់ចម្លើយ>ដែលអស់លោក លោកស្រីចៅក្រម បានស្តាប់ពីរឆ្នាំកន្លងមកនេះ បង្ហាញឱ្យឃើញកាន់តែច្បាស់ថាមានការប៉ះពាល់ និងធ្វើទៅដល់

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

រូបរាងកាយ ហើយនិងធ្វើឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈឺចាប់ខ្លាំង ដោយថាបង្ខំឲ្យរៀបការនេះ។ អ៊ីចឹងត្រូវធ្វើយ៉ាងណា តើពិចារណាថា តើមានធាតុផ្សំណាខ្លះដែលអាចយកមកគិតបានចំពោះអង្គជំនុំជម្រះដែលកើតចេញពីការ <>បទបញ្ជាការរៀបការនេះ។ ហើយមានចំណុចមួយដែលយើងនិយាយញឹកញាប់ដែរ ថាការរៀបការដោយសម្របសម្រួល ហើយនិងការរៀបបង្ខំ។ ខាងមេធាវីការពារក្ដីបាននិយាយថា ការរៀបការនៅកម្ពុជាប្រជាធិបតេយ្យនេះគ្រាន់តែជាការរៀបការដោយសម្របសម្រួលគ្នាទេ អង្គការគ្រាន់តែជំនួសតំណែងរបស់ឪពុកម្ដាយក្នុងការរៀបចំកូនចៅនោះទេ ផ្សំផ្គុំ ហើយមេធាវីការពារក្ដីថា បើយើងគិតអ៊ីចឹងថាអាហ្នឹងជាឧក្រិដ្ឋនោះ អាហ្នឹងគឺបានន័យថា បំបិទការផ្សំផ្គុំកូនចៅចោលតែម្ដងទៅ។

នៅក្នុងការរៀបការដោយផ្សំផ្គុំនេះ គឺគូស្រករគេហ្នឹងគេយល់ស្របគ្នា គេប្រទានសិទ្ធិនេះប្រគល់សិទ្ធិនេះទៅឲ្យឪពុកម្ដាយខ្លួនដើម្បីរៀបការ។ អ៊ីចឹងហើយបានយុត្តិសាស្ត្រទាក់ទងនឹងសិទ្ធិមនុស្សនេះយល់ឃើញថា ការរៀបការដោយផ្សំផ្គុំនោះមិនល្មើសនឹងមាត្រាទី១៦ នៃសេចក្ដីប្រកាសជាសាកលនៃសិទ្ធិមនុស្សនោះទេ នៅពេលដែលគូស្រករទាំងអស់គ្នានោះយល់ស្រប។ នៅក្នុងប្រពៃណីបុរាណក៏ដោយ នៅពេលដែលគេគ្រួសារជាអ្នកមានសិទ្ធិផ្សំផ្គុំកូនចៅ ប៉ុន្តែនៅពេលមានភាគីណាម្នាក់ហ្នឹងមិនព្រម គឺបានន័យថាការរៀបការដោយបង្ខំហើយ។ អ៊ីចឹងបានន័យថា វាជាការរំលោភបំពានទៅលើមាត្រា១៦ហើយ។ អ៊ីចឹង ដូច្នេះនៅពេលដែលអង្គជំនុំជម្រះធ្វើសេចក្ដីសម្រេចគេត្រូវសួរខ្លួនឯងថា តើគូស្រករទាំងអស់គ្នានោះមានបានផ្ដល់សិទ្ធិទៅអង្គការហ្នឹងឲ្យគេរៀបការឲ្យខ្លួនទេ គាត់ព្រមដោយពេញចិត្ត ដោយពេញលេញដែរឬទេ? អត់ទេ។

[១៤:១១:៣៩]

យើងធ្វើការងារនេះមិនមែនដោយរំភើបទេ យើងមិនធ្វើការជាអ្នក ដែលគេហៅថា ឈានមុខដូចអង្គការមួយចំនួន ក្រៅរដ្ឋាភិបាលមួយចំនួនទេ យើងគ្រាន់តែធ្វើតាមលក្ខណៈមូលដ្ឋានដែលតិចតួចបំផុតដើម្បីជួយដល់អង្គជំនុំជម្រះពេលធ្វើសេចក្ដីសម្រេច ហើយយើងបានយកសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងធាតុផ្សំមួយចំនួនដែលផ្សំកើតចេញជាអំពើឧក្រិដ្ឋកម្មផ្សេងៗ<ស្របគ្នាទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលដែរ>។ អ៊ីចឹង ខ្ញុំនៅទីនេះ ខ្ញុំយល់ឃើញថា ការចេញបញ្ជាដោយការរៀបការដោយបង្ខំ<នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ>នេះ -- ការរៀបការនេះ គឺជាធាតុផ្សំនៃឧក្រិដ្ឋកម្ម នៃអំពើអមនុស្សធម៌ផ្សេងៗ។ អ៊ីចឹងខ្ញុំយល់ឃើញយ៉ាងដូច្នេះ ហើយខ្ញុំសង្ឃឹមថាអស់លោក

លោកស្រីចៅក្រមនោះក៏ឃើញដូចខ្ញុំដែរ។ ដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀតនិយាយតែអំពីអត្ថិភាពនៃបរិយាកាសភ័យខ្លាច<កើតមាននៅសម័យនោះ។> សញ្ញានេះសំខាន់ណាស់ តើអង្គជំនុំជម្រះនឹងយល់ឃើញយ៉ាងណាថា បរិយាកាសនេះធ្វើ <បង្កើត>ជា<ស្ថានភាព>បង្ខំដែរឬទេ ហើយវាជំរុញឲ្យមានការព្រមរៀបការហ្នឹងដោយពេញចិត្ត ដោយចិត្តឯងដែរឬទេ។ នៅក្នុង<សវនាការជំនុំជម្រះក្ដីសំណុំរឿង អាកៃយ៉េសុ នៅចំពោះមុខ>តុលាការរ៉វាន់ដាបានចេញសេចក្ដីសម្រេចថា ការ<បង្ខិតបង្ខំ ដែលអាចមានជាប់ទាក់ទងនៅក្នុងកាលៈទេសៈ>មួយចំនួន <រួមបញ្ចូលទាំងនៅ>ក្នុងកាលៈទេសៈសង្គ្រាម ឬក៏ជម្លោះប្រដាប់អាវុធជាដើម។

ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន គឺជាអ្នកទទួលបន្ទុកមន្ទីរស្រុកស្អាងខេត្តកណ្ដាល ភូមិភាគនិរតី តាមរយៈមុខងាររបស់គាត់ ៗមានតួនាទីនៅក្នុងការរៀបចំការរៀបអាពាហ៍ពិពាហ៍។ សេង សឿន ជាទាហានពិការ ហើយគាត់ត្រូវបានរៀបការនៅខែកញ្ញា ឆ្នាំ១៩៧៧ បន្ទាប់ពីគាត់បានបដិសេធបីដងរួចមកហើយ។ គាត់បានរៀបរាប់អំពីបរិយាកាសភ័យខ្លាចដែលកើតមាននៅសម័យនោះ ហើយនិងរៀបរាប់ថា តើវាមានផលប៉ះពាល់អ្វីខ្លះនៅពេលដែលអ្នកណាម្នាក់ប្រកែកមិនព្រមរៀបការនោះ។ ដូច្នេះ ខ្ញុំសូមចាក់បញ្ចាំងវីដេអូលេខ១។

[១៤:១៤:១៧]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"អារឿងសម័យនោះ គឺខ្ញុំពិបាកនឹងជម្រាបថា ខ្លាចអី រឿងអីនោះ។ មួយ ក្រោមការដឹកនាំរបស់គេ។ ហើយសម័យនោះពិបាកណាស់ស្រួលមិនស្រួលហ្នឹងងាប់ បាត់ខ្លួន មិនដឹងជាស្អីៗ អាមិនថាឋានៈអីៗ តែមិនស្រួលបាត់ ហើយអ៊ីចឹងចេះតែគិតទៅអ៊ីចឹង។ អើ! ថាឲ្យយក ក៏យកទៅអាហ្នឹង ខ្ញុំបានគិតថាអ៊ីចឹងទេសម័យនុ៎ង។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:១៥:០៥]

ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម ជាទាហានខ្មែរក្រហម។ គាត់ជាជនជាតិភាគតិច។ គាត់បានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ១៩៧៧។ ហើយក្នុងពិធីនុ៎ងមាន២៩គូផ្សេងទៀត ដែលរៀបចំនៅមន្ទីរ ក-១១ នៅក្នុងភូមិភាគស្វយ័តមណ្ឌលគិរី។ ដើមបណ្ដឹងរដ្ឋប្បវេណី គាត់មិនបាន -- គាត់ត្រូវបានគេប្រាប់ថា គាត់នឹងត្រូវរៀបការតែប៉ុន្មានថ្ងៃ មុនពេលរៀបការតែប៉ុណ្ណោះ ហើយប្រពន្ធគាត់នោះជាជន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាតិពួង។ កុល ណែម គាត់មានគូដណ្ដឹងរួចទៅហើយនៅក្នុងស្រុកកំណើតរបស់គាត់ ហើយគាត់បានពន្យល់ជូនអង្គជំនុំជម្រះអំពីផលប៉ះពាល់នៃបរិយាកាសភ័យខ្លាចជាទូទៅដែលកើតមាននៅសម័យនោះទៅលើលទ្ធភាពក្នុងការប្រកែកមិនព្រមរៀបការ។ ដូច្នេះសុំការអនុញ្ញាតបញ្ចាំងវីដេអូលេខ២។

[១៤:១៦:០០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ហ្នឹងហើយ ពីណាក៏ដឹងដែរជំនាន់ហ្នឹង ព្រោះអីខ្ញុំចេញពីកន្លែងកងពល គេបញ្ជូនមក ខ្ញុំដឹងថាមេគេចាប់ហើយ ហ្នឹងហើយ។ ឈិន សយ គេចាប់ហើយ។ មកដល់នេះទៀត គេកៀបទៀត មិនដឹងយ៉ាងម៉េច គេធ្វើយ៉ាងម៉េច បានខ្លាចទាំងអស់គ្នា។ អ្នកណាក៏ខ្លាចដែរ មិនមែនតែខ្ញុំម្នាក់ទេ។ បាទ ត្រូវគោរពគេទាំងអស់។ ហ្នឹងហើយ យោបល់ខ្ញុំប៉ុណ្ណឹង។ បើមិនខ្លាចគេ ការធ្វើអី បើយើងនេះ។ ប៉ុន្តែយើងខ្លាចគេ សុខចិត្តយើងស្រប បាទ។ បើមិនចេញពីគំនិតណ៎ា បើទម្លាប់អ៊ីចឹងរហូតហើយ។ ឃើញថាឲ្យតែមានបញ្ហាខុសបន្តិចបន្តួច គឺគេចាប់យកទៅតែម្ដងបាទ។ ចាប់ទៅច្រើនណាស់។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:១៦:៥៣]

ដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនបាននិយាយថា ខ្លួនមិនដឹងអំពីការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន មិនដឹងពីថ្ងៃដែលត្រូវរៀបការ មិនដឹងអំពីអត្តសញ្ញាណនៃគូស្រករបស់ខ្លួនទេនៅមុនពេលរៀបការនោះ។ ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុខឿន មានអាយុ១៨នៅពេលដែលគាត់ត្រូវបានគេរៀបការឲ្យជាមួយនឹងទាហានពិការដៃ ហើយនិងពិការភ្នែក។ ការរៀបការរបស់គាត់គឺប្រព្រឹត្តទៅនៅឆ្នាំ១៩៧៧ ជាមួយនឹង១៥គូផ្សេងទៀតនៅក្នុងចម្ការកប្បាសនៅស្រុកព្រៃឈរ ភូមិភាគកណ្ដាល។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមិនបានដឹងអំពីថ្ងៃរៀបការ ឬក៏ដឹងអំពីអត្តសញ្ញាណនៃគូស្រកររបស់គាត់ទេ។ គាត់បានពន្យល់ជូនអង្គជំនុំជម្រះដូចតទៅ គឺនៅក្នុងវីដេអូលេខរៀងទី៣។

[១៤:១៧:៥០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ថ្ងៃដែលគេហៅទៅការហ្នឹង ខ្ញុំអត់បានដឹងព័ត៌មានថា គេហ្នឹងអញ្ជើញខ្ញុំទៅរៀបការទេ។ អ៊ីចឹងខ្ញុំអត់បានបដិសេធទេ ព្រោះគេហៅចូលរួម ចាសចូលរួមកម្មវិធី។ គេធ្វើអី ធ្វើអ៊ីចឹង ខ្ញុំអត់បានទទួលព័ត៌មានថា មិត្តឯងថ្ងៃហ្នឹងត្រូវរៀបការជាមួយអ្នកនេះអ្នកនោះទេ។ ចាស ពេលចែកខោអាវ គេឲ្យខោ*

*អាវយកទៅ បានដឹងៗថាគេឲ្យទៅរៀបការ ប៉ុន្តែនៅអារម្មណ៍គិតខ្លាចថា ក្រែងគេៗហ្នឹងភរយើង គេទៅសម្លាប់ គេប្រមូលគ្នាទៅតាមបណ្តាញខ្សែអ៊ីចឹងក៏មិនដឹង ខ្ញុំនឹកអារម្មណ៍អ៊ីចឹងទេ។ អ៊ីចឹងខ្ញុំអត់បានចាប់អារម្មណ៍ថា ខ្ញុំទៅការហ្នឹងខ្ញុំបានដឹងច្បាស់លាស់ ឬបដិសេធហ្នឹង ខ្ញុំអត់បានប្រកែកដោយសារខ្ញុំអត់បានដឹងចាស។ ដល់ពេលទៅដល់កន្លែងហ្នឹងទៅវាហួសចិត្ត ក៏នាំគ្នាយំទៅ។ ចាស សូមជម្រាបប្រសាសន៍អ៊ីចឹង។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:១៨:៥១]

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ទៀតថា គាត់ត្រូវបានគេណែនាំឲ្យបង្កើតកូនជូនអង្គការ ហើយគាត់បានបញ្ជាក់ថា គាត់ត្រូវបានគេតាមដាននៅក្នុងរាត្រីផ្សំដំណេក។ ហើយប្តីរបស់គាត់បានបង្ខំគាត់រួមដំណេកជាមួយគ្នាដោយខ្លាចគេធ្វើទារុណកម្ម។ ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុខឿន នេះគឺជាក្រមុំព្រហ្មចារី។ ហើយយើងរៀប -- យើងនឹង<>មើលវីដេអូទី៤ ដែលគាត់រៀបអំពីរាត្រីផ្សំដំណេកដំបូងនេះ។

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ចាស កាលដែលគាត់បង្ខំឲ្យខ្ញុំរួមរក្ស គាត់ពេលហ្នឹងគាត់ ថ្ងៃហ្នឹងខ្ញុំងងុយដេកពេក ខ្ញុំទៅដំបូងខ្ញុំចេះអត់ប៊ានដេកទេ ដល់ថ្ងៃហ្នឹងខ្ញុំដេកលក់។ ដល់ដេកលក់ទៅ គាត់ឱបខ្ញុំ។ ដល់ខ្ញុំរើបម្រះ រករត់រកអីអ៊ីចឹងទៅ គាត់ចាប់ខ្ញុំរំលោភ ដូចថា បើនេះទៅគាត់ដោះអាវ ដោះខោខ្ញុំទៅ គាត់ហែកខោខ្លីខ្ញុំហ្នឹងទៅ ហើយទៅគាត់ទាញបណ្តាច់ខ្សែអាវខ្ញុំ ខ្ញុំខំយកដៃក្តោបអ៊ីចេះ គាត់ថាប្តីប្រពន្ធសោះ នែអង្គការសម្លាប់ចោលងាប់ទាំងអស់គ្នា គាត់សម្លុតខ្ញុំដែរ គាត់គំរាមខ្ញុំ--"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:២០:២៥]

ប្តីរបស់គាត់ដែលអង្គការរើសឲ្យនេះ <ក្រោយមកទៀត គាត់>ត្រូវបានអង្គការចាត់ទុកថាជាខ្មាំង ហើយគេបាននាំទៅបាត់ទៅ។ ដូច្នេះអង្គការដែលបានជ្រើសរើសប្តីឲ្យ ព្រាប សុខឿន នេះបានចោទគាត់ថាគាត់ជាប្រពន្ធរបស់ជនក្បត់។ ហើយ ព្រាប សុខឿន នេះបានសម្រាលកូននៅពេលដែលប្តីរបស់គាត់បានបាត់ខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណី១៥រូប បានធ្វើសក្ខីកម្មអំពីវត្តមានរបស់ឈ្លបក្នុងពេលផ្សំដំណេក ឬក៏នៅពេលដែលប្តីប្រពន្ធជួបគ្នា អ្នកទាំងអស់គ្នាបានយល់ឃើញថា ការតាមដាននេះគឺជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការគំរាមកំហែង ឬក៏ការដាក់សម្ពាធឲ្យរួមដំណេក។ ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត ជាស្ត្រីមេម៉ាយ គាត់ជាប្រជាជនថ្មី គាត់ត្រូវបានអង្គការរៀបការម្ដងទៀត មួយសប្ដាហ៍ក្រោយពីប្ដីទី១របស់គាត់បានបាត់ខ្លួន។ ការរៀបការរបស់គាត់នេះ ប្រព្រឹត្តទៅនៅឆ្នាំ១៩៧៨ នៅភូមិភាគពាយ័ព្យ នៅពេលដែលគាត់មានអាយុ២០ឆ្នាំ ហើយប្ដីគាត់ថ្មីហ្នឹង ប្ដីថ្មីហ្នឹង ក៏ជាបុរសពោះម៉ាយដែរ ហើយមានអាយុលើសគាត់ពីរដង។ ង៉ែត ចាត នេះគឺមិនបានដឹងមុនអំពីថ្ងៃដែលគាត់ត្រូវរៀបការទេ ហើយក៏មិនដឹងអត្តសញ្ញាណប្ដីរបស់គាត់ដែរ គាត់បានរៀបរាប់ថា ក្នុងពេលរៀបការ គូស្រករទាំងអស់នោះត្រូវបានទទួលការណែនាំពីអង្គការឲ្យរួមដំណេកដើម្បីបង្កើតកូនជូនអង្គការ។ គាត់បានបញ្ជាក់ថាក្រោយពីរៀបការហើយ ប្ដីប្រពន្ធទាំងអស់ត្រូវបានគេបញ្ជូនទៅតាមផ្ទះនីមួយៗ ហើយពេលនោះគឺមានការតាមដានពីឈ្លបនៅពេលដែលយប់រាត្រីផ្សំដំណេកនេះ។ ដូច្នេះ សូមអនុញ្ញាតបញ្ចាំងវីដេអូទី៥។

[១៤:២២:១៦]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"នាំគ្នាដេកគិតគ្នាថា បើយើងរើបម្រះទៅខ្លាចគេឮ ម្ល៉ោះហើយចេះតែនាំគ្នាដេកស្ងួកៗអ៊ីចឹងទៅ មានឈ្លបគេតូចៗគេលបចាំស្ដាប់មើល គេដើរ។ មិនដឹងគេចាំស្ដាប់ចាំអី ប៉ុនគេដើរធ្វើ ទៅមកៗតាមអាផ្លូវយើង ដូចអាផ្ទះនេះមួយល្វែងៗ អាប្រឡោះកណ្ដាលអ៊ីចេះ គេដើរទៅដើរមកអ៊ីចឹង មិនដឹងគេដើរមានការអី ខ្ញុំអត់ដឹងដែរ ចេះតែនាំគ្នាដេកស្ងួកៗអ៊ីចឹងទៅ គិតគ្នា អត់មានប៉ាននិយាយជាមួយគ្នា សូម្បីតែខ្សឹបគ្នា ក៏មិនប៉ាននិយាយដែរ ព្រោះអីយកទៅវ៉ៃ -- យកទៅវាងដូចស្រស់ៗពេក ខ្លាចអត់ប៉ាននិយាយបណ្ដោយ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:២៣:០១]

សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប មានសារៈសំខាន់ ពីព្រោះគាត់ជាកម្មាភិបាលស្រី<ម្នាក់>ដែលធ្វើការនៅភ្នំពេញនៅមន្ទីររបស់ក្រសួងពាណិជ្ជកម្ម។ គាត់ធ្វើការនៅខាងអង្គភាពទទួលបន្ទុកខាងប្រមូលជយភណ្ឌដែលដាក់នៅក្នុងឃ្លាំង ហើយគាត់នៅក្នុងក្រុមពាណិជ្ជកម្ម។ គាត់បានចូលរួមនៅឆ្នាំ១៩៧៥ នៅវគ្គរៀនសូត្រមួយនៅវត្តឧណ្ណាលោម ហើយក្នុងពេលនោះ គឺ ខៀវ សំផន បានប្រកាសថា កម្មាភិបាលស្ត្រីទាំងអស់ត្រូវធ្វើការជូន<អង្គការ> ហើយត្រូវផ្សំផ្គុំឲ្យរៀបការ។ ចំពោះស្ត្រីណាដែលធ្វើការនៅក្នុងក្រសួង ហើយមានអាយុលើសពី១៩ឆ្នាំទៅ។ ប៉ុន្មានខែក្រោយមក គឺនៅចុង

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ្នាំ១៩៧៥ ជា ឌៀប គឺស្ថិតនៅក្នុងចំណោមក្រុមប្តីប្រពន្ធ១២គូ ដែលត្រូវបានរៀបនៅផ្សារដើមគ នៅតំបន់ស្ទឹយ័ត ក្រុងភ្នំពេញ។ បន្ទាប់ពីបានប្រកែកពីរដង ជា ឌៀប ត្រូវបានគេចោទថា ជា -- បានប្រព្រឹត្តអសីលធម៌<ថាមានមិត្តប្រុស> ហើយពេលនោះហើយ គាត់ក៏បង្ខំចិត្តព្រមរៀបការទៅ ដោយសារតែភ័យខ្លាច។ គាត់ត្រូវបានគេរៀបការជាមួយនឹងទាហានពិការមួយដែលគាត់ -- ម្នាក់ដែលគាត់មិនស្គាល់ពេលមុនការទេ។ ហើយគាត់បានប្រាប់តុលាការការថា នៅពេលការរួចហើយនោះ គេតាមដានគាត់នៅពេលយប់។ ដូច្នេះ សូមអនុញ្ញាតបញ្ចាំងវីឌីអូទី៦។

[១៤:២៤:៣៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"យប់ទី១ យប់ទី២ យប់ទី៣ គឺថាគេឲ្យទៅនៅតែបីនាក់ទេ -- បីថ្ងៃទេជាមួយគ្រួសារ ប៉ុនក្នុងបីថ្ងៃហ្នឹង គឺឈ្លបតាមដានរាល់យប់ ខ្ញុំដេកស្តាប់ រួចទៅទាំងគ្រួសារទាំងខ្ញុំផ្ទាល់គឺថាខ្លាចគេដែរ ចេះតែនាំគ្នាសម្ងំ មិនប៉ានមាត់ មិនប៉ាននិយាយទេ។ ដល់ពេលបីថ្ងៃហ្នឹង ក៏បែកគ្នាៗលុះត្រាតែ ប្រហែលជាមួយអាទិត្យ ឬ១០ថ្ងៃទេ បានខ្ញុំមកជួបគ្នាម្តងទៀត គេឲ្យមកជួបគ្នា ទើបខ្ញុំព្រមប្រគល់ខ្លួនឲ្យគ្រួសារខ្ញុំ។ ខ្ញុំមិនបានចាំខែចាំ--"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:២៥:១៧]

ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ត្រូវបានរៀបការនៅឆ្នាំ១៩៧៥ ក្នុងខេត្តកំពង់ចាម នៅពេលនោះ គឺមាន៦០គូ។ គាត់មិនដឹងអំពីការរៀបការមុនទេ ហើយគាត់ក៏មិនស្គាល់ប្តីគាត់ជាមុនដែរ។ ដំបូងគាត់ប្រកែកដែរ ប៉ុន្តែគេប្រាប់ថា បើនៅតែប្រកែកទៀត ប្រាកដជាមានគ្រោះថ្នាក់ហើយ។ គាត់បានឆ្លើយជូនអង្គជំនុំជម្រះថា គាត់ទទួលបានការណែនាំឲ្យបង្កើតកូនជូនអង្គការ ហើយគាត់ត្រូវបានគេតាមដានពេលយប់ផ្សំដំណេក គាត់រៀបរាប់ជូនអង្គជំនុំជម្រះអំពីកាលៈទេសៈនៃការរួមដំណេកជាមួយប្តីរបស់គាត់ ហើយនិងផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ទៅលើជីវិតរបស់គាត់។ នេះជាវីដេអូចុងក្រោយហើយ គឺវីដេអូលេខ៧។

[១៤:២៦:០៩]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...មួយជីវិតខ្ញុំ តាំងពីខ្ញុំដឹងក្តីមក ខ្ញុំពុំដែលជួបប្រទះ ខ្លួនខ្ញុំជាស្ត្រីខ្មែរមួយរូប អ្វីៗក៏វាមិនសំខាន់*

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*ដល់ស្មើនឹងខ្លួនរបស់នាងខ្ញុំដែរ។ តែនាងខ្ញុំសុខចិត្តញ័រញាក់ដូចកូនសត្វយ៉ាងណាក៏ដោយ ក៏នាងខ្ញុំសុខចិត្តថា នៅស្ងៀមដើម្បីឱ្យប្តីបម្រើទៅតាមចំណង់ចំណូលចិត្តរបស់គាត់រួមភេទ ព្រោះគាត់បានប្តេជ្ញាចិត្តនៅមុខអង្គការ។ នាងខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់ សូមឱ្យលោកប្រធានពិចារណា។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

លោកប្រធាន យើងបានបញ្ចប់ការបង្ហាញសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីហើយ ហើយខ្ញុំមានសេចក្តីសន្និដ្ឋានខ្លីមួយ មុននឹងយើងចូលទៅ<វគ្គចុងក្រោយ ដែលយើងនឹង>និយាយអំពីសំណង។ គម្រោងនៃការធ្វើបទបង្ហាញជាលាយលក្ខណ៍អក្សរ ហើយនិងផ្ទាល់មាត់នេះ គឺដើម្បីបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសក្ខីកម្មនៅក្នុងតុលាការអាចចូលរួមក្នុងការលាតត្រដាងការពិត និងជួយអង្គជំនុំជម្រះឱ្យបង្ហាញឱ្យឃើញអំពីធាតុផ្សំសច្ចានុម័តនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានវិនិច្ឆ័យ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចនៅក្នុងសំណុំរឿង០០២/០១ ថាដើមបណ្តឹងរដ្ឋប្បវេណីមានភាពស័ក្តិ-សមក្នុងការលាតត្រដាងអំពីអង្គហេតុដែលជាមូលដ្ឋាននៃបទចោទប្រកាន់។

[១៤:២៧:៤៦]

ខ្ញុំសូមរំឭកនូវភស្តុតាងមួយចំនួន ហើយនិងត្រឡប់មកនិយាយអំពីបញ្ហាសំខាន់មួយ គឺតម្លៃជាភស្តុតាង<>នៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលយើងនិយាយនៅថ្ងៃនេះ។ ខ្ញុំសូមរំឭកអំពីភស្តុតាងមួយចំនួន ខ្ញុំត្រូវបានអ្នកកាសែត និងអ្នកស្រាវជ្រាវជាច្រើនបានចោទសួរពាក់ព័ន្ធទៅនឹងភាពពាក់ព័ន្ធនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ហើយខ្ញុំគិតថា ការពិភាក្សាដេញដោលសួរនេះ គឺថាមិនត្រឹមត្រូវទេ ការចោទសួរបែបនេះ។ ប្រសិនបើមានប្រព័ន្ធនៃការចូលរួមនៅក្នុង អ.វ.ត.ក នេះ គឺថាដោយសារតែនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាន<>ប្រព័ន្ធនេះ។ អ៊ីចឹងថា តើយើងមិនបញ្ចូលផ្នែកដ៏សំខាន់នៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា នៅក្នុងវិធានរបស់តុលាការមួយដែលស្ថិតនៅក្នុងប្រព័ន្ធតុលាការកម្ពុជាយ៉ាងម៉េច<បាន> ហើយតុលាការនេះ គឺថាមានឧបនិស្ស័យក្នុងបន្សល់ទុកនៅកេរមរតកសម្រាប់កម្ពុជា។

[១៤:២៨:៥៥]

ដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវបានអនុញ្ញាតឱ្យចូលរួមនៅ អ.វ.ត.ក ក៏ដូចជានៅតុលាការសេណេហ្គាល់ដែរ ដែលបានវិនិច្ឆ័យទៅលើឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយជនផ្តាច់ការ ហ៊ីសាន់ ហាប

ហើយក៏នឹងមានវត្តមាននៅក្នុងតុលាការព្រហ្មទណ្ឌពិសេស នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាលនាពេលខាងមុខនេះ ពីព្រោះថានីតិវិធីព្រហ្មទណ្ឌទាំងអស់ហ្នឹង គឺថាមាននៅក្នុងប្រទេសទាំងនុ៎ង<ស្រាប់>។ ហើយមេធាវី នួន ជា តែងតែនិយាយថា ដើមបណ្តឹងរដ្ឋប្បវេណីនេះ និយាយបំផ្លើស។ ដូច្នេះ ខ្ញុំសូមរំឭកដូចតទៅ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូប -- ដើមបណ្តឹងរដ្ឋប្បវេណី គឺជាបុគ្គលមួយរូបដែលបានរស់ឆ្លងកាត់នៅរបបកម្ពុជាប្រជាធិបតេយ្យរបបខ្មែរក្រហម ដែលគាត់យល់ឃើញថា គាត់ទទួលរងនូវការឈឺចាប់ពីការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ដូច្នេះច្បាស់ណាស់ មនុស្សម្នាក់ដែលបាននិយាយថា ខ្លួនហូបឆ្អែត នៅក្នុងរបបនោះ អ្នកដែលមិនបានបាត់បង់បងប្អូន អ្នកដែលមិនបានទទួលរងនូវការភ័យរន្ធត់ ពួកគាត់ប្រាកដជាមិនដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើននេះ គឺគាត់មានរឿងរ៉ាវផ្ទាល់ខ្លួនកម្រិតខ្ពស់ដែលបង្ហាញអំពីបទពិសោធន៍ដែលគាត់បានទទួលរងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ យើងមិនចង់លើកស្ទួយតែរឿងរ៉ាវដែលមិនពិតប្រាកដទេ ហើយយើងធ្វើយ៉ាងម៉េចគឺថា ដើម្បីបង្ហាញនូវបទដ្ឋានពិតប្រាកដ អំពីអ្វីដែលបានកើតឡើងពិតប្រាកដនៅក្នុងរបបខ្មែរក្រហម។ បញ្ហានៃអវត្តមាននៃការស្បថរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះគឺថា នៅឲ្យតែមានការជជែកពិភាក្សាគ្នាច្រើន ទោះបីជា ហើយនៅពេលនោះ គឺថាអង្គជំនុំជម្រះបានសម្រេច ហើយអង្គជំនុំជម្រះតុលាការកំពូលនោះ ក៏បានផ្តល់សុពលភាពទៅលើវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់ជាភាគី ខ្ញុំបាននិយាយជាច្រើនលើក ច្រើនសាររួចមកហើយ វាដូចដែលជនជាប់ចោទអ៊ីចឹង គាត់ជាភាគី អ៊ីចឹងគាត់មិនចាំបាច់ធ្វើសម្បថទេ នៅពេលដែលគាត់មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនោះ។ តុលាការកំពូលក៏បានរំឭកអំពីចំណុចនេះដែរ រវាងដើមបណ្តឹង -- រវាងសក្ខីកម្មរបស់ជនជាប់ចោទ និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ មិនមែនដើមបណ្តឹងរដ្ឋប្បវេណីគាត់មិនចង់ស្បថទេ ក៏ប៉ុន្តែគាត់មិនអាចស្បថទេ ដូចជា នួន ជា ឬក៏ ខៀវ សំផន អ៊ីចឹង គាត់មិនអាចជ្រើសរើសថា គាត់ស្បថដើម្បីធ្វើសក្ខីកម្មក្នុងឋានៈជាសាក្សីទេ។ ដូច្នេះ សុំឲ្យយើងច្បាស់ទាំងអស់គ្នាថាមិនមានវិធាន<>ឬក៏មិនមានយុត្តិសាស្ត្រណាមួយដែលគាំទ្រទៅលើការអះអាងរបស់មេធាវីការពារក្តី<នួន ជា>ថា ការដែលគាត់មិនបានស្បថអ៊ីចឹង ធ្វើឲ្យសក្ខីកម្មរបស់គាត់ហ្នឹងមិនសូវមានតម្លៃ<ដូចសក្ខីកម្មសាក្សី>ទេ។ អ៊ីចឹងគ្មានច្បាប់ណាមកចែងអ៊ីចឹងទេ។ ដូច្នេះ ការអះអាងបែបនេះរបស់មេធាវី នួន ជា ហ្នឹង គឺខុសស្រឡះតែម្តង។ ដើមបណ្តឹងរដ្ឋប្បវេណីមិនសុំឲ្យមានការអនុគ្រោះ មិនសុំការអាណិតអីទេ គាត់គ្រាន់តែចង់ ឲ្យសក្ខីកម្មរបស់គាត់ត្រូវបានប្រព្រឹត្តដោយយុត្តិធម៌ដោយគោរពទៅតាមវិធាននីតិ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

វិធីជាធរមាននៅ អ.វ.ត.ក។

[១៤:៣២:៣៣]

ដូច្នេះតើយើងធ្វើយ៉ាងម៉េចដើម្បីគិតទៅដល់ការបំភ្លេច ឬក៏ការមិនច្បាស់លាស់ ដែលដោយសារតែពេលវេលាយូរនោះ។ បញ្ហាហ្នឹងគឺថាវា ស្ថិតនៅក្នុងចំណុចមួយដ៏សំខាន់នៅពេលដែលអង្គជំនុំជម្រះពិភាក្សាសម្រេចនោះ ថាតើយើងវាយតម្លៃទៅលើភាពជឿជាក់ ភាពអាចជឿទុកបានរបស់សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបយ៉ាងម៉េច នៅពេលដែលអង្គហេតុនោះ វាកើតឡើង៤០ឆ្នាំរួចមកហើយនោះ ហើយយើងវាយតម្លៃយ៉ាងម៉េចទៅលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគាត់ និងការចងចាំជាសមូហភាពនៅក្នុងរឿងរ៉ាវ ដែលគាត់បានរៀបរាប់នៅក្នុងសវនាការនោះ។ ខុសពីអ្វីដែលមេធាវីការពារក្ដីបានបញ្ជាក់។ បញ្ហានេះ គឺ<>សំខាន់ ហើយវាកើតឡើងចំពោះគ្រប់បុគ្គលទាំងអស់ ដែលមកផ្ដល់សក្ខីកម្មនៅតុលាការនេះ ទាំងដើមបណ្ដឹងរដ្ឋប្បវេណី ទាំងសាក្សីដោះបន្ទុក និងសាក្សីដោះបន្ទុក។ គឺថាស្ទើរតែមនុស្សគ្រប់រូបទាំងអស់ដែលមកផ្ដល់សក្ខីកម្មនេះ គឺថាវាមានផលប៉ះពាល់ទៅនឹងការឃោសនានៅទសវត្សរ៍ឆ្នាំ៨០ ហើយពួកគាត់ខ្លះនោះ ត្រូវបានគេសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នកខ្លះបានអានកាសែត អ្នកខ្លះស្ដាប់វិទ្យុ។ ដូច្នេះ ខ្ញុំគិតថា បញ្ហានោះគឺវាពាក់ព័ន្ធទៅមនុស្សទាំងអស់ ដែលយើងបានស្ដាប់សក្ខីកម្ម។

អង្គជំនុំជម្រះបានស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានវ័យចំណាស់ភាគច្រើនមកពីជនបទ ហើយនិងជាអ្នកមិនសូវចេះអក្សរ។ បុរសនិងស្ត្រីទាំងអស់នេះ គឺកើត គឺចេញមកពីជំនាន់មួយនៅក្នុងប្រទេសកម្ពុជាដែលជាសម័យបុរាណ ហើយពួកគាត់ដែលមានគោរពឋានានុក្រមណាស់។ អ៊ីចឹងនៅពេលដែលគាត់មកក្នុង<បន្ទប់>សវនាការ ហើយគាត់ឃើញចៅក្រមអង្គុយតម្រង់ជួរគ្នាអ៊ីចឹងហើយមានវេទិកាមានអី មានមនុស្សពាក់សម្លៀកបំពាក់មានឯកសណ្ឋាន ហើយមានចៅក្រមបរទេសហើយមានមេធាវី មានសហព្រះរាជអាជ្ញាបរទេស អ៊ីចឹងវាជារឿងមួយដែលចម្លែកណាស់សម្រាប់ពួកគាត់នោះ។ គឺគាត់មើលទៅ គាត់ចាញ់ច្រាបហើយនៅពេលឃើញអ៊ីចឹង។ អ៊ីចឹងយើងមិនអាចយកចំណុចហ្នឹង ទាំងអស់ហ្នឹងមកវាយតម្លៃថា ភស្ដុតាងគាត់ហ្នឹងវាមិនសូវមានទម្ងន់ទេ<នៅក្នុងបរិបទបែបនោះ>។ ដូច្នេះបញ្ហាបរិបទនេះ វាសំខាន់ណាស់ <ដោយមានហេតុផលដូចតទៅ>។ យុត្តិសាស្ត្រអន្តរជាតិហ្នឹង ហាក់ដូចជាមានភាពស៊ីសង្វាក់គ្នា ពាក់ព័ន្ធនឹងភាពមន្ទិលសង្ស័យដែលវាមាននៅ ពាក់ព័ន្ធទៅនឹងព័ត៌មានលម្អិតបន្ទាប់បន្សំ ហើយដែលធ្វើឲ្យគេគិតថាសក្ខីកម្មហ្នឹងវាមិនសូវមានតម្លៃ។ អ៊ីចឹង

យើងត្រូវវាយ បែងចែកឲ្យដាច់រវាងអ្វីដែលសំខាន់ និងអ្វីដែលរាយរង<តាមបរិបទវប្បធម៌ខ្មែរ>។ អ្វីដែលសំខាន់ និងអ្វីដែលបន្ទាប់បន្សំ។

[១៤:៣៥:១៥]

លោកប្រធាន! លោកប្រធានបានផ្តល់នូវសេរីភាព<>ឲ្យមេធាវីការពារក្តីក្នុងការសួរដេញដោលជាច្រើន ហើយមេធាវីការពារក្តីពេលខ្លះហ្នឹង គាត់បានចំណាយពេលរាប់ម៉ោងដើម្បីសួរសាក្សី ដើមបណ្តឹងរដ្ឋប្បវេណីទៅលើឈ្មោះ កាលបរិច្ឆេទ និងចម្ងាយ ដែលពួកគាត់ស្ថិតនៅជាដើម។ អ៊ីចឹងនៅក្នុងបរិបទកម្ពុជា បរិបទវប្បធម៌កម្ពុជាហ្នឹង ថាតើធាតុផ្សំទាំងអស់ហ្នឹង វាមានជាចំណុចសំខាន់ ឬវាគ្រាន់តែជាចំណុចរាយរងទេ ឬចំណុចបន្ទាប់បន្សំទេ? អ៊ីចឹងការដែលគាត់មិនច្បាស់លាស់ទៅលើចំណុចទាំងអស់ហ្នឹង យើងត្រូវ យើងគិតថារឿងរ៉ាវរបស់គាត់ហ្នឹងវាអត់មានសារៈសំខាន់ ឬក៏យ៉ាងម៉េច? ហ្នឹងយើងត្រូវថ្លឹងថ្លែងទៅលើចំណុចនេះ។

នៅពេលដែលមេធាវីក្តី នួន ជា ជំទាស់ទៅលើភាពជឿទុកចិត្តបាននៃសក្ខីកម្មរបស់ សយ សែន ដែលគ្រាន់តែនិយាយថា ដោយគ្រាន់តែគាត់មិនចាំអំពីឈ្មោះអ្នកដែលជាប់គុកជាមួយគាត់ហ្នឹង អ៊ីចឹងគ្រាន់តែគាត់មិនចាំឈ្មោះអ៊ីចឹង ក្នុងបរិបទខ្មែរយើងហ្នឹង ថាតើជាចំណុចសំខាន់ ឬក៏អត់ ពីព្រោះថាវាខុសពីវប្បធម៌ពួកបស្ចិមប្រទេស។ អ៊ីចឹងចំណុចហ្នឹង វាជាចំណុចសំខាន់របស់ សម្រាប់លោក វ៉ិចទ័រ កូប៉េ ដែល -- ប៉ុន្តែវា -- ចុះចំពោះលោក សយ សែន គាត់ប្រហែលជាគិតថាអត់សំខាន់ទេ គ្រាន់តែឈ្មោះទាំងអស់ហ្នឹងនោះ។

ដូចគ្នាផងដែរ ចំពោះអ្នក -- នៅពេលដែលអ្នកណាម្នាក់មានភាពភ័យរន្ធត់ នៅពេលដែលគាត់រួចផុតពីការសម្លាប់ នៅពេលដែលគាត់<រត់>រួច ត្រូវបានគេដាក់គុក នៅពេលដែលគាត់ត្រូវបានគេធ្វើទារុណកម្ម រំលោភបំពានហ្នឹង អ៊ីចឹងយើងគិតថាតើចំណុចណាជាចំណុចសំខាន់នៃការរៀបរាប់រឿងក្តីរបស់គាត់ហ្នឹង។ យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងទៀតហ្នឹង បានបង្ហាញថា យើងមិនអាច<រំពឹង>ឲ្យមនុស្សម្នាក់ដែលគាត់ទទួលរងនូវការភ័យរន្ធត់ខ្លាំង ហើយដែលរួចជីវិតមកហ្នឹង ឲ្យគាត់រៀបរាប់ឲ្យបានលម្អិតច្បាស់លាស់អំពីអ្វីដែលគាត់បានឆ្លងកាត់ទេ។ ដូច្នេះ ដើម្បីឆ្លើយតបទៅនឹងសំណួរទាំងអស់ហ្នឹង យើងឃើញនៅក្នុងសំណុំរឿង០០២/០១ហើយ ចម្លើយនោះ។ ហើយអង្គជំនុំជម្រះតុលាការកំពូលក៏បានបង្ហាញអំពីវិធីសាស្ត្រដែរ អ៊ីចឹងយើងត្រូវតែវាយតម្លៃទៅលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅតាមករណីនីមួយៗ។ ដើមបណ្តឹងរដ្ឋប្បវេណី<ម្នាក់ៗ> គាត់មានរឿងរ៉ាវរបស់

គាត់។ អ៊ីចឹងវាមានហេតុផល ដែលជំរុញឲ្យគាត់ដាក់ពាក្យដើមបណ្ដឹង -- ដាក់ពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ពួកគាត់មានរឿងរ៉ាវផ្ទាល់ខ្លួន មានមូលហេតុផ្ទាល់ខ្លួន ហើយយើងឃើញថាដើមបណ្ដឹងរដ្ឋប្បវេណី៦៣នាក់ ដែលបានមកផ្ដល់សក្ខីកម្មពាក់ព័ន្ធទៅចំណុចទាំងអស់នេះ។

[១៤:៣៧:៤០]

ចំណុចមួយទៀត <មុនខ្ញុំបញ្ចប់ ខ្ញុំសូមលើកឡើងអំពីរឿងរ៉ាវនៃការដាក់ពាក្យជាដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំគិតថា ខ្ញុំត្រូវប្រើពេលតែប្រាំនាទីប៉ុណ្ណោះនិយាយរឿងនេះ ហើយនេះជាចំណុចសំខាន់> ពីព្រោះថាមេធាវីការពារក្ដីបានប្រើប្រាស់ពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើតេស្ដទៅលើភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជាឯកសារដែលត្រូវបានប្រមូលដោយសមាជិកអង្គការ ឬក៏បុគ្គលិកអង្គការអន្តរ -- អង្គការក្រៅរដ្ឋាភិបាលមួយចំនួន។ ដូច្នេះ អង្គការនីមួយៗ គាត់មានវិធីសាស្ត្រផ្ទាល់ខ្លួនរបស់គាត់ក្នុងការប្រមូលឯកសារទាំងអស់ហ្នឹង ហើយគាត់ធ្វើការរៀងៗខ្លួន។ អ៊ីចឹងគាត់អត់ដឹងថាតើវិសាលភាពនៃការស៊ើបអង្កេតហ្នឹងយ៉ាងម៉េចទេ ពីព្រោះថាពេលនុ៎ង គឺការការស៊ើបអង្កេតហ្នឹង វាមានការសម្ងាត់។ ឯកសារទាំងអស់ហ្នឹង វាមានគុណភាពផ្សេងៗគ្នា។ អ៊ីចឹង ឯកសារហ្នឹងអត់មានកាតព្វកិច្ច ឬក៏អត់មានមហិច្ឆតាអីថា ត្រូវតែឲ្យរៀបរាប់លើអង្គសេចក្ដីហ្នឹងឲ្យបានពេញលេញទាំងអស់ទេ។ ឯកសារទាំងអស់ហ្នឹងគ្រាន់តែកំណត់អត្តសញ្ញាណនៃឧក្រិដ្ឋកម្មមួយនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត ដើម្បីអនុញ្ញាតឲ្យពាក្យសុំរបស់ខ្លួនហ្នឹងត្រូវបានទទួលយក ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។

[១៤:៣៨:៤៩]

នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះបានយកចិត្តទុកដាក់ទៅលើលក្ខខណ្ឌនៃការប្រមូលព័ត៌មានទាំងអស់នេះ ហើយបានផ្ដល់តម្លៃជាភស្តុតាងតិចតួចទៅលើឯកសារទាំងអស់នេះ។

សំណុំរឿង០០២/០២ បានបង្ហាញអំពីបញ្ហាជាច្រើនពាក់ព័ន្ធទៅនឹងឯកសារនេះ ហើយយើងខ្ញុំយល់ឃើញថា កំហុសភាគច្រើនដែលមាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ហ្នឹង វាមិនមែនជាកំហុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ<>ពួកគាត់មិនមែនជាអ្នកទទួលខុសត្រូវទេ។ យើងបានដឹងអំពីការលំបាកទាំងអស់ហ្នឹងក្នុងពេលដែលយើងបានបង្ហាញនៅពេលសវនាការលើឯកសារគន្លឹះនោះ ហើយយើងដឹងហើយថាពេលនោះ គឺខាងយើងបានពិនិត្យទៅលើឯកសារ<ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី>ទាំងអស់ហ្នឹង។ អ៊ីចឹងហើយ បានជាយើងមិនបានយកឯកសារណាមួយនៃ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពាក្យសុំតាំងខ្លួនហ្នឹងមកធ្វើជាការគាំទ្រទៅសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលទេ។ ដូច្នេះ អង្គជំនុំជម្រះត្រូវតែឆ្លើយតបនឹងសំណួរនេះ។ អង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះសាលាដំបូង ភាគីគឺបានព្រមព្រៀងក្នុងការនិយាយថា ឯកសារទាំងអស់ហ្នឹងមិនអាចទុកចិត្តគ្រប់គ្រាន់បានទេ។ អ៊ីចឹងយើងសួរថាតើអង្គជំនុំជម្រះសាលាដំបូងនឹងប្រើប្រាស់ឯកសារទាំងអស់ហ្នឹងក្នុងលក្ខខណ្ឌយ៉ាងម៉េច ក្នុងកម្រិតយ៉ាងម៉េច ដើម្បីបង្ហាញអំពីភាពអាចជឿជាក់បាននៃសក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីនោះ។

[១៤:៤០:១៤]

លោកប្រធាន ដើម្បីជាសេចក្ដីសន្និដ្ឋាន យើងស្នើសុំឱ្យមានការគោរព -- ឱ្យមានការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ហើយគឺធ្វើយ៉ាងម៉េចទៅតាមការស្នើសុំរបស់សហព្រះរាជអាជ្ញា ពីព្រោះថាពួកគាត់ជាអ្នកធ្វើបណ្ដឹងអាជ្ញា ជាអ្នកដឹកនាំបណ្ដឹងអាជ្ញា។ យើង<ក៏ស្នើ>សូមឱ្យអង្គជំនុំជម្រះពិនិត្យទៅលើភស្តុតាងទាំងអស់ ដែលបានផ្ដល់ជូនអង្គជំនុំជម្រះដោយដើមបណ្ដឹងរដ្ឋប្បវេណី ហើយអង្គជំនុំជម្រះត្រូវពិនិត្យថា តើអង្គហេតុទាំងអស់នេះវាជាឧក្រិដ្ឋកម្ម ហើយថាតើជនជាប់ចោទ<ពិតជា>បានប្រព្រឹត្តអង្គហេតុទាំងអស់ហ្នឹងបានអង្គហេតុទាំងអស់នេះដែរឬទេ? <ទាក់ទងនឹងឧក្រិដ្ឋកម្មដែលកើតមានឡើង> យើងសូមឱ្យអង្គជំនុំជម្រះទទួលស្គាល់ព្យសនកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណី<ក្រុមសមូហភាព>ទាំងអស់បានទទួលរង។<>ដើម្បីភ្ជាប់ទៅនឹងវគ្គចុងក្រោយ ដែលពាក់ព័ន្ធនឹងការស្នើសុំសំណងនោះ ខ្ញុំសូមរំឭកនូវអត្ថបទច្បាប់អន្តរជាតិដែលយល់ឃើញថា ការ -- សាលក្រមផ្ដន្ទាទោសនោះវាជាទម្រង់មួយនៃការផ្ដល់សំណង យើង<តែងតែ>បានតវ៉ាក្ដីនៅក្នុងសវនាការនេះ គឺសុំឱ្យមានការធ្វើយ៉ាងម៉េចឱ្យមានការកាត់ក្ដីឱ្យមានការឆាប់រហ័ស ប៉ុន្តែត្រូវតែគោរពច្បាប់ក្នុងការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌។ ជនជាប់ចោទនៅក្នុងសំណុំរឿងនេះគឺគាត់ចាស់ៗហើយ ហើយដើមបណ្ដឹងរដ្ឋប្បវេណី២០០នាក់ បានទទួលមរណភាពតាំងពីចាប់ផ្ដើមសវនាការនៅសំណុំរឿង០០២មក។ ដូច្នេះយើងឃើញហើយថាផែនការសម្រេចចុងក្រោយរបស់អ.វ.ត.ក ហ្នឹងគឺបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងចេញសាលក្រមនៅក្នុងរយៈពេល១ឆ្នាំទៀត ខ្ញុំគិតថាយូរណាស់មួយឆ្នាំហ្នឹងនោះ <ហើយចំពោះដើមបណ្ដឹងរដ្ឋប្បវេណី កាត់តែយូរសម្រាប់ពួកគាត់ទៀត>។

អ៊ីចឹង ខ្ញុំសូមអរគុណលោកប្រធាន ហើយយើងនឹងបន្តចូលទៅនិយាយអំពីបញ្ហាសំណងនាពេលបន្តិចទៀតនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ ហើយប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០០នាទី)*

[១៥:០០:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុនផ្តល់វេទិកាជូនសហមេធាវីការពារក្តី -- មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសុំជម្រាបជូនដំណឹងដល់ភាគីនៃរឿងក្តីនៅក្នុងសំណុំរឿង០០២ទាំងអស់ -- ០០២/០២ ទាំងអស់ថា នៅក្នុងកិច្ចដំណើរការសវនាការនៅពេលសេសសល់នៅរសៀលនេះ និងថ្ងៃបន្តបន្ទាប់ទៀត ដោយលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ គាត់មានបញ្ហាសុខភាពមិនអាចចូលរួមក្នុងកិច្ចដំណើរការសវនាការបាន ហើយបន្ទាប់ពីយើងខ្ញុំពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ម៉ាទីន ខារ៉ុបគីន ជាចៅក្រមបម្រុងអន្តរជាតិជំនួសកន្លែង ក្លូឌា ហ្វេនស៍ ដែលមិនមានលទ្ធភាពអាចចូលរួមសវនាការបាន រហូតដល់ពេលណាដែលលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ មានវត្តមាន និងមានលទ្ធភាពអាចបំពេញការងារក្នុងការចូលរួមសវនាការនៅក្នុងអង្គជំនុំជម្រះសាលាដំបូងវិញបាន។ ហើយការអនុវត្តនេះ យោងតាមខ្លឹមសារនៃបទបញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

បាទ តទៅនេះផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឡើងធ្វើសេចក្តីសន្និដ្ឋាន និងបន្តនូវការងារសេចក្តីសន្និដ្ឋានរបស់ខ្លួន។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ អស់លោក លោកស្រីចៅក្រម ទាំងអស់ជាទីគោរព។ យើងបានចំណាយពេលវេលាបីវគ្គនេះដើម្បីនិយាយអំពីផ្នែកទី១ នៃបណ្តឹងរដ្ឋប្បវេណីរបស់យើង គឺការចូលរួម

របស់យើងទៅនឹងការចោទប្រកាន់ទៅលើជនជាប់ចោទ។ ឥឡូវយើងចូលនិយាយអំពីផ្នែកទី២ គឺការសុំសំណង<>ផ្លូវចិត្ត ហើយនិងជាសមូលហភាព។ មុននឹងនិយាយអំពីនិយាយការលម្អិតពីចំណុចនេះ យើងសុំឲ្យអង្គជំនុំជម្រះទទួលស្គាល់នេះ គឺខ្ញុំសុំគូសបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីបានសម្តែងជាទូទៅអំពីការអត់ធ្មត់យ៉ាងអស្ចារ្យ ហើយដែលបានព្យាយាមរកមធ្យោបាយខ្លួនឯងដើម្បីជម្នះគ្រប់ឧបសគ្គទាំងអស់ដើម្បីមកចូលរួមដំណើរការនេះ គឺថារយៈពេល៤០ឆ្នាំកន្លងផុតមកហើយ។ ហើយ<ក្នុងអំឡុងពេលនេះដែរ ទាំង>អង្គការក្រៅរដ្ឋាភិបាល ហើយនិង<អង្គការ>រដ្ឋាភិបាល <មានគំនិតផ្តួចផ្តើម>បង្កើតឡើង ដើម្បីបំពេញការងារចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត<ប្រឆាំងទាស់នឹងជនរងគ្រោះ>នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមុនពេលចេញសាលក្រមនេះទៀតទៅផង មុននឹងកើត បង្កើតតុលាការនេះទៅទៀត។ អ៊ីចឹងយើងមិនមានអំណួតអួតអាងអីទេ គឺយើងដាក់ខ្លួន មុននឹងនិយាយអំពីបញ្ហាសំណងនេះ។ <វិសោធនកម្មឆ្នាំ២០១០>នៃវិធានផ្ទៃក្នុងយើងនេះ បានបង្កើតរបបសំណងជាក់លាក់មួយដោយសារវាមកបង្កើតឲ្យមាន -- ផ្តល់លទ្ធភាពដល់មេធាវីនាំមុខដោយប្រត្តិបត្តិការជាមួយនឹងអង្គភាពគាំពារជនរងគ្រោះដើម្បីកំណត់ ហើយនិងអភិវឌ្ឍន៍នូវគម្រោងសំណង ដែលបង្កើតឡើងជាមួយនឹងដៃគូ ហើយនិងទទួលហិរញ្ញប្បទានពីខាងក្រៅ។ ការបង្កើតប្រពន្ធនេះ បានបង្កើតជាដំណាក់កាលមួយ គេហៅថាដំណាក់កាលដកបទពិសោធន៍។ កាលនោះយើងពិបាកនឹងដឹងថា តើប្រព័ន្ធនេះនឹងវិវត្តន៍ទៅយ៉ាងណា។ មុននឹងបង្ហាញអំពីសក្តានុភាពនៃប្រព័ន្ធនេះ ខ្ញុំសូមធ្វើការបូកសរុបខ្លីមួយ ហើយនិងបង្ហាញថា តើប្រព័ន្ធនេះទោះបីជាមានលំហមួយ ដើម្បីផ្តល់សំណងក៏ដោយ ក៏ប្រព័ន្ធនេះ តាមព្រឹត្តិន័យហ្នឹង គឺបានកម្រិត រឹតត្បិតសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទទួលបានសំណង។ ការកម្រិត រឹតត្បិតទី១នោះ គឺផ្នែកច្បាប់ គឺមានសរសេរនៅក្នុងបទបញ្ជាផ្ទៃក្នុង ដែលហាមមិនឲ្យផ្តល់សំណងជាបុគ្គល ហើយនិងជាប្រាក់កាក់។ ដើមបណ្តឹងរដ្ឋប្បវេណីច្រើនតែសុំឲ្យមានការផ្តល់សំណងជាប្រាក់។នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ គឺមានដើមបណ្តឹងរដ្ឋប្បវេណីមានប្រហែលជា៥០នាក់បាន<មកដាក់ញត្តិ>សម្តែងការមិនសប្បាយចិត្តរបស់ខ្លួន<នៅចំពោះមុខអង្គជំនុំជម្រះ>ទាក់ទង<>ទៅនឹងសំណង។ យើងបានសុំឲ្យញត្តិរបស់ពួកគាត់នៅនេះ បញ្ជូនទៅអង្គ -- ដាក់ជូនអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះបានទទួលយក ហើយអង្គជំនុំជម្រះបានប្រកាសថាខ្លួនមិនមានសមត្ថភាព ឬសមត្ថកិច្ចក្នុងការផ្តល់សំណងជា<បុគ្គល>នេះទេ។ នៅលើឆាកអន្តរជាតិ សំណងជាសមូហភាព ហើយនិង<សំណង>ផ្លូវចិត្តនេះគេពេញចិត្តច្រើន ក៏ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើននៅយើងនេះ គឺគាត់រស់នៅក្នុងស្ថានភាពលំបាក ហើយបើ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។

សិនជាយើងមានការសងជាថវិកា នេះ គឺធ្វើឲ្យគាត់ ជីវភាពរបស់គាត់ធូរស្រាលជាងមុន។ លោកប្រធាន មានការដាក់កម្រិតផ្នែកយុត្តាធិការ -- យុត្តិសាស្ត្រមួយទៀត<ចេញពីយុត្តិសាស្ត្រអង្គជំនុំជម្រះនេះតែម្តង>។ បទបញ្ញាផ្ទៃក្នុងចែងថា នៅពេលដែលយើងបង្កើតឲ្យមានការសងផ្លូវចិត្ត ហើយនិងសមូហភាពនេះ អង្គជំនុំជម្រះអាច ទី១ សម្រេចថាតើការសំណងនេះ ត្រូវទទួលជា ជនជាប់ចោទទទួលបន្ទុក ឬក៏យ៉ាងណា នៅពេលដែលគាត់ត្រូវបានប្រកាសថាគាត់មានពិរុទ្ធភាព។ ហើយទី២ គឺថាទទួលស្គាល់គម្រោងជាក់លាក់ ថាជាចម្លើយសមស្របទៅនឹងសំណើសុំសំណង។

[១៥:០៧:១៣]

នៅក្នុងក្របខ័ណ្ឌ<វគ្គដំបូង>នៃសំណុំរឿង០០២យើងនេះ យើងបានសុំឲ្យអង្គជំនុំជម្រះថា ការ--- សំណងទាំងអស់នេះ គឺជាបន្ទុករបស់ជនជាប់ចោទ <ឲ្យធ្វើគម្រោងអ្វីមួយ ហើយនេះជាជម្រើសទី២>។ ហើយអង្គជំនុំជម្រះបានជំទាស់នឹងសំណើរបស់យើង ហើយបាន<លើកឡើងថាទម្រង់នៃ> សំណងដែលមាននៅ អ.វ.ត.ក នេះៗមិនមានបែប -- មិនអាចមានទាំងពីរបានទេ មានមួយអត់មួយ ហើយអ៊ីចឹង<សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី>ត្រូវតែយករបៀបសំណងណាមួយ។ អាស្រ័យហេតុដូចនេះ តាមវិធាន<បច្ចុប្បន្ន>ដែលអង្គជំនុំជម្រះវាយតម្លៃនោះ មិនអាចអនុញ្ញាតឲ្យគោរពគោលការណ៍ជាមូលដ្ឋានដែលគោលការណ៍ គឺថាអ្នកណាក៏ដោយ ដែលដល់ពេលគេប្រកាសថាមាន ទាល់ប្រកាសថាមានពិរុទ្ធភាពហើយ គឺជាអ្នកទទួល គាត់ជាអ្នកទទួលខុសត្រូវនៃព្យសនកម្ម។ <តាមសាលក្រមរបស់អង្គជំនុំជម្រះ>ក្នុងសំណុំរឿង<០០២/០១>មួយ <>នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ <ក្នុងរឿងក្តី ឡូបានកា >នៅ-- ដែលមានសាលក្រមមួយចេញថា ការសំណងនេះត្រូវតែចេញដើម្បីត្រូវប្រឆាំង នឹងអ្នកទាំងឡាយណាដែលត្រូវបានរកឃើញថាមានពិរុទ្ធភាព <តាមយុត្តិសាស្ត្រអន្តរជាតិ>។ មានកំហិតមួយទៀតដែលអនុវត្តដោយអង្គជំនុំជម្រះហ្នឹង<ក្នុងអំឡុងពេលសំណុំរឿង០០១ អង្គជំនុំជម្រះបានប្រាប់ឲ្យយើងចាប់ផ្តើមអនុវត្តគម្រោងសំណង គឺមុនពេលការផ្តន្ទាទោសជនជាប់ចោតទៅទៀត។> ការអនុវត្តនេះមានការលំបាកខ្លាំងណាស់ក្នុងការរកជំនួយ ដោយសារថាការផ្តល់សំណងតាមផ្លូវតុលាការនេះធ្វើមិនបានទេ ក៏ប៉ុន្តែការផ្តល់ -- បាទដោយសារតាមផ្លូវតុលាការនេះមានការលំបាក យើងបានបង្កើតគម្រោងក្រៅផ្លូវតុលាការ ហើយដោយចាំក្នុងចិត្ត ហើយនិងរំឭកទៅដល់ភាគីយើងផងថា យើងត្រូវតែគោរពគោលការណ៍សន្មតថាគ្មានទោសជាមុន។ យើងបានធ្វើសំណើសុំឲ្យមានការផ្តល់សំណងតាមផ្លូវតុលាការ ប៉ុន្តែមិន -- តាមការពិត -- អ៊ីចឹងការ -- បាទមានកំហិតមួយទៀត គឺទាក់ទង

ទៅនឹងការផ្តល់ហិរញ្ញប្បទានដល់គម្រោង ដោយជំទាស់នៅក្នុងសំណុំរឿង ០០២/០១ នៃការបង្កើតមូលនិធិប៉ះប៉ូវដល់ដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានបង្កើត មានយន្តការមួយដើម្បីបញ្ជូនទៅអ្នកផ្តល់ជំនួយ ហើយ<ទោះបីវាស្រប>ច្បាប់<សម្រាប់>អ្នកផ្តល់ជំនួយនោះ<ក៏ដោយ ក៏>គាត់មានអាណត្តិមានអាទិភាព ក៏ប៉ុន្តែគម្រោងទាំងអស់នេះ គឺថាមាន -- វាមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើភាពប្រព្រឹត្តធ្វើទៅបាននៃគម្រោងសុំសំណង។ ឧទាហរណ៍ ដូចជា ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន គាត់សុំឱ្យធ្វើ មានស្តូប<នៅទូទាំងប្រទេស> ហើយគម្រោងទាំងអស់នេះ អត់ដែលមានអ្នកណាជួយទេ សូម្បីតែអាជ្ញាធរក៏មិនដែលជួយដែរ។ មានគម្រោងមួយទៀតដែរ ដែលអាចជួយឱ្យដើមបណ្តឹងរដ្ឋប្បវេណីដែលជាទូទៅគាត់ចាស់ៗ ហើយដើម្បីឱ្យគាត់ទទួលបាននៅការព្យាបាល<ថែទាំសុខភាព> ហើយគម្រោងហ្នឹង គឺដើមបណ្តឹងរដ្ឋប្បវេណីគាត់ត្រូវការសម្បើមណាស់ ក៏ប៉ុន្តែមិនបានទទួលហិរញ្ញប្បទានទេ។ មានកំហិតមួយទៀត គឺថាគម្រោងសំណងមួយចំនួននោះ មិនអាចកើតឡើងទេ។ ដើម្បីកើតឡើងទាស់តែមានកិច្ចសហប្រត្តិបត្តិការជាមួយជាមួយ<រាជ>រដ្ឋាភិបាល តាំងពីចាប់ផ្តើមនៃសំណុំរឿង០០២នេះ តាំងពីឆ្នាំ២០១៣ យើងបានសុំទៅរាជរដ្ឋាភិបាលកម្ពុជា ពីព្រោះថា រដ្ឋាភិបាលគាត់មានកាតព្វកិច្ចដែរ ក្នុងការផ្តល់សំណង។ អ៊ីចឹងយើង អង្គាល់នោះ គោលគំនិតរបស់យើង គឺយើងចង់សុំឱ្យគាត់ផ្តល់ហិរញ្ញប្បទានដល់គម្រោងមួយចំនួន ក៏ប៉ុន្តែដល់ចុងក្រោយនោះ យើងបានបង្ហាញគម្រោងតែមួយទេ ដែលទាក់ទងទៅនឹងការចូលពិគ្រោះឯកសារទាក់ទងទៅនឹង អ.វ.ត.ក គឺជាឯកសារច្បាប់ <ឧបត្ថម្ភដោយទីស្តីការគណៈរដ្ឋមន្ត្រី ហើយសហភាតារបស់ខ្ញុំ លោក ពេជ អង្គ នឹងជម្រាបបន្ថែមទៀត>។

[១៥:១២:២៩]

មានកំហិតមួយទៀតទាក់ទងទៅនឹងក្របខ័ណ្ឌស្ថាប័ន ទាក់ទងទៅនឹងបញ្ហាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក កាលធ្វើវិសោធនកម្ម<វិធាន>ផ្ទៃក្នុងនៅឆ្នាំ២០១០ហ្នឹង គឺធ្វើឱ្យបាត់លំនឹងរវាងសំណងតាមផ្លូវតុលាការ ដែលសម្រាប់ផ្តល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលយើងសហការជាមួយនឹង វី.អេស.អេស ហើយនិង ទន្ទឹមគ្នាពេលហ្នឹងដែរហ្នឹង គឺយើងបង្កើតគម្រោងសំណងក្រៅផ្លូវតុលាការដែលសម្រាប់ជនរងគ្រោះទាំងអស់តែម្តង។ យើងដឹងថា មានចំនួនតិចណាស់ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលនៅចំពោះមុខតុលាការនេះ ហើយនិងការសំណងក្រៅផ្លូវតុលាការដែលវាជាប់ទៅនឹងតុលាការយើងហ្នឹងដែរ។ ក៏ប៉ុន្តែមិនពាក់ព័ន្ធទៅនឹងពិរុទ្ធភាពនៃជនជាប់ចោទ<ក្នុងសំណុំរឿង០០២/០២>នោះទេ។ សំណងនេះ គឺសំដៅជូន<>ទៅដល់ជនរងគ្រោះ<នៃរបបខ្មែរក្រហម មានលក្ខណៈ>

ទូលំទូលាយទូទាំងប្រទេសកម្ពុជាតែម្តង។ <ខាងអង្គភាពជនរងគ្រោះមិនចង់ពិនិត្យឲ្យស៊ីជម្រៅគំនិតបន្ថែមមកលើអាទិភាពនៃវិវឌ្ឍនភាពសំណងដែលមានកំហិតបែបនេះទេ។> <>ចំណុចមួយនេះ <ជាប្រយោល> គឺគូសបញ្ជាក់ពីការលំបាកនៃការបញ្ជាក់យុត្តិសាស្ត្រសមហេតុផលមួយ ថាតើអ្នក តើសហចារី គឺអ្នកទទួលខុសត្រូវរួមនោះ ផ្នែកមួយនេះអ្នកណាខ្លះ។ ហើយដោយសារយើងពិបាកសហការជាមួយនឹង វី.អេស.អេស ក៏ប៉ុន្តែការងារនេះ វាទំនួលខុសត្រូវរួម ក៏ប៉ុន្តែយើង<>ត្រូវតែដឹងពីការលំបាកមួយចំនួន ដែលដៃគូយើងហ្នឹងក៏គាត់រងលំបាកដែរ ហើយនិងបញ្ជី -- យើងនឹងបង្ហាញជូននៅថ្ងៃ -- ដែលបង្ហាញនៅថ្ងៃនេះ ហើយនិងជាលទ្ធផលនៃការងារដ៏លំបាករបស់យើង ដូចថា គំនិតមួយទៀតគឺថាការជួយគ្នាទៅវិញទៅមករឿងសំណងតាមផ្លូវតុលាការ និងសំណងតាមក្រៅតុលាការមិនដែលត្រូវបានសិក្សាឲ្យបានលម្អិតនោះទេ។ ហើយគំនិតនេះ គឺធ្វើឲ្យយើងពិចារណា ហើយនិងយើងបង្ហាញជូននៅថ្ងៃនេះ។

ទី១ គម្រោងនេះ <ត្រូវ>ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ហើយដើម្បី -- ចំណុចធ្វើការងារពិបាកនេះ គឺយើងត្រូវប្រឹងប្រែងឲ្យអស់ចិត្ត ដោយមានជំនួសពី វី.អេស.អេស ផង និងពិគ្រោះជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងដៃគូរបស់យើង ដើម្បីធ្វើគម្រោងនេះឡើង។ យើងបានសុំឲ្យអង្គការក្រៅរដ្ឋាភិបាលបញ្ជូន -- អ៎! បញ្ចូលការពិគ្រោះជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី។ ទាក់ទងទៅនឹងការពិគ្រោះនេះ គឺយើងព្យាយាមឲ្យមានតម្លាភាពបំផុតនៅក្នុងសេចក្តីសន្និដ្ឋានស្តាពររបស់យើងនេះ គឺយើងបញ្ចូលទិន្នន័យទាំងអស់ ដែលយើងទទួលបានពីការពិគ្រោះ។ ចំណុចទី១ គឺអត្ថប្រយោជន៍ដែលយើងផ្តល់ជូនទៅដើមបណ្តឹងរដ្ឋប្បវេណី ហើយទី២ ស្របតាមយុត្តាធិការនៃអង្គជំនុំជម្រះ តាមសមណុំរឿង០០២/១ហ្នឹង គឺគម្រោងភាគច្រើនហ្នឹង គឺត្រូវតែផ្តល់ផលប្រយោជន៍ទៅដល់ជនរងគ្រោះដែលមិនមានអ្នកតំណាងផងដែរ។

[១៥:១៦:២៨]

មិនមានការកម្រិតណាមួយដែលយើងលើកឡើងនេះ ប៉ះពាល់ដល់គុណភាពនៃគម្រោងដែលយើងសុំឲ្យតុលាការទទួលស្គាល់នោះទេ មានគម្រោង១២ ដែលយើងទទួលបានហរិញ្ញប្បទានសព្វគ្រប់អស់ហើយ ហើយខ្លះហ្នឹងធ្វើបានមួយផ្នែកមួយនោះទេ។ លោក អង្គ ពេជ ហើយនិងខ្ញុំបាទ និងខ្ញុំផ្ទាល់បានសុំឲ្យទទួលស្គាល់គម្រោង១១។<>យើងបានបញ្ចូលនៅក្នុងសំណើរបស់យើង គម្រោងចំនួនប្រាំពីរដែលមិនទាន់មានជំនួយនៅឡើយ។ ដោយយើងនឹងមិនបង្ហាញថ្ងៃនេះទេ ដោយសារមិនមានទេ ហើយ

ច្រើនពេក យើងមានបង្ហាញនៅក្នុងសារណាស្ដាពរបញ្ចប់ការដេញដោលរបស់យើងហើយយើងសុំរយៈពេលដល់ខែ១១ ដើម្បីដាក់សារណានេះរបស់យើង ដោយអនុលោមទៅតាមវិធាន២៣(៥) ស្ទួនបួន។ បើសិនជាពីនេះ ដល់ខែ១១នេះ យើងមិនបាន មិនអាចដាក់នៃឯកសារណាមួយ ដើម្បីសុំជំនួយសម្រាប់គម្រោងទាំងអស់នេះទេ យើងសុំឱ្យអស់លោក លោកស្រីចៅក្រម <ពិចារណា កុំធ្វើសេចក្ដីសម្រេចក្នុងសាលក្រមរបស់អង្គជំនុំជម្រះច្រានចោល>គម្រោងអស់នេះ<ដោយសារខ្វះថវិកាអី>។

ខ្ញុំសូម<បង្ហាញគម្រោងបី ហើយ>លោកមេធាវី អង្គ ពេជ <នឹងបង្ហាញគម្រោងដែលនៅសេសសល់ ហើយមុននឹងបញ្ចប់ ខ្ញុំនឹងឡើងនិយាយវិញអំពីគម្រោងចុងក្រោយដែលខ្លួនខ្ញុំផ្ទាល់ ចង់គាំទ្រ ហើយបង្ហាញអង្គជំនុំជម្រះ។> គម្រោងបី ដែលខ្ញុំនឹងបង្ហាញនោះ គឺស្ថិតនៅក្នុងប្រភេទនៃការ -- ធានាថា នឹង<មិន>មានការកើតឡើងម្ដងទៀត។ វាជាប្រភេទនៃការ -- នៃសំណងដែលទទួលស្គាល់ដោយអត្ថបទច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសំណង។ ជាពិសេសពាក់ព័ន្ធនឹងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្ដីអំពីសំណង។

[១៥:១៨:៤៧]

គម្រោងទី១ គឺជាគម្រោងដែលយើងបានរៀបចំ ដោយសហការជាមួយនឹងមជ្ឈមណ្ឌលបុប្ផាណា។ គឺមជ្ឈមណ្ឌលធនធានសោតទស្សន៍ បុប្ផាណា។ នេះគឺជាគម្រោងបង្កើតកម្មវិធីកុំព្យូទ័រពាក់ព័ន្ធនឹងការរៀនអំពីប្រវត្តិសាស្ត្រ ប្រវត្តិខ្មែរក្រហម។ យើង<នឹង>ចាក់ផ្សាយវីដេអូទី១ រួចមកហើយ ដែលពន្យល់ជាក់ស្ដែងជូនអង្គជំនុំជម្រះ និងភាគី អំពីខ្លឹមសារ និងគោលបំណងនៃគម្រោងនេះ ហើយនិងផលប្រយោជន៍ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។ នេះគឺជាគម្រោងដែលបានធ្វើឡើងជាមួយនឹងអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា ហើយគម្រោងនេះ គឺថាអាចដាក់កម្មវិធីកុំព្យូទ័រហ្នឹងទៅតាមសាលារៀននៅស្រុកខ្មែរយើង។ <គម្រោងនេះត្រូវបានបង្ហាញជូន>ដើមបណ្ដឹងរដ្ឋប្បវេណី <៣៤០>នៅតាមវេទិការួចមកហើយ។ ហើយយើងបានបង្ហាញជូននៅកំពង់ចាមហ្នឹង គឺដល់ដើមបណ្ដឹងរដ្ឋប្បវេណី គឺ១៣៦នាក់ <កាលពីខែកុម្ភៈ ២០១៧>។ អ៊ីចឹងឥឡូវនេះ ខ្ញុំសូមមើលវីដេអូ សុំដាក់វីដេអូទី១ នៅលើគម្រោងមួយ ដែលមានចំណងជើងថា "កម្មវិធីកុំព្យូទ័រពាក់ព័ន្ធនឹងការរៀនសូត្រអំពីប្រវត្តិខ្មែរក្រហម"។

[១៥:២០:១១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

"កម្មវិធីសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈប្រព័ន្ធអេឡិចត្រូនិច ត្រូវបានធ្វើឡើងដើម្បីផ្តល់លទ្ធភាពដល់សាធារណជន ជាពិសេស យុវជនកម្ពុជាដើម្បីសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ លោកអ្នកអាចប្រើប្រាស់ឧបករណ៍អេឡិចត្រូនិច ដូចជា ថាប្លេត ដើម្បីសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនេះ។ លើសពីនេះ លោកអ្នកក៏អាចប្រើប្រាស់ទូរស័ព្ទដៃដើម្បីស្វែងរកព័ត៌មាន និងដើម្បីសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនេះផងដែរ។ អត្ថបទសរសេរ ខ្សែភាពយន្ត ខ្សែអាត់សំឡេង រូបថត ស្នាដៃសិល្បៈផ្សេងៗ ស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ព្រមទាំងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេស បទសម្ភាសន៍ជាមួយនឹងជនរងគ្រោះនៃរបបខ្មែរក្រហម ត្រូវបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមមួយនេះ។ នៅក្នុងគម្រោងរបស់យើងហ្នឹង យើងបែងចែកជាបីក្រុម។ ក្រុមទី១ គឺក្រុមអ្នកស្រាវជ្រាវ និងអ្នកនិពន្ធ ដែលពួកគាត់ទទួលបន្ទុកក្នុងការចងក្រង និពន្ធប្រវត្តិសាស្ត្រខ្មែរក្រហម។ ការចងក្រង និងការនិពន្ធប្រវត្តិសាស្ត្រនេះ ត្រូវបានធ្វើឡើងតាមលក្ខណៈវិទ្យាសាស្ត្រដោយមានការផ្តល់យោបល់ និងការត្រួតពិនិត្យពីគណៈកម្មការបច្ចេក-ទេសជាតិ និងអន្តរជាតិ ដែលពួកគាត់សុទ្ធតែជាអ្នកជំនាញទៅលើប្រវត្តិសាស្ត្រខ្មែរក្រហមហ្នឹង ជាយូរយារណាស់មកហើយ។ ចំណែកឯក្រុមទី២ វិញ គឺជាក្រុមអ្នកផលិតខ្សែភាពយន្ត។ ពួកគាត់ចុះសម្ភាសជាមួយនឹងជនរងគ្រោះនៃរបបខ្មែរក្រហម ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកឯកទេសមួយចំនួនដើម្បីប្រមែប្រមូលព័ត៌មានក្នុងការចងក្រងធ្វើជាខ្សែភាពយន្ត។ ក្រុមទី៣ គឺជាក្រុមទទួលបន្ទុកផ្នែកព័ត៌មានវិទ្យា។ គាត់ជាអ្នកទទួលបន្ទុកក្នុងការសរសេរកូដ ក្នុងការសរសេរកម្មវិធីផ្សេងៗ ធ្វើយ៉ាងណាផ្តល់ភាពងាយស្រួលក្នុងការដាក់បញ្ចូលព័ត៌មានទាំងអស់ហ្នឹង នៅក្នុងឧបករណ៍អេឡិចត្រូនិច។

[១៥:២៣:២៦]

ចំពោះកម្មវិធីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមនេះ គឺវាមានសារៈសំខាន់ណាស់សម្រាប់សិស្សនិស្សិតទូទៅ ដូចជាពួកខ្ញុំដែលជាអ្នករៀនហ្នឹង ដោយសារវាមាន ក្នុងហ្នឹងមានអត្ថបទដែលសង្ខេបស្រួលយល់ដែលធ្វើឱ្យយើងអាចស្វែងយល់បានអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយក្នុងនោះទៀតសោតនៅក្នុងកម្មវិធីហ្នឹងវាមានបញ្ចូលទាំងរូបភាព-សំឡេង ហើយនិងវីដេអូដែលយើង ដែលអាចធ្វើឱ្យយើងមើលបាន អានបាន ហើយនិងស្តាប់បាននៅក្នុងពេលដំណាលគ្នា។

កម្មវិធីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមនេះ មានរូបថត វីដេអូ ឯកសារ ដែលធ្វើឱ្យខ្ញុំបានឃើញជាក់ស្តែងនូវទិដ្ឋភាពដែលបានកើតឡើងនៅក្នុង-- (ចម្រៀង)

*ការសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈកម្មវិធីអេប គឺមានសារៈសំខាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ជនរងគ្រោះដែលក្នុងសម័យខ្មែរក្រហមទាំងអស់ ដោយសារទី១ គឺយើងបានកត់ត្រារឿងរ៉ាវទាំងអស់របស់ជនរងគ្រោះនៅក្នុងកម្មវិធីហ្នឹង។ ទី២ទៀតគឺយើងបានចែករំលែកទៅដល់មនុស្សសម័យថ្មី មនុស្សជំនាន់ក្រោយហ្នឹង តាមរយៈរឿងរ៉ាវ របស់កម្មវិធីនេះ បើថាគេចង់ចូលមើលរឿងដែលកើតនៅក្នុងអតីតកាល គឺគ្រាន់តែចូលទៅក្នុងកម្មវិធីហ្នឹង គឺគាត់អាចដឹង តើដំណើរការជីវិតហ្នឹង វាយ៉ាងម៉េចខ្លះ? អ៊ីចឹងវាមានភាពងាយស្រួល។ ដល់អ៊ីចឹងហើយខ្ញុំសប្បាយចិត្តនៅក្នុងការចែករំលែក។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:២៥:២២]

លោកប្រធានគម្រោងទី២ ដែលយើងខ្ញុំស្នើសុំឱ្យតុលាការទទួលស្គាល់ក្នុងក្របខ័ណ្ឌនៃប្រភេទនៃការធានាដោយមិនឱ្យមានការកើតឡើងម្ដងទៀតនោះ គឺពាក់ព័ន្ធនឹងការសន្ទនាអន្តរជំនាន់ គឺជាគម្រោងដែលដៃគូរបស់យើងហ្នឹងគឺជាមជ្ឈមណ្ឌលឯកសារកម្ពុជា។ គម្រោងនេះ គឺជាគម្រោងបណ្ដុះបណ្ដាលគ្រូ <និងគ្រូកម្រិតសាកលវិទ្យាល័យ>អំពីប្រវត្តិសាស្ត្រខ្មែរក្រហម<តាមរយៈសិក្ខាសាលា>។ មេបង្រៀននេះគឺ ដាក់បញ្ចូលនូវរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី យើងមានរូបថត ហើយខ្ញុំអាចចែកជូនទៅភាគីបាននៅពេលដែលខ្ញុំកំពុងតែនិយាយ។ ខ្ញុំភ្លេចអម្បាញ់មិញ ភ្លេចរៀបរាប់អ្នកដែលអាចឱ្យគម្រោងបុប្ផាណា<ដំណើរការ>បាននោះ គឺសហភាពអឺរ៉ុប ហើយនិងមូលនិធិរេដ។ ពាក់ព័ន្ធនឹងគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានេះ គឺជាការបណ្ដុះបណ្ដាលគ្រូសាលារៀន និងគ្រូសាកលវិទ្យាល័យ ហើយយើងបានដាក់បញ្ចូលនូវរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងរដ្ឋប្បវេណី ១៤៧នាក់ បានទទួលនូវបទបង្ហាញអំពីគម្រោងនេះ ហើយពួកគាត់បានផ្ដល់យោបល់មតិពាក់ព័ន្ធទៅនឹងគម្រោងមួយនេះជាមួយនឹង<វត្តមានរបស់>មជ្ឈមណ្ឌលឯកសារកម្ពុជា។ គម្រោងហ្នឹងគឺសហភាពអឺរ៉ុបជាអ្នកផ្ដល់មូលនិធិទាំងស្រុងតែម្ដង។

[១៥:២៧:០៥]

គម្រោងទី៣ ដែលយើងស្នើសុំឱ្យទទួលស្គាល់នូវប្រភេទនៃការធានាមិនឱ្យកើតឡើងដដែលនោះគឺវាពាក់ព័ន្ធនូវគំនិតនៃការសន្ទនាអន្តរជំនាន់រវាងដើមបណ្ដឹងរដ្ឋប្បវេណី និងយុវជនជំនាន់ក្រោយ។ គម្រោងនេះយើងបានបង្កើតឡើងជាមួយមេតាហោស៍ និងសមាគមសកម្មភាពសិល្បៈខ្មែរ ហើយនិង<អង្គការ>យុវសន្តិភាព។ គម្រោងនេះមានចំណងជើងថា "គម្រោងអណ្ដើកក្ដាហាន"។ គឺយើងបង្ហាញ

អំពីល្ខោនរឿងល្ខោនមួយដែលដើរតួដោយយុវជនកម្ពុជា។ រឿងល្ខោនហ្នឹង គឺនិយាយអំពីភាពក្លាហាននៅក្នុងរបបខ្មែរក្រហម ហើយថាតើហេតុការណ៍ទាំងអស់ហ្នឹងវាអាចផ្សារភ្ជាប់ទៅនឹងអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះយ៉ាងដូចម្តេចខ្លះ។ គម្រោងនេះត្រូវបានធ្វើឡើងដោយមានអនុស្សរណៈនៃការយោគយល់ជាមួយក្រសួងអប់រំ។ រឿងល្ខោននេះ គឺនឹងត្រូវចាក់បញ្ចាំងនៅតាមសាលារៀននៅទូទាំងប្រទេសកម្ពុជា ហើយក្នុងពេលដែល<>បង្ហាញចប់ហ្នឹង នឹងមានដើមបណ្តឹងរដ្ឋប្បវេណីគាត់អាចនិយាយពាក់ព័ន្ធនឹងចំណុចទាំងអស់នេះ។ ដូច្នេះ ខ្ញុំនឹងបង្ហាញវីដេអូទី២ ដែលពាក់ព័ន្ធទៅនឹងខ្លឹមសារនៃ "គម្រោងអណ្តើកក្លាហាន" នេះ។

[១៥:២៨:៣៥]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[-អណ្តើកដើរបានលុះត្រាតែវាដកកចេញពីក្នុង។ (ភ្លេង)*

*-ហើយអានេះគឺជាសត្វអណ្តើកដែលខ្ញុំចិញ្ចឹម ខ្ញុំហៅវាថា អណ្តើកនិនចារទេ។*

*-ឃើញអញហៅហើយ ម៉េចក៏មិនហៅ! ហាស់!*

*-មិត្តបង! យកខ្ញុំទៅណាមិត្តបង?*

*-ទៅកន្លែងមានសុវត្ថិភាពហ្នឹង ទាន់គេប្តូរវេទយាមគ្នា លឿនឡើង!*

*-ចុះម៉ែខ្ញុំ?*

*-តែយើងត្រូវធ្វើម៉េចទៅដើម្បីទប់ស្កាត់សោកនាដកម្មហ្នឹងកុំឲ្យកើតឡើងម្តងទៀត?*

*-ហើយចៅៗទាំងអស់គ្នាគិតថា យើងត្រូវធ្វើដូចម្តេច អ្នកស! ចៅស្រី? យើងត្រូវធ្វើដូចម្តេច?*

*-ខ្ញុំត្រូវមានភាពក្លាហាន*

*-អូយ! ត្រូវហើយ!*

*(សំឡេងទះដៃ)*

*-វាមានភាពក្លាហាន ចេះការពារប្រជាជនពីភាពអយុត្តិធម៌ នែ! ឡូយអត់?*

*-ឡូយ! (ភ្លេង)*

*-ដើម្បីពង្រឹងការចូលរួមរបស់យុវជនក្នុងលក្ខខណ្ឌនៃការរំពុកឡើងវិញ ក៏ដូចជាឆ្លុះបញ្ចាំងអំពីរឿងរ៉ាវដែលកើតមានឡើងចំពោះប្រពលរដ្ឋខ្មែររាប់លាននាក់កាលពីសម័យខ្មែរក្រហមនោះ "គម្រោងអណ្តើកក្លាហាន" យើងបានបង្កើតនូវកិច្ចសន្ទនាអន្តរជំនាន់ រវាងយុវជននិងដើមបណ្តឹងរដ្ឋប្បវេណី។*

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*ហើយដើមបណ្ដឹងរដ្ឋប្បវេណី បានចូលរួមជាសាក្សីចំពោះមុខតុលាការខ្មែរក្រហម ឬក៏អង្គជំនុំជម្រះវិសាមញ្ញនៅតុលាការកម្ពុជា។ ចំណែកឯពួកគាត់វិញ គាត់មានការចាប់អារម្មណ៍ក៏ដូចជាជឿជាក់ខ្លាំងចំពោះដំណើរការនៃការអនុវត្តនូវគម្រោងរបស់យើង តាមរយៈការសម្ដែងនូវល្ខោននិយាយ ឬក៏តាមបែបសិល្បៈដើម្បីការអប់រំ ដោយមានការចែករំលែកនូវរឿងរ៉ាវជាក់ស្ដែង ដែលកើតឡើងចំពោះគាត់កាលពីសម័យខ្មែរក្រហមជាមួយនឹងយុវជនជំនាន់ក្រោយ។*

*-កាលបញ្ចេញយោបល់ និងការឆ្លើបទបង្ហាញរបស់អ៊ំចាស់ៗពីរនាក់ដែលឈ្មោះ សុខឿន និង អ៊ំឡាយ អម្បាញ់មិញនេះ ខ្ញុំគិតថាវាល្អដែរ គឺដើម្បីគាត់ចង់ចែករំលែកនូវអ្វីដែលពិបាកនៅក្នុងរបបខ្មែរក្រហមទៅដល់ ជាពិសេសគឺពួកខ្ញុំផ្ទាល់ហ្នឹង។*

*-អ៊ីចឹងអារម្មណ៍របស់ខ្ញុំ កាលណាបានជជែកប្រាប់ក្មេងៗទៅ ខ្ញុំដូចជាមានការធូរអារម្មណ៍ឲ្យអស់ចិត្ត។ បើថាអ្វីដែលយើងចង់បង្ហាញ ចង់ប្រាប់ហ្នឹង បើសិនជាយើងមិនបានប្រាប់ ដូចជាវានៅក្នុងអារម្មណ៍តឹងតែងហ្នឹង។ បើយើងបានជជែកប្រាប់កូនៗ យើងក្មេងៗយើងអ៊ីចឹងទៅ ហើយក្មេងយើងបើគាត់មិនយល់ ខ្ញុំបន្ថែម បាទ ពន្យល់គាត់ឲ្យទាល់តែយល់។*

*-ពេលគេចង់ខ្ញុំយកទៅវៃចោល លោកគ្រូ មានមេក្រុមជាមូលដ្ឋានចាស់ហ្នឹងគាត់ជួយខ្ញុំចាស ដូចរឿង "អណ្ដើកក្លាហាន" ម្សិលមិញអ៊ីចឹង គឺសាច់រឿងអណ្ដើកក្លាហានម្សិលមិញដូចសាច់រឿងខ្ញុំអ៊ីចឹង។ ចាស ខ្ញុំអរគុណហើយដែលបានអ្នកគ្រូអញ្ជើញខ្ញុំមកហើយ ហើយខ្ញុំបានទស្សនារឿងអស់នេះទៀត ខ្ញុំមានអារម្មណ៍ថាធូរស្រាលក្នុងចិត្ត។*

*-ក្រោយពេលរបបខ្មែរក្រហមរលំទៅ ហើយខ្ញុំបាទបាននិយាយចំពោះកូនចៅ ទូន្មានកូនចៅ ឬ/និងនិយាយអំពីប្រវត្តិលំបាកលំបិនក្នុងរបបខ្មែរក្រហមប្រាប់កូនចៅដែរ។ បាទ កូនចៅដែលវាអត់ទាន់ដឹងក្ដី ទើបនឹងដឹងក្ដីនៅពេលបច្ចុប្បន្ននេះវាថាវាអត់ជឿទេ មិនដែលមនុស្សឯណាមកធ្វើបាបមនុស្សអ៊ីចឹងទេ។ ]*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:៣៣:០៣]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

លោកប្រធាន គម្រោងនេះត្រូវបានផ្ដល់មូលនិធិ<ទាំងស្រុង>ដោយសហភាពអឺរ៉ុប <ហើយនិងវិទ្យាស្ថាន អាយ.អេហ្វ.អេ អាល្លឺម៉ង់>។ ហើយឥឡូវនេះខ្ញុំនឹងទុកវេទិកានេះជូនទៅលោក អង្គ ពេជ

ដើម្បីរៀបរាប់អំពីគម្រោងផ្សេងទៀត។ ហើយបន្ទាប់មកទៀត ខ្ញុំនឹងសុំពេលបន្តិចដើម្បីបង្ហាញអំពីមូលហេតុសម្រាប់គម្រោងទី<>២។

**លោក ពេជ អង្គៈ**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងសាធារណជនសាជាថ្មី។ គម្រោងបន្ទាប់គឺជាគម្រោងដែលមានប្រភេទដែលជាការធានាមិនឱ្យកើតមានសាជាថ្មីដែលផ្តល់ប្រយោជន៍ជាក់លាក់នៃដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។ មានគម្រោងចំនួនបីដែលត្រូវបានរៀបចំឡើង ដោយឆ្លើយតបទៅនឹងការខូចខាតដែលទទួលរងដោយក្រុមជាក់លាក់ពីឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពនៃសំណុំរឿង០០២។ គម្រោងទាំងនេះគឺផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលរងផលប៉ះពាល់ដោយការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាមវៀតណាម ការរៀបចំ -- ការរៀបការដោយបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សហមេធាវីនាំមុខពិចារណាឃើញថា គម្រោងទាំងនេះផ្តល់ផលពាក់ព័ន្ធទៅនឹងវិធានការសំណងនៃការធានាមិនឱ្យកើតមានសាជាថ្មីទៀត ហើយប៉ះប៉ូវទៅដល់ការខូចខាតដែលទទួលរងដោយក្រុមដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះទាំងនោះ។ ហើយដើម្បីលើកកម្ពស់ការយល់ដឹងអំពីឧក្រិដ្ឋកម្មដែលបានប៉ះពាល់ ជាពិសេសដល់ប្រជាជននៃក្រុមជាក់លាក់ទាំងនោះ។ មេធាវីនាំមុខក៏សូមស្នើថា គម្រោងទាំងនេះត្រូវបានទទួលស្គាល់ថា ជាសំណងតាមផ្លូវតុលាការនៅក្នុងសំណុំរឿង០០២ផងដែរ។

[១៥:៣៥:០០]

គម្រោងនេះមានគម្រោងប្រព័ន្ធផ្សព្វផ្សាយតាមសហគមន៍សម្រាប់ជនជាតិចាម និងខ្មែរក្រហមអំពីជនជាតិចាមនិងខ្មែរក្រហម។ សមាគមវប្បធម៌កម្ពុជា-អាល្លឺម៉ង់ ដោយសហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានបង្កើតនិងអនុវត្តគម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍ប្រជាជនចាម និងខ្មែរក្រហម ដើម្បីជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីជនជាតិចាម គ្រួសាររបស់ពួកគាត់ និងមនុស្សជំនាន់ក្រោយតាមរយៈការអប់រំជាសាធារណៈអំពីបទពិសោធន៍របស់សហគមន៍ចាមនៅក្នុងសម័យខ្មែរក្រហម។ តាមរយៈសកម្មភាពនៃគម្រោង អ្នកថតរូប ផលិតករភាពយន្ត និងអ្នកស្រាវជ្រាវជំនាន់ក្រោយអំពីសហគមន៍ចាម នឹងធ្វើការផលិតខ្សែភាពយន្តពីរខ្សែ ដែលឆ្លុះបញ្ចាំងអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិចាម។ គម្រោងនេះចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០១៦។ នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៦ សហគមន៍កម្ពុជាអាល្លឺម៉ង់ បានដាក់ឱ្យប្រើប្រាស់នូវឯកសារការបះបោរនៃ

ប្រជាជនចាមនៅស្វាយឃ្លាំង និងការដាក់តាំងពិព័រណ៍តាមប្រព័ន្ធផ្សព្វផ្សាយចម្រុះស្ដីអំពីប្រជាជនចាម និងខ្មែរក្រហម។ ក្នុងឆ្នាំ២០១៧ កម្រងប្រព័ន្ធផ្សព្វផ្សាយចម្រុះនេះ នឹងត្រូវបានចងក្រងបញ្ចូលគ្នាជាខ្សែវីឌីអូជាភាសាចាម ភាសាខ្មែរ និងភាសាអង់គ្លេស។ គម្រោងនេះនឹងដាក់បញ្ចូលក្នុងគេហទំព័រមួយដើម្បីបង្កើត -- បង្កើនការចូលមើលឲ្យបានកាន់តែទូលំទូលាយពីសំណាក់យុវជនកម្ពុជាជំនាន់ក្រោយ។គម្រោងនេះផ្ដល់ប្រយោជន៍ទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី ជាពិសេសឆ្លើយតបទៅនឹងខូចខាត ដែលទទួលរងដោយដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិចាមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងចងក្រងជាឯកសារនូវបទពិសោធន៍របស់ពួកគាត់សម្រាប់មនុស្សជំនាន់ក្រោយផងដែរ។

[១៥:៣៧:១៩]

ខ្សែភាពយន្តនេះ នឹងបង្ហាញអំពីដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើននាក់ ហើយក៏បានអនុញ្ញាតឲ្យកូនចៅរបស់ពួកគាត់ចូលរួមក្នុងដំណើរការរៀបចំ និងផលិតខ្សែភាពយន្តនេះផងដែរ។ ចំពោះបញ្ហាថវិកា គម្រោងនេះបានទទួលថវិកាគ្រប់គ្រាន់ពីស្ថានទូតស្វីសប្រចាំនៅទីក្រុងបាងកក និងបានទទួលមូលនិធិថវិកាពីមូលនិធិ*ហៃនរិច្ចប៊ូល*។ គម្រោងមួយទៀតមានឈ្មោះថា "ផ្កាស្លាក្រោមអង្គការ"។ វិទ្យាស្ថានសិល្បៈខ្មែរសហការជាមួយអង្គការក្ដីករុណា មជ្ឈមណ្ឌលបុប្ផាណា និងអង្គការចិត្តសង្គមអន្តរវប្បធម៍ ធី.ភី.អូ បានបង្កើត និងកំពុងតែអនុវត្តគម្រោង "ផ្កាស្លាក្រោមអង្គការ" ដែលបានស្នើឡើងជាគម្រោងសំណងតាមផ្លូវតុលាការ ដោយមានកិច្ចសហការពីមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ។ គម្រោងនេះបានបង្កើតរបាំបុរាណមួយ និងការតាំងពិព័រណ៍ចល័ត ដោយបង្ហាញពីបរិយាកាសអាពាហ៍ពិពាហ៍ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ គម្រោងនេះរួមមាន ការសម្ដែងជាសាធារណៈ ការជជែកគ្នា ការសន្ទនាតាមសហគមន៍ និងអន្តរជំនាន់ដើម្បីជំរុញការពិភាក្សាជាសាធារណៈឲ្យមានកាន់តែច្រើន និងការយល់ដឹងអំពីការរៀបការដោយបង្ខំ ដែលប្រព្រឹត្តទៅនៅក្នុងរបបនោះ។ ការអនុវត្តគម្រោងនេះចាប់ផ្ដើមនៅខែឧសភា ឆ្នាំ២០១៦ ហើយសកម្មភាពនៃគម្រោងនេះ រំពឹងថានឹងចប់នៅខែមីនា ឆ្នាំ២០១៨។ នៅថ្ងៃទី២០, ២១ និង២២ ខែមករា ឆ្នាំ២០១៧ កន្លងទៅនេះ ដៃគូអនុវត្តនៃគម្រោងនេះបានរៀបចំឲ្យមានការសម្ដែងរបាំបុរាណទាំងនេះ និងការតាំងពិព័រណ៍អំពី "ផ្កាស្លាក្រោមអង្គការ" នៅរាជធានីភ្នំពេញ។ ការសម្ដែងរបាំ និងការតាំងពិព័រណ៍មួយទៀតបានប្រព្រឹត្តទៅ និងប្រព្រឹត្តនៅក្នុងខេត្តបាត់ដំបងនៅថ្ងៃទី០៦ ខែឧសភា ហើយមួយទៀតនឹងត្រូវប្រព្រឹត្តទៅនៅខេត្តកំពត ក្នុងខែកក្កដា ឆ្នាំ២០១៧។ ដូច្នេះ ខ្ញុំសូមបញ្ចាំងជូនលោកប្រធាន លោក លោកស្រីចៅក្រម នៅវីដេអូនៃគម្រោង "ផ្កាស្លាក្រោម

អង្គការ" ដូចតទៅ៖

[១៥:៤០:១០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[-គម្រោងផ្កាស្លាហ្នឹង ដែលគេចង់បានហ្នឹង តើពូមីងហ្នឹងចង់បានអ៊ីចឹងដែរ អត់? ហើយបើពូមីងចង់បាន ចង់ឃើញរូបភាពវាយ៉ាងដូចម្ដេច? បើនិយាយអំពីកុន គួរដាក់កុនរបៀបម៉េច? ហើយបើសិនលេងជាល្ខោន តើគួរជាល្ខោនរបៀបម៉េច? ហើយកុនល្ខោនដែលយកទៅបញ្ចាំងផ្សព្វផ្សាយនៅតាមសហគមន៍ហ្នឹង គួរតែធ្វើរបៀបម៉េច? ហើយការព្យាបាលផ្លូវចិត្តវិញ គួរតែធ្វើជារបៀបម៉េចយ៉ាងម៉េច? បានសេចក្ដីថា បងចង់ឲ្យអាគម្រោងសាសនាហ្នឹងចេញដែរណ៎ា? បាទ។*

*-ឯកភាពសូមលើកដៃម្ដងទៀត ចំា? ចាស។*

*-សូមជម្រាបថា គម្រោងផ្កាស្លានេះមានសារៈសំខាន់ត្រង់ថា យើងបានផ្ដល់ឱកាសឲ្យពួកគាត់ដែលបានឆ្លងកាត់ការឈឺចាប់នៅក្នុងសម័យ ប៉ុល ពត ដែលគេបង្ខំឲ្យគាត់រៀបការហ្នឹងរាយរាប់រឿងរ៉ាវឈឺចាប់របស់គាត់ឲ្យពួកយើងស្រករក្រោយនេះបានស្ដាប់។ ដំណាក់កាលទី២ គឺយើងនឹងសរសេរជារឿងល្ខោនរបាំបុរាណបែបទំនើបមួយ។*

*-អង្គការក្ដីកុរុណារបស់យើង យើងចូលរួមជាមួយនឹងអង្គការប្អូនហ្នឹង ដោយផលិតសម្ភារៈពិព័រណ៍ យកពិព័រណ៍របស់យើងហ្នឹង ទៅតាំងបង្ហាញនៅបណ្ដាខេត្តនានា ហើយយើងមានកិច្ចសុន្ទនាអន្តរជំនាន់រវាងជនរងគ្រោះពីការបង្ខំឲ្យរៀបការ ជាមួយនឹងយុវជនជំនាន់ក្រោយ។*

*-មជ្ឈមណ្ឌលបុប្ផាណា ចូលរួមនៅក្នុងគម្រោងផ្កាស្លា ជាមួយនឹងអង្គការដទៃទៀតទីនេះ ក្នុងគោលបំណងធ្វើការកត់ត្រា ការចងចាំ និងប្រវត្តិសាស្ត្ររបស់ជនរងគ្រោះ ដែលត្រូវបានគេបង្ខំឲ្យរៀបការនៅក្នុងរបបខ្មែរក្រហម ហើយឯកសារដែលយើងកត់ត្រាបាននេះ យើងនឹងតម្កល់ទុកនៅក្នុងបុប្ផាណា និងផ្សព្វផ្សាយជូនសាធារណជនឲ្យទស្សនាបាននៅពេលខាងមុខនេះ។*

*-វិសមភាពរវាងភេទប្រុស និងភេទស្រី បែបពួកមិត្តឯង មានតែភេទប្រុស ប្រុសតែងមានជ្រើសរើស ឯភេទស្រីវិញ ពុំគ្រាន់តែគ្មានសិទ្ធិជ្រើសរើសប៉ុណ្ណោះទេ សូម្បីតែសិទ្ធិបដិសេធក៏គ្មានដែរ។ តើនេះគឺជាការបញ្ហាដែលមានយុត្តិធម៌របស់ពួកមិត្តឯងឬ? យើស! ខ្លាំង១១ ខ្លាំងដូចអ្នកឯងជាស្រី (ឮមិនច្បាស់)។*

*-បានល្អខ្លាំងណាស់ ខ្ញុំសូមសរសើរ បានល្អខ្លាំងណាស់ អ្នកគ្រូ បានដឹកនាំ ហើយស្រាវជ្រាវ*

*ឯកសារយកមកចងក្រងរឿងហ្នឹង។ ខ្ញុំពេញចិត្ត ហើយចុងក្រោយខ្ញុំសប្បាយចិត្ត។ ខ្ញុំរិភាគទៅអាទឹកផ្អែកនៅហ្នូរក៏សប្បាយចិត្តឃើញ ហើយឃើញក្នុងហ្នឹងឃើញអាមេខ្មែរក្រហមធ្វើអ៊ីចឹង ឃើញអ្នកគ្រូធ្វើអ៊ីចឹងមក ខ្ញុំសប្បាយចិត្តណាស់។ អើ! បានក្មេងជំនាន់ក្រោយបានឃើញរឿង នែ៎! សម័យ ដើមបណ្តឹងសម័យខ្មែរក្រហមគេធ្វើបាបអ៊ីចឹង។ ក្មេងជំនាន់ក្រោយនឹងយកទៅសិក្សារៀនសូត្រ ហើយដឹកនាំប្រទេសសាក្រោយនេះ មិនឲ្យរបបហ្នឹងកើតមាន។*

*-ដល់ពេលមកខ្ញុំបានមកមើលរឿងហ្នឹង ដូចថា បានឲ្យប្រជាជនជំនាន់ក្រោយដឹងឮ ខ្ញុំមានអារម្មណ៍ធូរស្រាលជាងមុន ដូចថា គេយកចិត្តទុកដាក់ក្នុងរឿងរបស់ខ្ញុំ។ ដូចថា គេថាមិនបានវាយតម្លៃមិនបានមើលងាយថា ខ្ញុំនេះជាស្រីអីមិនល្អអ៊ីចឹងណា៎។ គេនៅយល់ថា ខ្ញុំនេះនៅជាមនុស្សល្អត្រឹមត្រូវដែរ ដោយគេបង្ហំអ៊ីចឹង ខ្ញុំដូចថា មានអារម្មណ៍ធូរស្រាលជាងមុន។*

*-ល្អមែនទែន ហើយខ្ញុំគាំទ្រឲ្យមានការបន្តនូវស្នាដៃបែបនេះ ហើយនិងធ្វើការសម្តែងបន្តទៅទៀត សម្រាប់បើកឱកាសឲ្យមិនមែនតែអ្នកនៅទីក្រុង ប៉ុន្តែអ្នកនៅតាមជនបទនានាហ្នឹងគាត់បានដឹងឮនៅបញ្ហានេះ ហើយដែលយើងអាចរៀនសូត្របានពីការរៀបរាប់នៅតាមរយៈការសម្តែងនេះ។*

*-ខ្ញុំឃើញថា កម្មវិធីហ្នឹងល្អមែនទែន ហើយវាបានជាពិសេស ខ្ញុំចាប់អារម្មណ៍ គឺទាក់ទងទៅនឹងប្រពៃណីរបស់ផង គឺផ្កាស្លា។ អ៊ីចឹងវាជាអត្ថន័យមួយធំទូលំទូលាយសម្រាប់ឲ្យយើងដឹងបន្ថែមទៀតថា ផ្កាស្លាហ្នឹងមានន័យថា ម៉េចសម្រាប់សង្គមខ្មែរ ហើយសម្រាប់អាពាហ៍ពិពាហ៍។]*

*(បញ្ចប់ការបង្ហាញរូបភាពវីដេអូ)*

[១៥:៤៥:០៧]

ខ្ញុំសូមអនុញ្ញាតបញ្ជាក់ផងដែរ ថាគម្រោងនេះ បានទទួលថវិកាការពេញលេញពីទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ស្វីស ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ តាមរយៈអង្គការ ជី.អាយ.ហ្ស៊ិត និងទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍអន្តរជាតិ យូ.អេស.អេ.អាយ.ឌី។ គម្រោងទី៦ គឺសំឡេងពីជនជាតិភាគតិច។ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តមកលើជនភាគតិចចាម និងវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជាសម័យខ្មែរក្រហម។ អង្គការក្តីករុណា សហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះបានបង្កើត និងកំពុងអនុវត្តគម្រោងនេះ ដែលជាគម្រោងដែលបានស្នើឡើងជាសំណងតាមផ្លូវតុលាការ។

[១៥:៤៦:១៧]

គម្រោងនេះ ផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីជាភាគតិចចាម និងវៀតណាម តាមរយៈការប្រមូលចងក្រង និងបង្ហាញឯកសារស្តីពីបទពិសោធន៍របស់គាត់ ហើយក៏ផ្តល់ឱកាសសម្រាប់ការសន្ទនាអន្តរជំនាន់អំពីការធ្វើទុក្ខបុកម្នេញលើពួកគាត់នៅក្នុងសម័យខ្មែរក្រហម។ គម្រោងនេះ លើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីមូលហេតុ និងផលវិបាកនៃអំពើហិង្សាលើជនជាតិភាគតិច និងការរើសអើងមកលើដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនជាតិភាគតិច តាមរយៈតាំងពិព័រណ៍ចល័ត ការសន្ទនាអន្តរជំនាន់ ការបោះពុម្ពផ្សាយរឿងប្រលោមលោក និងវេទិកាល្ខោន។ គម្រោនេះ បានចាប់ផ្តើមអនុវត្តក្នុងខែមករា ឆ្នាំ២០១៦ ហើយនិងបន្តអនុវត្ត នៅខែធ្នូ ឆ្នាំ២០១៧។ គម្រោងផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនជាតិភាគតិចចាម ឬវៀតណាម ហើយគម្រោងនេះ ផ្តល់អំពី -- បរិយាយអំពីព្យសនកម្ម ដែលជាផលនៃឧក្រិដ្ឋកម្មនៅក្នុងវិសាលភាពសំណុំរឿង០០២។ ដោយលើកកម្ពស់យល់ដឹងជាសាធារណៈ ការលើកឡើងអំពីផ្នត់គំនិត និងជំរុញការប្រឆាំងនឹងការរើសអើង ការផ្តល់ឱកាសឲ្យមានការសន្ទនាជាសាធារណៈ និងការចងក្រងឯកសារបទពិសោធន៍របស់ក្រុមជនជាតិភាគតិចទាំងអស់នេះ។ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គការក្តីករុណា បានរៀបចំការតាំងពិព័រណ៍ចល័ត ដែលជាផ្នែកនៃគម្រោងនៅទីក្រុងភ្នំពេញ ដែលមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន១២រូប បានចូលរួម។

[១៥:៤៨:០៧]

នៅថ្ងៃទី០៨ និងថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ មានដើមបណ្តឹងរដ្ឋប្បវេណី១៤រូប មានវត្តមាននៅក្នុងការតាំងពិព័រណ៍ដែលប្រព្រឹត្តទៅនៅខេត្តកំពង់ឆ្នាំង។ ហើយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ មានដើមបណ្តឹងរដ្ឋប្បវេណីប្រាំនាក់ មានវត្តមាននៅក្នុងការដាក់ឲ្យប្រើប្រាស់សៀវភៅរឿងប្រលោមលោក និងការពិគ្រោះយោបល់ក្នុងទីក្រុងភ្នំពេញ។ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ អង្គការក្តីករុណា ត្រូវបានអញ្ជើញឲ្យចូលរួមវេទិកាដើមបណ្តឹងរដ្ឋប្បវេណីដែលរៀបចំនៅខេត្តកំពង់ចាម បង្ហាញគម្រោងសំណងជូនដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៣៦នាក់។ នៅថ្ងៃទី០៦ ដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួននាក់ មានវត្តមាននៅការតាំងពិព័រណ៍ចល័តដែលរៀបចំនៅខេត្តព្រៃវែង។

គម្រោងនេះ បានទទួលថវិការគ្រប់គ្រាន់ពីសំណាក់ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍអាល្លឺម៉ង់ តាមរយៈកម្មវិធី ហ្ស៊ិត.អេហ្វ.ឌី របស់អង្គការ ជី.អាយ.ហ្ស៊ិត និងស្ថានទូតស្វីសប្រចាំនៅក្រុងបាងកក។

ប្រភេទគម្រោងផ្សេងទៀត ដែលខ្ញុំនឹងលើក គឺជាប្រភេទគម្រោងដែលមានគោលដៅផ្តល់នូវការពេញចិត្ត។ ការសងសំណងសហមូភាពដល់ដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈការធ្វើឱ្យពេញចិត្ត សំដៅទៅលើការផ្សព្វផ្សាយរឿងរ៉ាវពិតរបស់ជនរងគ្រោះជាសាធារណៈ។ រំឭកការវិញ្ញាណក្ខន្ធ – រំឭកវិញ្ញាណក្ខន្ធទៅដល់ជនរងគ្រោះ និងការបញ្ចូលរឿងរ៉ាវនៃឧក្រិដ្ឋកម្មនៅក្នុងសម្ភារៈ ផ្សព្វផ្សាយអប់រំនៅគ្រប់លំដាប់ថ្នាក់។ ដើមបណ្តឹងរដ្ឋប្បវេណីភាគីច្រើនបានស្នើសុំឱ្យមានការសាងសង់ស្តូប រំឭកវិញ្ញាណក្ខន្ធ និងការរៀបចំពិធីបុណ្យនានា ហើយពួកគេអាចមានឱកាសនិយាយអំពីរឿងរ៉ាវរបស់ពួកគេដល់សាធារណជន និងមនុស្សជំនាន់ក្រោយ។

[១៥:៥០:១៩]

សហមេធាវីនាំមុខយល់ឃើញថា មានគម្រោងចំនួនបួន ដែលមានគោលដៅឆ្លើយតប ទៅនឹងការផ្តល់សំណង តាមរយៈការធ្វើឱ្យមានការពេញចិត្តដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានទទួលរងព្យសនកម្ម បណ្តាលមកពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២ វគ្គពីរ។ ហេតុដូច្នេះ សហមេធាវីនាំមុខ សូមស្នើជូនអង្គជំនុំជម្រះមេត្តាទទួលស្គាល់គម្រោងទាំងបួន ដែលខ្ញុំនឹងលើកដូចខាងក្រោមនេះ។

ការបោះពុម្ពផ្សាយសៀវភៅស្តីអំពីរឿងរ៉ាវដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ វគ្គពីរនៃអ.វ.ត.ក។ អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា ច្រាក់ ដោយមានកិច្ចសហប្រតិបត្តិការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានរៀបចំគម្រោងការបោះពុម្ពផ្សាយសៀវភៅ ស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២ នៅអ.វ.ត.ក ដែលស្នើឡើងជាសំណងតាមផ្លូវតុលាការ។ គម្រោងនេះ បានបោះពុម្ពសៀវភៅមួយអំពីរឿងរ៉ាវ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានបទពិសោធន៍ឧក្រិដ្ឋកម្ម និងប្រធានបទដែលបានលើកឡើងនៅក្នុងសំណុំរឿង០០២។ គម្រោងចាប់ផ្តើម ប្រមូលរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងខែមិថុនា ឆ្នាំ២០១៥ ហើយអនុវត្តចប់សព្វគ្រប់នៅខែមិថុនា នៅឆ្នាំ២០១៦។ គម្រោងផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្តល់ឱកាសដើម្បីចែករំលែករឿងរ៉ាវបទពិសោធន៍សម្រាប់ផ្សព្វផ្សាយ និងឱ្យមានការទទួលស្គាល់ជាសាធារណៈ ដូចជាការផ្តល់សិទ្ធិអំណាចដល់ដើមបណ្តឹងរដ្ឋប្បវេណី និងការបង្កើតអត្ថន័យនៃយុត្តិធម៌ និងភាពធូរស្បើយតាមរយៈការទទួលស្គាល់អំពីការឈឺចាប់របស់ពួកគាត់។

ក្នុងរយៈពេលនៃការអនុវត្តគម្រោង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣០រូប ត្រូវបានសម្ភាសអំពី

រឿងរ៉ាវ បទពិសោធន៍របស់ពួកគាត់ពាក់ព័ន្ធទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ការធ្វើទុក្ខបុកម្នេញលើពុទ្ធសាសនិកជន ការប្រព្រឹត្តទៅលើជនជាតិភាគតិច មន្ទីរសន្តិសុខ ការដ្ឋានការងារ ឬសហករណ៍ដើម្បីសរសេរចូលក្នុងសៀវភៅ។

[១៥:៥២:៤៣]

សៀវភៅចំនួន៥០០ក្បាល ត្រូវបានបោះពុម្ពសម្រាប់ចែកជូនដល់ដើមបណ្តឹងរដ្ឋប្បវេណី និងស្ថាប័នអប់រំ។ គម្រោងនេះ ត្រូវបានអនុវត្តចប់សព្វគ្រប់រួចហើយ ដោយមានថវិកាឧបត្ថម្ភពីមូលនិធិ *ហែនរិច្ចបូល*។ គម្រោងបន្ទាប់ គឺជាគម្រោងទី៨ ដែលលើកនៅថ្ងៃនេះ គឺ "ពេលដែលត្រូវចងចាំ"។ ការប្រកួតតែងបទចម្រៀងនៅឆ្នាំ២០១៦ ដោយមានការចូលរួមរបស់យុវជនក្នុងការផលិត និងបទចម្រៀងដើម្បីការចងចាំ។ អង្គការកម្មវិធីយុវជន អង្គការកម្មវិធីអភិវឌ្ឍន៍យុវជនបានរៀបចំ និងអនុវត្តចប់សព្វគ្រប់ គម្រោងសំណង"ពេលដែលត្រូវចងចាំ" ការប្រកួតតែងបទចម្រៀងឆ្នាំ២០១៦ ការចូលរួមរបស់យុវជនក្នុងការផលិតបទចម្រៀងដើម្បីចងចាំ ដែលបានស្នើឡើងជាសំណងតាមផ្លូវតុលាការ ដោយសហមេធាវី -- ដោយសហការជាមួយនឹងមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ។ គម្រោងនេះបានទទួលស្គាល់ -- ទទួលស្គាល់បទពិសោធន៍អ្នកដែលរស់រានមានជីវិតពីរបបសម័យខ្មែរក្រហម ដោយជំរុញឲ្យមានការសន្ទនាអន្តរជំនាន់ រវាងដើមបណ្តឹងរដ្ឋប្បវេណី និងមនុស្សជំនាន់ក្រោយ ដើម្បីនិយាយអំពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបាន -- ដែលជាកម្មវត្ថុនៃការជំនុំជម្រះនៅក្នុងសំណុំរឿង០០២ វគ្គពីរ។ សកម្មភាពនៃគម្រោងបានអនុវត្តរវាង ខែមីនា និងខែធ្នូ ឆ្នាំ២០១៦ ហើយមានការគាំទ្រពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ការប្រគុំតន្ត្រីនៅវគ្គផ្តាច់ព្រ័ត្របានប្រព្រឹត្តធ្វើនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦ នៅចំពោះមុខសាធារណជនប្រហែល៤០០នាក់។ ខ្ញុំសូមបញ្ចាំងវីដេអូនេះជូនដូចតទៅ៖

[១៥:៥៤:៥៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*[-ជម្រាបសួរ ខ្ញុំឈ្មោះ រិន ថោវីរៈ សព្វថ្ងៃគឺជាសារព័ត៌មានព្រីខ្មែន បាទ ហើយខ្ញុំមានស្រុកកំណើតនៅក្នុងរាជធានីភ្នំពេញ។ មូលហេតុខ្ញុំដាក់ពាក្យចូលរួមក្នុងការប្រកួតប្រជែងចម្រៀងនៅក្នុងកម្មវិធី "ពេលដែលត្រូវចងចាំ"នេះ ដោយសារតែមានចំណុចសំខាន់ជាច្រើន។ ទី១ ដែលថាខ្ញុំចង់បង្ហាញស្នាដៃពាក់ព័ន្ធជាមួយនឹងការសរសេរទំនុកច្រៀង ពាក់ព័ន្ធជាមួយនឹងរបបខ្មែរក្រហម ការឈឺចាប់និង*

*ទុក្ខសោកផ្សេងៗរបស់ប្រជាពលរដ្ឋក្នុងសម័យនោះ។*

*-ច្រើន គឺមុនដែលខ្ញុំចូលរួមប្រឡងក្នុងកម្មវិធីនេះ គឺខ្ញុំបានស្រាវជ្រាវឯកសារពីឯកសារផ្សេងៗ ដែលទាក់ទងនៅក្នុងសម័យកាលប៉ុល ពត នោះ។ អ្វីដែលជាពិសេស ខ្ញុំបានរៀនពីលោកគ្រូ អ្នកគ្រូខ្ញុំនិងប៉ាម៉ាក់របស់ខ្ញុំផ្ទាល់។*

*-ត្រូវតែចូលរួមទាំងអស់គ្នា ដើម្បីឱ្យពួកយើងផ្សះផ្សាជាតិរបស់ពួកយើងឱ្យកាន់តែល្អប្រសើរ ដើម្បីកុំឱ្យមានរបបដ៏ឃោរឃៅនេះកើតឡើងសាជាថ្មី។ (ចម្រៀង)*

*-បាទ ហើយនៅក្នុងថ្ងៃនេះដែរ អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជនក៏បានរៀបចំកម្មវិធីប្រកួតប្រឡងចម្រៀងនិងរៀបចំកម្មវិធី “ពេលដែលត្រូវចងចាំ” ដើម្បីចង់បញ្ជាក់ឱ្យយុវជនរបស់យើងស្វែងយល់អំពីរបបខ្មែរក្រហម។*

*-ជាបឋមខ្ញុំសូម-- (ចម្រៀង)*

*-ចេញ! ៗ ភ្នំពេញអើយខ្ញុំលាអ្នកហើយ ខ្ញុំគ្មានស្បើយនៅក្នុងឱរ៉ា ខ្ញុំដឹងថាយើងគ្មានសេរី តាំងពីចេញបានមុន--]*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៥:៥៧:៥០]

គម្រោងនេះ បានទទួលថវិកាអំពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និង ការអភិវឌ្ឍន៍អាល្លឺម៉ង់ តាមរយៈកម្មវិធី ហ្ស៊ិត.អេហ្វ.ឌី នៃអង្គការ ជី.អាយ.ហ្ស៊ិត។ គម្រោងទី៩ សម្រាប់ថ្ងៃនេះ គឺផ្ទាំងគំនូរសម្រាប់ការចងចាំអំពីក្រាំងតាចាន់។ អង្គការយុវសន្តិភាព និងវិទ្យាស្ថានសន្តិភាពកម្ពុជា បានបង្កើតនិងអនុវត្តគម្រោងសំណងផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់នេះ ដែលបានស្នើឡើងជាសំណងតាមផ្លូវតុលាការ ដោយមានការសហការជាមួយមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ សម្រាប់ជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ វគ្គពីរ។ គម្រោងនេះបានបង្កើតការតាំងពិព័រណ៍ផ្ទាំងគំនូរនៃការចងចាំនៃមន្ទីរសន្តិសុខជាមួយនិស្សិតសាកលវិទ្យាល័យ ដោយមានការពិគ្រោះយោបល់ពីដើមបណ្ដឹងរដ្ឋប្បវេណី។

គំនូរត្រូវបានបង្ហាញជាសាធារណៈរួចហើយ ហើយកូនសៀវភៅក៏បានបោះពុម្ពដែរ ដើម្បីរំឭកទៅដល់ដំណើរការនៃការបង្កើតផ្ទាំងគំនូរដើម្បីការចងចាំ។ គម្រោងបានដាក់ឱ្យដំណើរការនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៦ ដែលមានសមាជិកសហគមន៍ចំនួន១១៥នាក់ ដែលមានយុវជន ព្រះសង្ឃ តំណាងអាជ្ញា

ធរមូលដ្ឋាន និងជនរងគ្រោះ ឬអ្នករស់រានមានជីវិតមានវត្តមានផងដែរ។

[១៥:៥៩:២៧]

គម្រោងផ្តល់ប្រយោជន៍ទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី ដោយរំឭកដល់បទពិសោធន៍ទៅដល់ពួកគាត់ និងទទួលស្គាល់ការឈឺចាប់របស់ពួកគាត់ ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលកើតឡើងនូវក្រាំងតាចាន់។ គម្រោងនេះក៏ផ្តល់ឱកាសដល់និស្សិតសាកលវិទ្យាល័យដើម្បីចូលរួមជាមួយដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះឲ្យដឹងពីបទពិសោធន៍នៅមន្ទីរសន្តិសុខក្រាំងតាចាន់។

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦ អង្គការយុវសន្តិភាពបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការបង្កើតផ្ទាំងគំនូរដល់ក្រុមនិស្សិតវ័យក្មេង ដែលសិក្សាជំនាញផ្សេងៗ ដែលជាផ្នែកនៃគម្រោង។ ព្រឹត្តិការណ៍នេះបានរៀបចំធ្វើឡើងនៅសារមន្ទីរក្រាំងតាចាន់ ដែលស្ថិតក្នុងខេត្តតាកែវ ហើយក៏មានវត្តមានដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួននាក់ចូលរួមផងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូប បានចូលរួមក្នុងកម្មវិធីដាក់ឲ្យដំណើរការនៃគម្រោងផងដែរ។ គម្រោងនេះបានទទួលថវិកាពីសម្ព័ន្ធអន្តរជាតិនៃទីតាំងសម្បជញ្ញៈ – *អ៊ិនធឺណាស្យូណល ខូអ័រលីស៊ិន អូហ្វ សាយ អូហ្វ ខនសាយអេនស៍*។

គម្រោងទី១០ សម្រាប់ថ្ងៃនេះ គឺការចូលរួមទៅពិនិត្យឯកសាររបស់សាលាក្តីខ្មែរក្រហម និងឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលឯកសារច្បាប់ អ.វ.ត.ក។

នៅឆ្នាំ២០១៣ សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានផ្តួចផ្តើមឲ្យមានកិច្ចពិភាក្សាជាមួយនឹងរាជរដ្ឋាភិបាលតាមរយៈការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក។ ហើយជាលទ្ធផលទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជាបានឯកភាពស្នើគម្រោងការចូលពិនិត្យឯកសាររបស់សាលាក្តីខ្មែរក្រហម និងឯកសាររបស់ដើមបណ្តឹងរដ្ឋប្បណីនៅមជ្ឈមណ្ឌលឯកសារច្បាប់ អ.វ.ត.ក ជាគម្រោងសំណងតាមផ្លូវតុលាការក្នុងសំណុំរឿង០០២ វគ្គពីរ។

[១៦:០១:៣៦]

មជ្ឈមណ្ឌលឯកសារច្បាប់ អ.វ.ត.ក បានបង្កើតឲ្យមានឃ្លាំងផ្ទុកឯកសារដែលមានលក្ខណៈជាសាធារណៈដោយឥតគិតថ្លៃ ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនៃសាលា -- នៃនីតិវិធី និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក។ ព្រឹត្តិការណ៍សាធារណៈនឹងត្រូវបានរៀបចំដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ តាមរយៈបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ គម្រោងនេះនឹងបង្កើតបញ្ជីពេញលេញមួយនៃដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២

ដែលនឹងត្រូវបង្ហាញជាសាធារណៈ។ មិនត្រឹមតែសក្ខីកម្មផ្ទាល់មាត់របស់ពួកគេនឹងឯកសារសាធារណៈនឹងត្រូវដាក់បង្ហាញផងដែរ។

គម្រោងនេះ ផ្តល់ប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួម ចូលទៅពិនិត្យមើលកំណត់ហេតុតុលាការស្តីអំពីការជំនុំជម្រះលើអតីតមេដឹកនាំខ្មែរក្រហម និងតាមរយៈការសម្របសម្រួលដល់ការចូលទៅមើល និងផ្សព្វផ្សាយឯកសារដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារសាធារណៈនានារបស់តុលាការទៅដល់សាធារណជន និងមនុស្សជំនាន់ក្រោយ ពោលគឺស្របទៅនឹងសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការពេញចិត្ត និងការទទួលបានយុត្តិធម៌ ដូចបានកំណត់ក្នុងគោលការណ៍ជាមូលដ្ឋានស្តីអំពីការទទួលបាននូវការប៉ះប៉ូវ និងការសងសំណង។ ដោយហេតុនេះហើយ គម្រោងនេះបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់ជនរងគ្រោះដទៃដែលមិនមែនជាមេ -- ដែលមិនមានមេធាវីតំណាង។

[១៦:០៣:១០]

នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ប្រធានមណ្ឌលឯកសារច្បាប់ អ.វ.ត.ក ត្រូវបានអញ្ជើញឱ្យធ្វើបទបង្ហាញស្តីអំពីគម្រោងនេះជូនដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៣០រូប នៅវេទិកាដើមបណ្តឹងរដ្ឋប្បវេណីមួយ ហើយក៏ទទួលបានមតិយោបល់គាំទ្រពីពួកគាត់ដែរ។

នៅថ្ងៃ១៧ ខែមីនា ឆ្នាំ២០១៧ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៥០រូប ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវេទិកាដែលរៀបចំធ្វើនៅមជ្ឈមណ្ឌលឯកសារកម្ពុជានេះ។ ហើយផ្តល់ឱកាស -- ត្រូវបានផ្តល់ឱកាសឱ្យបានទស្សនាអគារមជ្ឈមណ្ឌល និងត្រូវបានណែនាំអំពីសកម្មភាពនៃគម្រោងផងដែរ។ គម្រោងនេះបានទទួលថវិកាទាំងស្រុងពីរាជរដ្ឋាភិបាលដោយប្រើប្រាស់ថវិកាជាតិ។ អគារមជ្ឈមណ្ឌលតម្កល់ឯកសាររបស់ អ.វ.ត.ក នេះត្រូវបានសាងសង់រួចស្រេចដោយប្រើប្រាស់ថវិកាជំនួយឧបត្ថម្ភពីស្ថានទូតជប៉ុន។

គម្រោងមួយចំនួនទៀតប្រភេទជាការស្តារនីតិសម្បទា។ ការស្តារនីតិសម្បទា ជាវិធានសំណងសម្រាប់ថែទាំ ផ្តល់ការថែទាំវេជ្ជសាស្ត្រ និងចិត្តសាស្ត្រដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ជាច្រើនលើកច្រើនសាថា ការទទួលបានការថែទាំផ្នែកសុខភាពផ្លូវកាយនិងផ្លូវចិត្តគឺជាបំណងប្រាថ្នាចម្បងបំផុតរបស់ពួកគាត់ក្នុងចំណោមការអ្វីដែលពួកគាត់ចង់បាន។

ដូចដែលបានបង្ហាញក្នុងផ្នែកនៃផលប៉ះពាល់ និងបន្តបន្ទាប់នៅក្នុងផ្នែកទី៤ នៃសេចក្តីសន្និដ្ឋានចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នាអំពីការចង់បានរបស់ពួកគាត់នៅក្នុងការថែទាំសុខភាព

ផ្លូវកាយ ផ្លូវចិត្ត ដែលទទួលរងផលប៉ះពាល់មកពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២ វគ្គពីរ។

[១៦:០៥:១០]

មេធាវីនាំមុខពិចារណាថា មានគម្រោងមួយដែលជាបពាក់ព័ន្ធទៅនឹងវិធានការនៃសំណងនេះ ហើយនិងអាចផ្ដល់ប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយដែលមេធាវីនាំមុខនឹងសុំ ស្នើសុំដល់អង្គជំនុំជម្រះទទួលស្គាល់គម្រោងនេះជាគម្រោងសំណងតាមផ្លូវតុលាការផងដែរ គឺជាគម្រោងទី១១ ដែលនិយាយអំពីការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អង្គការចិត្តសាស្ត្រសង្គមអន្តរវប្បធម៌បានរៀបចំបង្កើតគម្រោងសំណងនេះឡើយ ដោយមានកិច្ចសហការពីអង្គការក្ដីករុណា និងដោយមានការគាំទ្រពីសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ។ គម្រោងនេះនឹងផ្ដល់ការព្យាបាលភាពបាក់ស្បាតផ្លូវចិត្តជូនដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតអំពីរបបខ្មែរក្រហមនៅក្នុងខេត្តចំនួន១៥។ គម្រោងនេះនឹង ១) ផ្ដល់សេវាសុខភាពផ្លូវចិត្ត។ ២) ផ្ដល់ការអន្តរាគមន៍ដោយប្រើប្រាស់ការរៀបរាប់រឿងរ៉ាវពិត ហើយនិងការផ្សះផ្សា។ ៣) ផ្ដល់ការអភិវឌ្ឍផ្នែកសមត្ថភាពសម្រាប់បុគ្គលិកគម្រោង និងអ្នកសម្របសម្រួលមូលដ្ឋាននៅក្នុងសហគមន៍គោលដៅ។ ការព្យាបាល ការប៉ះទង្គិចផ្លូវចិត្ត នឹងរាប់បញ្ចូលទាំងការព្យាបាលតាមរយៈការប្រឹក្សាយោបល់ដោយផ្ទាល់តាមទីកន្លែង និងតាមរយៈទូរស័ព្ទ។ ក្រុមជួយខ្លួនឯង និងការព្យាបាលតាមបែបធ្វើសក្ខីកម្ម។ សកម្មភាពនិយាយអំពីរឿងរ៉ាវពិត និងការផ្សះផ្សា ដូចមានជាការសន្ទនាតាមសហគមន៍ ល្ខោន វេទិកា និងការ -- នៃការចងចាំ និងសកម្មភាពផ្សព្វផ្សាយនានារបស់យុវជន ទាំងនេះមានគោលបំណងដើម្បីផ្ដល់ការអប់រំ និងបង្កើនការយល់ចិត្តគ្នា ៗសម្រាប់អ្នករស់រានមានជីវិតពីការធ្វើទារុណកម្ម ឬឧក្រិដ្ឋកម្មផ្សេងទៀត។

[១៦:០៧:១១]

គម្រោងនេះនឹងត្រូវអនុវត្តសម្រាប់រយៈពេលបីឆ្នាំ ចាប់ផ្ដើមពីខែសីហា ឆ្នាំ២០១៦ និងបញ្ចប់នៅខែសីហា ឆ្នាំ២០១៩។ គម្រោងនេះផ្ដល់ប្រយោជន៍ដោយផ្ទាល់ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះនៃការធ្វើទារុណកម្ម ដូចមានជាប្រជាជនចាម កាន់សាសនាអ៊ីស្លាម អ្នករស់រានមានជីវិតពីការរំលោភផ្លូវភេទ និងអ្នករស់រានមានជីវិតអំពីការបង្ខំឲ្យធ្វើការ។

ជាឧទាហរណ៍ និងដូចដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ១១.២ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន

៤៥រូប ត្រូវបានប៉ាន់ស្មានថា នឹងទទួលអត្ថប្រយោជន៍ដោយផ្ទាល់អំពីការព្យាបាលតាមបែបសក្ខីកម្ម និង៥០រូបផ្សេងទៀតបានទទួលអត្ថប្រយោជន៍ដោយផ្ទាល់អំពីក្រុមជួយខ្លួនឯង។ អង្គការចិត្តសង្គមអន្តរវប្បធម៌ ធី.ភី.អូ បានបង្ហាញអំពីគម្រោងនេះទៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៥០រូប នៅក្នុងវេទិកាដើមបណ្តឹងរដ្ឋប្បវេណីដែលរៀបចំនៅមជ្ឈមណ្ឌលឯកសារច្បាប់ អ.វ.ត.ក នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧ ហើយគម្រោងនេះទទួលថវិកាពេញលេញពីទីភ្នាក់ងារសហរដ្ឋអាមេរិក សម្រាប់ការអភិវឌ្ឍ យូ.អេស.អេ.អាយ.ឌី។

មកដល់ត្រឹមនេះគឺមានគម្រោងចំនួន១១ ដែលគាំទ្រដោយមេធាវីនាំមុខទាំងពីររូប ហើយដែលមានថវិកា ហើយដូចបានលោក លោកស្រីមេធាវីនាំមុខអន្តរជាតិបានលើកឡើង គម្រោងដែលមិនមានថវិកាគ្រប់គ្រាន់ ឬក៏មិនមានថវិកាសោះមិនត្រូវបានលើកឡើងនាពេលនេះទេ។ ហើយយើងនឹងស្វែងរកថវិកាបន្ថែមទៀតរហូតទៅដល់ខែ១១ នៃឆ្នាំ២០១៧នេះ។ ហើយជាចុងក្រោយ លោកស្រីមេធាវីនាំមុខអន្តរជាតិស្នើសុំលោកប្រធានរយៈពេលមួយនាទី ដើម្បីនិយាយបន្ថែមអំពីគម្រោងរបស់គាត់។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអញ្ជើញ អង្គជំនុំជម្រះអនុញ្ញាត។

[១៦:០៩:២៨]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំត្រូវការពេលតែមួយនាទីទេដើម្បីបង្ហាញអំពីគម្រោងដែលនេះ ដែលខ្ញុំស្នើសុំឱ្យអង្គជំនុំជម្រះទទួលស្គាល់ជាគម្រោងស្នើសុំសំណងសមស្រប<មួយ>ក្នុងសំណុំរឿង ០០២/០២។ គម្រោងនេះមានចំណងជើងថា ការអប់រំច្បាប់ និងសិទ្ធិពលរដ្ឋសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនជាតិភាគតិច។ <អង្គការ>ដៃគូដែលអភិវឌ្ឍន៍គម្រោងនេះ គឺអង្គការក្រៅរដ្ឋាភិបាល <មានឈ្មោះថា> អង្គការសិទ្ធិជនជាតិភាគតិច <ហៅកាត់ថា មីរ៉ូ>។ គម្រោងនេះត្រូវបានធ្វើឡើងដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះជនជាតិវៀតណាម។ គម្រោងនេះមានគោលដៅដើម្បីអនុញ្ញាតឱ្យជនជាតិវៀតណាមទទួលបានព័ត៌មាន ដែលអាចឱ្យពួកគាត់យល់ច្បាស់អំពីឋានៈផ្លូវច្បាប់របស់ពួកគាត់។ យោងតាមច្បាប់កម្ពុជា គម្រោងនេះ ដូចដែលខ្ញុំបានបញ្ជាក់រួចមកហើយ គឺបានការសហការគ្នាជាមួយដើមបណ្តឹងរដ្ឋ

ប្បវេណីដែលមានដើមកំណើត -- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលមានដើមកំណើតវៀតណាម ដើមបណ្តឹងរដ្ឋប្បវេណី ៣៩នាក់<មកពីខេត្តកំពង់ឆ្នាំង កាលពីខែសីហា ឆ្នាំ២០១៥> ត្រូវបានអញ្ជើញឲ្យមកពិគ្រោះយោបល់ អ្នកទាំងអស់នេះបានស្នើសុំឲ្យមានការអនុវត្តគម្រោងនេះឡើង។ ដើមបណ្តឹងរដ្ឋប្បវេណី២៩នាក់ បានទទួលផលប្រយោជន៍ពីគម្រោងនេះរួចមកហើយ ពីព្រោះថាគម្រោងនេះបានអនុវត្តរួចមកហើយ។ គម្រោងនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយអង្គការ ជី.អាយ.ហ្សិត។

សូមអរគុណលោកប្រធាន សូមអរគុណអង្គជំនុំជម្រះទាំងមូល ដែលបានចាប់អារម្មណ៍ទៅលើការបង្ហាញរបស់យើងខ្ញុំ។ យើងខ្ញុំសូមបញ្ចប់ហើយលោកប្រធាន។

[១៦:១១:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធទី១៤ ខែមិថុនា ឆ្នាំ២០១៧ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង០០២/០២ ហើយដែលនឹងធ្វើដោយសហព្រះរាជអាជ្ញា។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៣ នាទី)*